# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៥ លេខ ១០ ខែ តុលា

ព.ស. ២៥០៥ គ.ស. ១៩៦៣

– ភ្នំពេញ –

# ព្រះរាជក្រឹត្យ

តែងតាំងសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាសម្តេចព្រះសង្ឃរាជ

---

## ព្រះរាជក្រឹត្យ

បានទ្រង់យល់រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៦០១ ប.រ. ចុះថ្ងៃទី ៦ តុលា គ.ស. ១៩៦២ កែប្រែ និងបន្ថែម តាមអត្ថបទក្រោយ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣០ រ.វ. ចុះថ្ងៃទី ៣១ ធ្នូ ១៩៦០ ស្តីពីការរៀបចំក្រសួងនានានៃព្រះបរមរាជវាំង ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ២ រ.វ. ចុះថ្ងៃទី ២៣ មករា ១៩៥៨ ស្តីពីការតែងតាំងអគ្គនាយក ក្រសួងនានានៃព្រះបរមរាជវាំង ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ១២៣ ន.ស. ចុះថ្ងៃទី ៣ មេសា ១៩៥២ ស្តីពីការរៀបចំក្រសួងធម្មការ សាសនសិក្សាធិការ ។

បានទ្រង់យល់ព្រះរាជក្រមលេខ ១២ ន.ស. ចុះថ្ងៃទី ៩ កុម្ភៈ ១៩៤៣ ស្តីពីការរៀបចំក្រុមរាជការ ក្រសួងពុទ្ធចក្រ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានកែប្រែតាមព្រះរាជក្រមលេខ ៦៨ ន.ស. ចុះថ្ងៃទី ១៨ កញ្ញា ១៩៤៣ និងលេខ ១ រ.វ. ចុះថ្ងៃទី ២៦ ឧសភា ១៩៤៨ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ២៩ ន.ស. ចុះថ្ងៃទី ៤ មិថុនា ១៩៤៨ ដែលតែងតាំងព្រះពោធិវង្ស ជួន-ណាត ជាទីព្រះសង្ឃនាយកគណៈមហានិកាយ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៤៣ រ.វ. ចុះថ្ងៃទី ១៨ មេសា ១៩៥០ ដែលតាំងព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន-ណាត ជាទីសម្តេច ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៧ រ.វ. ចុះថ្ងៃទី ៣១ មករា ១៩៥៦ តែងតាំងព្រះពុទ្ធាចារ្យ កុល-ខេស រាជាគណៈថ្នាក់ទី ១ គង់វត្តបទុមវតី ជាសង្ឃនាយកស្តីទី ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ១៤ រ.វ. ចុះថ្ងៃទី ២៨ កុម្ភៈ ១៩៥៨ តែងតាំងព្រះមហាថេរ កុល-ខេស ជាសង្ឃនាយកគណៈធម្មយុត្តិពេញទីហើយទ្រង់ដំឡើង ឋានន្តរកិត្តិយសជាទីសម្តេចព្រះសុធម្មាធិបតី ។

តាមព្រះរាជបំណងយើង ។

## ត្រាស់បង្គាប់

ប្រការ ១ — ទ្រង់សព្វព្រះរាជហឫទ័យលើក ព្រះឋានន្តរ-សក្តិជា៖ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១

ដល់សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយក

គណៈមហានិកាយ ។

សម្តេចព្រះសង្ឃរាជថ្នាក់ទី ២

ដល់សម្តេចព្រះសុគន្ធាធិបតី កុល-ខេស សង្ឃនាយកគណៈធម្មយុត្តិកនិកាយ ។

ប្រការ ២ – ស័ព្ទដែលត្រូវប្រើទៅកាន់ សម្តេចព្រះសង្ឃរាជ ទាំងពីរព្រះអង្គនេះ គឺជាស័ព្ទដែលប្រើសម្រាប់រាជស័ព្ទ ។

ប្រការ ៣ – សម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ មានសិទ្ធិ ត្រូវបានបុព្វសិទ្ធិដូចខាងក្រោម៖

ព្រះសុវណ្ណកោដ្ឋ ពិសេស

ផ្លិតស្រួច ពិសេស

រងព្រះសិរ ពិសេស

ទង់សម្រាប់ព្រះទីនាំងរថយន្ត

បុព្វសិទ្ធិទាំងនេះ មានផ្ទៃពណ៌លឿងនិងរូបព្រះសង្ហ នៅលើព្រះទីនាំងរថយន្តខាងស្តាំ មានទង់សាសនា ខាងឆ្វេង មានទង់សម្រាប់សម្តេចព្រះសង្ឃនាយក ។

ប្រការ ៤ – អ្នកឧកញ៉ាវាំងវរៈវៀងជ័យ អគ្គនាយក ក្រសួងនានានៃព្រះបរមរាជវាំង និងអ្នកអង្គម្ចាស់ រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការ ត្រូវទទួលការចាត់ការរៀងខ្លួនឲ្យបានសម្រេច

តាមព្រះរាជក្រឹត្យនេះ ។

ធ្វើនៅព្រះបរមរាជវាំងក្រុងភ្នំពេញ នៅថ្ងៃទី ២៨ វិច្ឆិកា ១៩៦៣

ព្រះហស្តលេខា : ន.សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខា សម្តេចព្រះប្រមុខរដ្ឋ

អ្នកឧកញ៉ាវរៈវៀងជ័យ អគ្គ

នាយកក្រសួងនានា នៃព្រះបរមរាជវាំង

ហត្ថលេខា: សានយុន



សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយបានឡើងព្រះឋានៈជាសម្តេច
ព្រះសង្ឃរាជទី ១ នៃគណៈមហានិកាយ នៅថ្ងៃទី ២៨ វិច្ឆិកា ១៩៦៣



សម្តេចព្រះសុគន្ធាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ បានឡើងព្រះឋានៈជាសម្តេច សង្ឃរាជទី ២ នៃគណៈធម្មយុត្តិនៅថ្ងៃទី ២៨ វិច្ឆិកា ១៩៦៣

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា នឹងអក្សរសាស្ត្រ
បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

- មិនគួរភ្លេចសំដីដើម (វិហារណកថា) លោក ផេង-ជ្រីវ តែងរៀបរៀង . . . ៩៩១
- ប្រវត្តិ នឹងកិត្តិគុណរបស់ធម៌ ព្រះមុនីកោសល សួរ - ហាយ តែងរៀបរៀង . . . ៩៩៦
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ - ប៊ូ តែងរៀបរៀង (ត). . . ១០០៧
- មហោសធជាតក (ត) . . . . . . . . . . ១០១៦
- ខ្ទីនបាស់ម្នាក់ឈ្មោះ កច្ចានី សែនខ្វិសផលទៅឲ្យឡោចធម៌សុចរិត
  ព្រះសាសនមុនី កឹម - តូ តែងរៀបរៀង . . . . . . . . ១០២៧

*ផ្នែកអក្សរសាស្ត្រ*

- អំពីបោរកម្ម (វិហារណកថា) រៀបរៀង ដោយលោក ផេង - ជ្រីវ . . . ១០៣៦
- ដើមកំណើត នឹងការវិវត្តន៍ នៃអារ្យធម៌ខ្មែរ ដោយ លី - ធាមតេង . . . ១០៤១
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង - ខាត់ រៀបរៀង (ត) . . . ១០៤៧
- រឿងសាមកុក អ្នកចកញ៉ាវិបុលរាជសេនា នូ - កន ប្រែរៀបរៀង (ត) . . . ១០៥៩
- ល្បើកឃ្លាហ្វុងតែន លោកផេង - ជ្រីវ ប្រែពីភាសាបារាំង (ត) . . . . ១០៦៦
- រឿងព្រេងពួកគុង (ការបែងចែក) លោក វ៉ាយ - ប៊ុក ប្រែពីភាសាបារាំង (តចប់) . ១០៧២
- សំបុត្រ ទី ៦ របស់លោកនេរុ លោក ឈន-អៀម ប្រែពីភាសាអង់គ្លេស . . . ១០៧៧
- របាំរុកអង្រែ ( ទំនៀមទម្លាប់ខ្មែរ ) . . . . . . . . ១០៨៣

*ផ្នែកកំណត់នឹងប្រវត្តិការណ៍*

- បាតុកម្មខាងព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា . . . . . . ១០៩០
- សារាចរ ស្តីអំពីការ គាំពារ ថែរក្សាបូរាណវត្ថុជាតិ . . . . . ១០៩៥

## ផ្នែកសាសន

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក ឲ្យធ្វើល្អទៅ
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.ព.

### វិចារណកថា

# មិនគួរភ្លេចសំដីដើម

*លោក ដេង-ជ្រីវ រៀបរៀង*

ខ្ញុំព្រះករុណាលើករឿងនេះមកពិចារណាដោះស្រាយ ដើម្បីជាវិភាគទានមួយតូច ផ្នែកខាងការរំលឹក ដល់ព្រះតេជព្រះគុណជាសមណៈទាំងឡាយខ្លះ ក្នុងដំណើរជីវភាពនៃព្រះអង្គក្នុងពុទ្ធសាសនា ។

តាមការបានឮ បានឃើញនិងការសង្កេត មានកុលបុត្រភាគខ្លះ បានចេញចាកភេទគ្រហស្ថ ហើយចូលកាន់ភេទអ្នកបួសក្នុងព្រះពុទ្ធសាសនា ជាសាសនាដែលមានគោលដៅគឺការស្ងប់ ច្រើនតែភ្លេចសំដីដើមរបស់ខ្លួន គឺថា លុះបានចូលស៊ីបក្នុងសាសនាកាលណា បែរជាមិនសូវមានការទាក់ទងនឹងការស្ងប់ ៗ ព្រះតេជព្រះគុណបានសិក្សាច្បាប់ព្រះពុទ្ធសាសនាសព្វគ្រប់ហើយ បើខ្ញុំព្រះករុណាយកច្បាប់នេះមកលាតត្រដាងអធិប្បាយពន្យល់

នោះ ទើបធ្លាក់ចុះក្នុងបុរាណភាសិតថា : «ប្រដៅក្រពើហែលទឹក» ៗ

ពិតមែនហើយ មនុស្សបុថុជ្ជន ទោះបីជាគ្រហស្ថក្តី ជាបព្វជិតក្តី មិនមានជនណាម្នាក់អាចហ៊ានប្រកាសថាខ្លួនកាន់ច្បាប់ដ៏ទៀងទាត់ប្រសើរជាងជនដទៃបានឡើយ តែទោះយ៉ាងនេះក៏ដោយ គង់មានជនខ្លះ ឬ ក្រុមជនខ្លះ មានស្មារតីល្អ រលឹកញយ ៗ ដល់ច្បាប់ ឬ ពាក្យសំដីដែលខ្លួនបានសិក្សា ដែលខ្លួនបានសន្យានោះដែរ ការរលឹកញយ ៗ នេះហើយ ជាកត្តាដ៏យ៉ាងសំខាន់មួយ សម្រាប់ញាក់ទាញចិត្តភ្ញាក់ភ្ញាំងរបស់យើង ឲ្យវិលមករកគន្លងត្រូវបានខ្លះដែរ ៗ

ព្រះតេជព្រះគុណជាតួ ឬ ជាគំរូ នៃសេចក្តីស្ងប់ នៃសេចក្តីសន្តោស នៃសេចក្តីករុណា នៃសេចក្តីខន្តី នៃការប្រាថ្នាតិច នៃសេចក្តីមិនត្រូវការរែកមុខរែកមាត់ នៃសេចក្តីសប្បុរស របស់គ្រហស្ថទាំងឡាយ ៗ ការកង្វល់ឥតមានស្រាក ព្រោះតែសេចក្តីត្រូវការ ជាភារៈដាច់ណាត់របស់អ្នកគ្រប់គ្រងផ្ទះ ៗ ព្រះតេជព្រះគុណ នៅពេលដែលចូលស៊ុបជាពុទ្ធបុត្រហើយ មានការស្រាល ឬ មានព្រះហឫទ័យដាច់ស្រឡះពីកង្វល់ក្នុងសម្ភារៈហើយ ៗ តែងផ្ញើជីវភាពដោយស្ងប់ នេះគឺការណ៍ពិតជាបឋម ៗ គួរគប្បីព្រះតេជព្រះគុណសមណៈនោះនោះ សើរើត្រិះរិះនឹងពិចារណាក្នុងពេលណាមួយជាចម្តងល្បងមើល ៗ

ចំពោះការខ្ពស់មុខ ចំពោះសក្តិយស ( សមណសក្តិ ) ចំពោះការ

បានលាភទឹងមិនបានលាភ រឿងអស់នេះ បើតាមការណ៍ដែលខ្ញុំព្រះករុណាបានដឹងខ្លះ មិនជាការចាំបាច់របស់ពុទ្ធបុត្រឡើយ ។ តែ ប្រសិនបើជាត្រូវបានវិញ ក៏គប្បីទទួលយកដែរ ក្នុងសភាពសមរម្យ ។ គួរតែយកប្រវត្តិនៃព្រះពុទ្ធអង្គ មកលាតត្រដាងជានិច្ចនៅខាងមុខ ទុកជាអារម្មណ៍ ដើម្បីកាំងចិត្ត ដើម្បីធ្វើជារបងចិត្ត ។ ព្រះតេជព្រះគុណទាំងឡាយជ្រាបស្រាប់ហើយ ជាចិត្តជាតែរញ្ជាក់រញ្ជៀវណាស់ ជាតែរហ័សណាស់ ជាតែឃ្លេងឃ្លោងណាស់ ប្រៀបបានទឹងសត្វស្វាឬគោព្រៃសហតកខ្សែ តែបើមានការឃាមឃ្លាំងឃាំជានិច្ច តាមខ្ញុំព្រះករុណាយល់ វាគ្រាន់បើណាស់ដែរ ដូចជាសត្វសិង្ហ ឬសត្វខ្លារបស់អ្នកសិល្បៈសៀក (cirque) សត្វទាំងពីរបែបនេះ ជាសត្រូវនឹងមនុស្ស ជាសត្រូវនឹងសត្វដទៃ ព្រោះវាមានមហិទ្ធិរិទ្ធិ ហើយនិយមយកសាច់ជាអាហារផង តែអ្នកសិល្បៈសៀក អាចយកសត្វពីរប្រភេទនេះមកឲ្យនៅកណ្ដាលជំនុំចំណោមមហាជនដែលជាអ្នកខ្លាចស្លាប់ឲ្យរាំ ឲ្យដើរ ឲ្យតេ់ចុះឡើងដើម្បីទស្សនាបាន ។ សួរថាសត្វសាហាវទាំងពីរបែបនេះ ហេតុដូចម្ដេច ក៏មិនស្ទុះទៅខាំទស្សនជន? ឆ្លើយថាមកពីគេដាក់ទ្រុងវា គេមានរបាំងវា គេតាមថែរក្សាវា កុំឲ្យវាអាចទៅធ្វើអំពើព្រៃផ្សៃបាន ។

ចុះចំណែកចិត្តរបស់មនុស្ស ជាពិសេស របស់ព្រះតេជព្រះគុណសមណៈទាំងឡាយនោះ នឹងមានអ្វីជារបាំង ជារបងសម្រាប់កាំង សម្រាប់ស្កាត់ដែរ?

មិនមានអ្វីក្រៅពីស្មារតីឡើយ ។ ដូច្នេះ ទើបខ្ញុំព្រះករុណា ចូលចិត្តទុកស្មារតី ជាកត្តាដ៏ចម្បងបំផុត ក្នុងការស្ទាក់ចិត្តដែលច្រួលច្របល់ងាកទៅរកផ្លូវខុស ។ ព្រះតេជព្រះគុណសមណៈទាំងឡាយនោះ គួរទស្សាហ៍ទឹកទៅរកពេលខាងដើម គឺពេលដែលព្រះតេជព្រះគុណស្ថិតនៅក្នុងព្រះវិហារកណ្តាលជំនុំសង្ឃ ២១ អង្គ ហើយមានព្រះតេជព្រះគុណមួយអង្គចាស់គង់ពីខាងមុខ ដែលហៅថាព្រះឧបជ្ឈាយ៍នោះ ។ ពេលនោះ ព្រះតេជព្រះគុណនៅជានាគនៅឡើយ ហើយព្រះតេជព្រះគុណពោលចំពោះជំនុំសង្ឃថាដូចម្តេច? ព្រះតេជព្រះគុណសន្យាខ្លួនឯងថាដូចម្តេច? ឯវិធីភេទដែលព្រះតេជព្រះគុណបានបញ្ចេញកណ្តាលជំនុំសង្ឃ បើតាមខ្ញុំព្រះករុណានៅចាំគឺជាបឋម ការប្រគល់សំពត់កាសាវៈដល់ព្រះឧបជ្ឈាយ៍ សូមឲ្យលោកបំបួសព្រះតេជព្រះគុណ ដើម្បីប្រព្រឹត្តសមណធម៌ និងរលាស់ចោលនូវទុក្ខទាំងពួង ។ កាលណាព្រះឧបជ្ឈាយ៍បានទទួលយកសំពត់កាសាវៈហើយ នាគទូលព្រះឧបជ្ឈាយ៍ទៀតថា: សូមព្រះឧបជ្ឈាយ៍យកសំពត់កាសាវៈនេះបំបួសខ្ញុំ ដើម្បីបានប្រព្រឹត្តសមណធម៌ និងរលាស់ចោលនូវទុក្ខទាំងពួង ។ ពេលដែលនាគបានស្លៀកដណ្តប់សំពត់កាសាវៈហើយ ខ្ញុំត្រូវមកអង្គុយចំពោះព្រះភក្ត្រឧបជ្ឈាយ៍ម្តងទៀត ឧបជ្ឈាយ៍ប្រទានតចបញ្ចកកម្មដ្ឋានគឺ កេសា លោមា នខា ទន្តា តចោ ជាផ្លូវពិចារណាថាសក់ រោម ក្រចក ធ្មេញ ស្បែកជាដើមនេះ សុទ្ធសឹងតាំងនៅក្នុងព្រះត្រៃលក្ខណ ។

សេចក្ដីប៉ុន្មាននេះហើយ ជាសំដីដើមដំបូងបង្អស់ ហើយសំខាន់អស្ចារ្យ ដែលហូរចេញយ៉ាងស្មោះត្រង់ ពីដួងចិត្តដ៏បរិសុទ្ធនៃព្រះតេជព្រះគុណ សមណៈទាំងឡាយនោះ នៅខណៈនៃការឆ្លងកាត់ពីភេទមួយទៅភេទមួយ ដែលគេនិយមទុកជាឧត្តមភេទ ៗ

តាមការយល់ ហើយប្រហែលជាមិនឃ្លៀងឃ្លាតប៉ុន្មាន ថាគួរគប្បី ព្រះតេជព្រះគុណសមណៈទាំងឡាយនោះ ឧស្សាហ៍រំលឹកសំដីនៃព្រះអង្គនេះឲ្យបានញយ ៗ នោះលោកធម៌នឹងមិនសូវគ្របសង្កត់ មិនសូវញាំញី មិនសូវធ្វើទុក្ខបុកម្នេញនូវព្រះអង្គពេក ៗ បើកាលណាធម៌នេះមានកំឡាំងខ្សោយ សមណៈអធិករណ៍នឹងចិត្តកង្វល់ ក៏នឹងខ្សោយដែរជាលំដាប់ ម៉្លោះហើយសេចក្ដីសុខ ការស្ងប់ ត្រូវតែកើតមានដល់ព្រះអង្គ ៗ

ជាអវសាន ខ្ញុំព្រះករុណា សូមបញ្ជាក់ថា អត្ថបទនេះ មិនមែនជាការរិះគន់ មិនមែនជាការប្រមាថ គឺជាការរំលឹកដោយសុទ្ធចិត្ត ដើម្បីចៀសវាង ឧបសគ្គអធម៌ពីខាងក្រៅ ដើម្បីការពារព្រះតេជព្រះគុណសមណៈទាំងឡាយនោះនឹងអំពើមិនគប្បីរបស់អសប្បុរស ដែលនឹងធ្លាក់មកលើព្រះពុទ្ធសាសនាដ៏ប្រសើរតែប៉ុណ្ណោះ ៗ

# ប្រវត្តិនិងកិត្តិគុណរបស់ធម៌

រៀបរៀងដោយ

ព្រះមុនីកោសល សុវ-ហា យរអធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក

---

ធម៌គឺសេចក្ដីពិត បានចាប់កំណើតនៅក្នុងលោករស់ជាធម្មតា ឋិតនៅជាចន្លោះនៃសេចក្ដីវិនាស ជាចន្លោះនៃពាក្យថា «ចាស់គ្រាំគ្រា» ។ ធម្មតាវត្ថុ ៗ ទាំងអស់ក្នុងលោក មានប្រាក់មាស រទេះ ផ្ទះជាដើម ដែលគេសិទ្ធសូន្យគាត់តែងកសាងឡើងហើយ រមែងមានរូបប្រែប្រួល ទៅផ្សេង ៗ តាមកាលសម័យដែលនិយមរាប់អាន ជួនកាលវត្ថុដែលមិនមែនជាមាសប្រាក់សុទ្ធទេ ប៉ុន្តែគេអាចកាឡៃ ធ្វើដោយក្លែងក្លាយឲ្យមាន ពណ៌ដូចប្រាក់ មាសសុទ្ធក៏បាន ។ មាសប្រាក់កាឡៃនោះក្ដី រទេះ ឬផ្ទះជាដើមក្ដី រមែងចាស់គ្រាំគ្រាទ្រុឌទ្រោម ដែលធ្លាប់មានតម្លៃក៏ត្រឡប់ ទៅជារបស់ឥតតម្លៃវិញ ។ មួយទៀត វត្ថុមានមាសប្រាក់ជាដើមដែល ជារបស់ក្លែងក្លាយ កាលបើគេដឹងច្បាស់ថា ជារបស់ក្លែងក្លាយហើយ គេក៏លែងត្រូវការរបស់ទាំងនោះ សេចក្ដីនេះ យ៉ាងណាមិញ ច្បាប់ទំលាប់ក្នុងលទ្ធិណាមួយ ដែលគេធ្លាប់គោរពជឿ ដោយឥតពិចារណា រកហេតុផល ជាច្បាប់ដែលគេតាក់តែងឡើង ដោយឧបាយមិនសម

ហេតុផល គឺជាដំណើរមិនស្របទៅតាមសេចក្ដីពិត ច្បាប់ទម្លាប់ទាំងនោះ គង់ត្រូវអ្នកផង ដែលមានប្រាជ្ញា ធ្លាប់បានស្ដាប់ស្ទង់ពិចារណា អាចយល់ទាស់កំហុសបាន ថាជាច្បាប់មិនពិត ព្រោះមិនសមហេតុផល បើទុកជាគេមិនចាប់ថ្នាក់ ក៏គង់គេដឹងបាន ហើយគេកងចាលលែងគោរពតទៅទៀត ៗ ច្បាប់នោះក៏ទៅជារបស់រៀវរោយ សាបរលាប លែងមានអ្នកណាមួយគោរពជឿកុះចូលក៏យ៉ាងនោះដែរ ៗ

ទើបឯព្រះធម៌ មានសភាពពិតមែនគឺច្បាប់ ដែលស្របតាមហេតុផលតែងមានអាយុជីវិតរស់នៅប្រចាំលោកជាស្ថាពរ មិនចេះចាស់គ្រាំគ្រា មិនចេះរៀវរោយ សាបសូន្យ ថយចុះដូច្នោះឡើយ ៗ

ស្វាក្ខាតធម៌ : ដែលព្រះសម្មាសម្ពុទ្ធរបស់យើង ទ្រង់បានត្រាស់ដឹងឡើងហើយ ទ្រង់ប្រកាសប្រដៅមនុស្សក្នុងលោក កាលដើមដំបូង មិនសូវមានមនុស្សជ្រះថ្លាជឿកាន់ច្រើនប៉ុន្មានទេលុះកាលខាងក្រោយមក ទើបពួកទេវតា នឹងមនុស្សបានដឹងឮសុសសាយច្រើនគ្នាស្ញើចសរសើរថា ឱហ្ន៎ ! នេះជាធម៌ពិតប្រព្រឹត្តទៅដើម្បីសេចក្ដីសុខក្សេមក្សាន្ត រួចនាំគ្នាប្រព្រឹត្តប្រតិបត្តិកាន់តាម ដើម្បីលត់ភ្លើងកិលេស ភ្លើងទុក្ខ ហេតុបានមគ្គផលនិព្វាន តាមនិស្ស័យវាសនា យ៉ាងស័ក្ដិសិទ្ធិ ដូចទឹកសម្រាប់លត់ភ្លើង ៗ ធម៌គឺសេចក្ដីពិត មានអាយុជីវិតដ៏មាំមួន ជារបស់មិនចេះចាស់ ថ្នូ មិនចេះស្លាប់ អាចរស់នៅឋិតថេរទាំងមានតម្លៃអង្វែងគត

ទៅមិនចេះចុះថ្ងៃឡើយ សេចក្ដីនេះ គប្បីសន្និដ្ឋានបានដោយងាយ ដូចយ៉ាងធម៌របស់ព្រះសម្ពុទ្ធនៃយើងទាំងឡាយ ដែលព្រះអង្គសំដែងឡើងតាមពិត មិនវិបរិតខុសពាក្យសេចក្ដីពិត បើយើងគិតតាំងអំពីឆ្នាំដែលព្រះអង្គបរិនិព្វាន មកដល់ឥឡូវនេះបាន ២៥០៦ ឆ្នាំ ហើយ ទោះបីយូរអង្វែងមកប៉ុណ្ណោះ ព្រះធម៌នោះ ក៏នៅថ្មីទៀងទាត់ដដែល ដូចប្រក្រតី ឥតមានចាស់គ្រាំគ្រា ប្រែប្រួល ខូចតម្លៃយ៉ាងណា ៗ ឡើយ ។

ពុទ្ធភាសិត ដែលមានមកក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ បញ្ជាក់ចំពោះពាក្យថា «ធម៌» របស់លោកអ្នកសប្បុរស មានព្រះសម្ពុទ្ធជាដើម ជាធម៌មិនចេះចាស់គ្រាំគ្រា ឬមិនចេះសាបសូន្យ កាលបើមិនមានសេចក្ដីចាស់គ្រាំគ្រាទេ សេចក្ដីឈឺចាប់ក៏មិនមាន កាលបើសេចក្ដីឈឺចាប់មិនមានទេ សេចក្ដីស្លាប់ក៏ពុំមានឡើយ ។ សេចក្ដីចាស់គ្រាំគ្រាមានចំពោះតែវត្ថុដែលមានរូបដូចយ៉ាងរទេះ ផ្ទះសម្បែង និងរូបកាយ របស់មនុស្សសត្វប៉ុណ្ណោះ ។

ពាក្យថា ធម៌ ដែលអធិប្បាយមកនេះ សំដៅយកសេចក្ដីពិតជានាមធម៌ គឺសេចក្ដីល្អ អាក្រក់ ជាធម្មជាតិឥតមានរូបកង គឺមានតែនាមដែលចាប់កំណើតនៅក្នុងលោកសម្រាប់ដឹងបាន ដោយបញ្ញាចក្ខុប៉ុណ្ណោះ ឥតមាននរណាមួយស្រាវជ្រាវរកប្រវត្តិឲ្យឃើញថាធម៌នេះ ចាប់កំណើតពីកាលណា ៗ បានឡើយ ដូចភ្លើងនិងខ្យល់ដែលគេមិនអាចដឹងដើម

កំណើតបានដូច្នោះដែរ គឺជាធម្មជាតិ តែងកើតមានទៅប្រចាំលោកជាធម្មតា ។

សេចក្ដីអធិប្បាយខាងលើនេះ អាចយល់បានថា កុសលកម្មនិងអកុសលកម្ម តែងរស់នៅជាស្ថាពរប្រចាំលោកជានិច្ច ទាំងមគ្គផលនិព្វានក៏មានទៅប្រាកដ មិនត្រូវវិនាសបាត់បង់ចាកលោក ដោយអន្តរាយណាមួយឡើយ សូម្បីលោកធាតុទាំងមូលត្រូវភ្លើងឆេះ កុសលាកុសលកម្មនិង មគ្គផលនិព្វាន អាចតាំងនៅដដែល មិនចេះរលត់រលាយបានទេ ចំណែកខាងពាក្យរិះគន់របស់ពួកជនខ្លះដែលនិយាយឡើងថា ធម៌ ថ្មី ធម៌ចាស់សាបសូន្យទៅហើយនោះ កប់ថាជាមោឃៈ (ជាពាក្យឥតប្រយោជន៍) ។ សូមលោកអ្នកទាំងឡាយ ប្រើវិចារណញ្ញាណឲ្យហ្មត់ចត់ ឲ្យឃើញច្បាស់ថា ធម៌របស់លោកអ្នកសប្បុរសមានព្រះសម្ពុទ្ធជាដើមនោះ មិនមានថ្មី មិនចាស់ទេ មិនចេះសាបសូន្យឡើយ ព្រោះធម៌ជាសភាវៈឥតរូប មានតែនាម សម្រាប់សិក្សាប្រតិបត្តិប៉ុណ្ណោះ មានពាក្យថា ថ្មីចាស់ សាបសូន្យ ចំពោះតែរបស់មានរូប ដូចយ៉ាងរូបសាស្ត្រាស្លឹករឹត ឬសៀវភៅជាដើម ។ សូមលោកអ្នកបែរទៅពិចារណាតាមពុទ្ធភាសិតថា (រាជរថទាំងឡាយ ដែលជាងរចនាល្អហើយ រមែងដល់នូវសេចក្ដីចាស់គ្រាំគ្រាសាបសូន្យ សូម្បីសរីរកាយរបស់សត្វទាំងឡាយ ក៏ដល់នូវសេចក្ដីចាស់គ្រាំគ្រាសាបសូន្យដូចគ្នាដែរ ទើប

ធម៌របស់លោកអ្នកសប្បុរសមានព្រះសម្ពុទ្ធជាដើម មិនដល់នូវសេចក្តីគ្រាំគ្រាដូច្នោះឡើយ ។

ពាក្យថា « ធម៌ » របស់លោកអ្នកសប្បុរស បានដល់ធម៌ ៣ យ៉ាងគឺ :

១ – បរិយត្តិធម៌ បានដល់ច្បាប់សម្រាប់សិក្សា ,

២ – បដិបត្តិធម៌ បានដល់ច្បាប់សម្រាប់ប្រតិបត្តិ ,

៣– បដិវេធធម៌ បានដល់ការត្រាស់ដឹង ។

ពុទ្ធវចនៈ គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បានដល់ព្រះត្រៃបិដក គឺព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម ដែលព្រះសម្ពុទ្ធទ្រង់សំដែងទុកមកជាពុទ្ធបញ្ញត្តិក៏មាន ជាពុទ្ធានុញ្ញាតក៏មាន ដើម្បីឲ្យពុទ្ធបរិស័ទរៀនសូត្រឈ្មោះថា បរិយត្តិធម៌ ។

កុសលធម៌ទាំងឡាយ មានទាន សីល ភាវនា ជាដើមដែលជាធម៌គួរពុទ្ធបរិស័ទគោរពប្រតិបត្តិកាន់តាម ឈ្មោះថា បដិបត្តិធម៌ ។

កាលបុគ្គលជាបព្វជិត ជាគ្រហស្ថ មានសទ្ធាជ្រះថ្លា បានប្រតិបត្តិតាមដោយគោរព ចំពោះកុសលធម៌ទាំងឡាយនោះហើយ រមែងបាននូវគុណវិសេសដ៏ខ្ពង់ខ្ពស់បំផុតគឺ ការត្រាស់ដឹងមគ្គផលនិព្វានដែលជាគោលដៅរបស់ព្រះពុទ្ធសាសនា នេះឈ្មោះថា បដិវេធធម៌ ។

ធម៌ទាំង ៣ យ៉ាង ដូចរៀបរាប់ខាងលើនេះ មិនមានឈ្មោះថាធម៌

ចេះចាស់ឈឺចាប់ស្លាប់ឡើយ ដោយហេតុថា ជាសភាវៈឥតរូបកងកាយ គឺគ្រាន់តែជាច្បាប់សម្រាប់សិក្សា សម្រាប់ប្រតិបត្តិប៉ុណ្ណោះ ៗ វត្ថុដែលមានរូបរាងអស់ដូចយ៉ាងនេះ ផ្ទះសម្បែង នឹងរូបមនុស្សសត្វជាដើម ទើបមានថ្មី មានចាស់ មានជម្ងឺមានមរណៈ ៗ

## សេចក្តីពិត មិនសាបសូន្យ

បុណ្យ គឺអំពើល្អ បាប គឺអំពើអាក្រក់ គុណ គឺសេចក្តីចំរើន ទោស គឺសេចក្តីវិនាស ទាំង ៤ យ៉ាងនេះជាដើមឈ្មោះថាជាប្រវត្តិគឺជាដើមកំណើតរបស់ពាក្យថាធម៌ ដែលជាសេចក្តីពិតរស់នៅប្រចាំលោកជាដរាប សូម្បីក្នុងកាលលង្វែក គឺកាលដែលមិនមានព្រះពុទ្ធត្រាស់ដឹងឬមិនមានអ្នកប្រាជ្ញ ក៏គង់មានបុណ្យ មានបាប មានគុណ មានទោសតាំងនៅជាប្រក្រតី ឥតមានសាបសូន្យ ចាកលោកធាតុឡើយ ៗ បើបុគ្គលណាមួយក្នុងលោកមាន កាយ វាចា ចិត្ត ប្រព្រឹត្តល្អ ត្រូវតាមសីលធម៌ មានព្រហ្មវិហារ ផ្សាយទៅក្នុងពពួកសត្វគ្រប់ទិស មានកតញ្ញូកតវេទិតាធម៌ ចំពោះលោកអ្នកមានគុណ មានមាតាបិតាជាដើម បុគ្គលនោះរមែងបានទទួលផលបុណ្យ ដោយការជួបប្រទះនឹងសេចក្តីសុខចម្រើនដោយពិត បើបុគ្គលប្រព្រឹត្តអាក្រក់ ដោយមិនមានគុណធម៌ មិនមានព្រហ្មវិហារ មិនមានកតញ្ញូកតវេទិតាធម៌ ចំពោះលោកអ្នកមានគុណក៏រមែងទទួលផល បាប ទទួលទោសដោយខ្លួនឯង មិនចាំបាច់

នរណាមួយប្រគល់ផលបុណ្យបាបឲ្យឡើយ នេះជាសេចក្តីបញ្ជាក់ឲ្យឃើញថា បុណ្យ បាប គុណ ទោស ជារបស់មាននៅក្នុងលោកជាធម្មតាមិនមែនកប់ថាថ្មីចាស់ឬសាបសូន្យទេ ។ ពាក្យថា បុណ្យ បាប គុណ ទោស ទាំងនេះឈ្មោះថាធម៌ ព្រោះជាសភាវៈទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ។

បុណ្យបាបជាដើមនេះ ឈ្មោះថាជា ប្រវត្តិរបស់ធម៌ ដែលចាប់កំណើតកើតឯង ហើយតាក់ឬសជាប់នៅក្នុងលោកដោយទៀងទាត់ មិនចេះចាស់គ្រាំគ្រា ឬវិនាសសាបសូន្យដោយពិត ប៉ុន្តែជារបស់ស្ងាត់កំបាំងអំពីប្រាជ្ញា របស់មនុស្សបថុជ្ជន ដូចភ្លើងជារបស់មាននៅទៀងទាត់ ចាប់កំណើតនៅជាប់ទីងអាកាស ឬនៅក្នុងដើមឈើ កាលបើគេចេះវិជ្ជាខាងគ្រឿងផ្សំធាតុត្រូវតាមហេតុផល ភ្លើងក៏អាចឆេះលះជាអណ្តាតឡើងបាន បើមិនចេះគ្រឿងផ្សំទេ ភ្លើងក៏មិនអាចឆេះឡើងបានឡើយ ។ មួយទៀត ព្រះធម៌ដូច ឱសថ គឺថ្នាំសម្រាប់រម្ងាប់រោគ ដែលកើតអំពីជាតិឈើ ឬអំពីធាតុផ្សេងៗ ជារបស់កើតមាននៅជាធម្មតា មិនចេះវិនាសទេ គ្រូពេទ្យអ្នកចេះចាំក្បួនតម្រាអាចផ្សំធាតុតាមរូបមន្តឲ្យទៅជាឱសថបានដោយងាយ ។ ពាក្យដែលយើងនិយាយថា ភ្លើងរលត់នេះជាសេចក្តីសន្មត គឺភ្លើងគ្រាន់តែរលត់អំពីចង្កៀងប៉ុណ្ណោះ នឹងថាភ្លើងរលត់បាត់ទៅចាកលោកមែនទែនក៏ទេ សេចក្តីនេះយ៉ាងណាមិញ ប្រវត្តិ

ទីងកិត្តិគុណរបស់ធម៌តែងមាននៅក្នុងលោកដោយពិតប្រាកដ មិនចេះវិនាសសាបសូន្យ មិនចេះស្លាប់ផុតពូជក៏យ៉ាងនោះដែរ ។

ពាក្យដែលគេនិយាយថា ព្រះធម៌សាបសូន្យ ឬសាសនាវៀវពេយនោះ គ្រាន់តែសំដៅយកព្រះធម៌ដែលសាបសូន្យ ចាកខន្ធសន្តានរបស់បុគ្គលអ្នកសិក្សាអ្នកប្រព្រឹត្តប៉ុណ្ណោះ ពុំមែនសាបសូន្យឬវៀវពេយចាកលោកឡើយ ។

មគ្គផលនិព្វាន ឈ្មោះថាកិត្តិគុណរបស់ធម៌ តែងពួនខ្ចរខ្ចាយនៅក្នុងលោកដោយហូរហែរជាដរាបមកមិនដាច់ ព្រោះហេតុនោះបុគ្គលអ្នកស៊ើបដំណើររកធម៌ក្នុងលោកនេះតែងមានគ្រប់ ៗ កាល តាមសេចក្តីប្រតិបត្តិក្នុងសាសនារបស់គេ ប៉ុន្តែច្រើនតែប្រទះទៅលើផ្លូវវងដោយអំណាចអវិជ្ជានាំសត្វឲ្យវង្វេង ឬដោយគំនិតយល់ខុសតាមលទ្ធិរបស់គ្រូដោយខ្លួន ៗ ។ ក្នុងកាលជាចន្លោះព្រះពុទ្ធត្រាស់ឡើង គង់ប្រាកដថាមានបុគ្គលខ្លះក្នុងលោកមានចិត្តនឿយណាយចាកកាមគុណ នឹកក្នុងចង់ស្វះស្វែងរកប្រវត្តិពង្សាវតារ ដែលជាគ្រឿងនៃមោក្ខធម៌ គឺព្រះនិព្វានហើយលះភេទគ្រហស្ថ ចេញចាកកាមារម្មណ៍ កាន់ភេទជាតាបសឥសីប្រព្រឹត្តតបវត្ត ដើម្បីស្រូតទៅរកព្រះនិព្វានជាធម្មតា ។ តាបសខ្លះប្រទះបានតែត្រឹមឈានសមាបត្តិ ឬអភិញ្ញាជាលោកិយប៉ុណ្ណោះ តាបសខ្លះឃ្លាតរហូតដោយខ្វះគ្រឿងផ្សំ ឬមានគ្រឿងផ្សំជាគុវិជ្ជាប្រាជ្ញាស្មារតី

មិនទាន់គ្រប់គ្រាន់ ព្រះសម្ពុទ្ធរបស់យើង កាលនៅជាពោធិសត្វក៏នៅក្នុងពួកតាបសដូច្នោះដែរ ព្រះអង្គតែងជាប់ព្រះហឫទ័យក្នុងការស្វែងរកព្រះធម៌ ទោះបីព្រះអង្គបានជាក្សត្រិយ៍សោយរាជ្យ ដែលគួរស្រវឹងក្នុងសម្បត្តិ និងយសបរិវារ ទ្រង់ក៏មិនភ្លេចអំពីដំណើរបុណ្យបាប តែងពេញព្រះហឫទ័យក្នុងភេទតាបសជារឿយ ៗ ចំប្រព្រឹត្តយ៉ាងខ្ជាប់ខ្ជួនតាបសឯទៀត ៗ ជាដរាបអស់ច្រើនជាតិណាស់ ៗ ព្រះមហាបុរសមានព្យាយាមយ៉ាងក្លៀវក្លាអង់អាច អង់អាល មិនតក់ស្លុតមិនលែងពេលអំពីការស្វែងរកមោក្ខធម៌ ព្រោះអាស្រ័យការដឹងជាមុខជានឹងបានឃើញមោក្ខធម៌ដូចប្រាថ្នា ៗ ព្រះអង្គចំប្រើនសន្សំសេចក្តីល្អ លះសេចក្តីអាក្រក់ ចំណាំប្រវត្តិរបស់ព្រះអង្គនិងព្រះធម៌របស់ព្រះអង្គ ឆ្លាប់ប្រតិបត្តិរៀងរាបដរាបដល់បច្ឆិមជាតិ ទើបបានគ្រឿងផ្សំធាតុសព្វគ្រប់ ហៅថា បារមីធម៌ ១០ ប្រការនោះឯង ៗ

លុះព្រះបរមពោធិសត្វមានបារមីធម៌ ចូលមកគ្រប់គ្រាន់ក៏បានរំពឹងស្រាវជ្រាវរកពន្យល់តាមព្រះធម៌ជាអនុលោមប្បដិលោម ទាល់តែបានឃើញជាក់ច្បាស់ដោយសព្វញ្ញុតញ្ញាណហើយទ្រង់សំដែង បើកបង្ហើបបង្ហាញធម៌នោះ ៗ ដល់ពួកសត្វនិករឲ្យភ្លឺច្បាស់ហាក់ដូចជាព្រះចន្ទរះឡើងដូចថ្ងៃ១៥ កើត ៗ ព្រះធម៌ដែលបាប់កំណើតនៅក្នុងផ្ទៃលោកធាតុជាយូរលង់មកហើយនោះក៏ស្រាប់ផុះរបើកអណ្តែតឡើង ហាក់ដូចជាប្រ

សូតចាកលោកជាគុមកប្រតិស្ឋានថ្មី ៗ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ នេះឯងហៅថាព្រះអង្គត្រាស់ដឹង ៗ មូលហេតុដែលនាំឲ្យពួកតាបសឯទៀត ៗ ក្តី តាបសគឺព្រះពោធិសត្វក្តី ខំសង្វាតបំពេញបារមីធម៌ទាំងនោះ ក៏ព្រោះអាស្រ័យការដឹងក្ដីទក្រអូប ការបាំប្រវត្តិនឹងកិត្តិគុណរបស់ធម៌ជាប់ហែរ ៗ មក ដូចជាដំណឹងថាមាសពេជ្រជាបច្ច័យ នាំឲ្យគេស្វែងរកមាសពេជ្រ គឺអាស្រ័យការដឹងជាដើមហេតុ ទើបមានការស្វែងរកជាខាងក្រោយគេ ៗ មក រហូតទាល់តែបានសម្រេចផលដូចប្រាថ្នា ៗ ដំណឹងថាមគ្គផល ជានិព្វាន រមែងមានក្ដីទក្រអូបនៅក្នុងលោក សម្បូរមគ្គផលជាធម៌នាំសត្វឲ្យឆ្លងឡើងចាកលោកព្រះនិព្វានជាគុណជាតិផុតស្រឡះចាកលោកហើយក៏ពិតមែន តែកិត្តិស័ព្ទរមែងសល់នៅក្នុងលោកមិនចេះសាបសូន្យឡើយ ៗ លុះព្រះអង្គបរិបូណ៌ដោយប្រាជ្ញាស្មារតីគ្រប់គ្រាន់ ដោយសេចក្ដីត្រិះរិះជ្រាបច្បាស់ចំពោះព្រះអង្គហើយ ទើបទ្រង់លើកស្រាវជ្រាវប្រមូលយកធម៌ដែលមាននៅក្នុងលោកស្រាប់នោះ មកលាតត្រដាងសំដែងសើរើចែករំលែកឲ្យមានមាតិកាដោតក្រងតម្រៀប ឲ្យមានតម្រង មានរបៀប ជាគោលចារិកពក់ជ្រៅសង្ខេបពិស្ដារច្បាស់លាស់ជាក់ស្ដែងឡើងដើម្បីឲ្យពួកបរិស័ទនិកាយរបស់ព្រះអង្គ ងាយស្ដាប់ងាយពិចារណារកផ្លូវប្រតិបត្តិ ៗ ពួកមនុស្សអ្នកមានសេចក្ដីជ្រះថ្លាក្នុងធម៌ គោរពចំពោះព្រះអង្គនាំគ្នាហៅថា ព្រះអង្គ

បានត្រាស់ដកបមក ៗ ធម៌ដែលព្រះអង្គបានត្រាស់ដឹងទាំងនោះ ក៏គឺធម៌ដែលធ្លាប់មាននៅស្រាប់ក្នុងលោកនោះឯង ៗ

សរុបសេចក្តីទាំងអស់ ដែលបានអធិប្បាយមកនេះ ឃើញថាព្រះធម៌ចាក់ឫសនៅក្នុងលោកមិនចេះសាបសូន្យ មិនចេះចាស់មិនចេះថ្មីទេ មនុស្សពួកខ្លះ ដែលប្រកាន់ដោយសេចក្តីភ័ន្តច្រឡំថា ធម៌មានចាស់ថ្មីនោះ គួរដូរលេខគំនិតពិចារណាទៀត បើឃើញថា ការប្រកាន់នោះនៅក្នុងលេខភ័ន្តច្រឡំ គួរលះលុបចោលចេញឲ្យជ្រះស្រឡះ ៗ

+

\+ +

# ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ុំ រៀបរៀង

តមក

## ៥ – ពហុលកម្ម

កុសលាកុសលេសុ បន យំ ពហុលំ តំ ពហុលកម្មំ ណាម តំ ទីឃរត្តំ លទ្ធាសេវនំ វេទិតព្វំ យំ វា ពលវំ កុសលេសុ សោមនស្ស-ការំ អកុសលេសុ សន្តាបការំ ឯតំ ទ្វយំ ពហុលំ ណាម ហោតិ ៗ

លំដាប់នេះ សូមវិសជ្ជនាក្នុងកម្មបច្ច័យ អធិប្បាយនូវពហុលកម្មតទៅ សេចក្ដីថា ទុវិធំ ពហុលកម្មនោះមាន ២ ប្រការគឺ ពហុលកម្មជាកុ-សល ១ ពហុលកម្មជាអកុសល ១ ៗ បើកម្មខាងកុសលមានកម្លាំង ឈ្មោះថា ពហុកម្មជាកុសល ៗ

ម្យ៉ាងទៀត បើសំដែងតាមបទត្ថ គឺប្រែតាមអត្ថនៃបទនោះថា កម្មដែលបុគ្គលធ្វើឲ្យច្រើន ឬធ្វើរឿយៗ នោះឯងឈ្មោះថា ពហុលកម្ម ៗ ទីឃរត្តំ អ្នកប្រាជ្ញគប្បីដឹងថាពហុលកម្មនោះ ដោយអំណាចនៃអា-សេវនៈ គឺការសេពគប់រឿយ ៗ ឬធ្វើរឿយ ៗ នោះឯងឈ្មោះថា

ពហុលកម្ម ។

សោមនស្ស [illegible] ពហុលកម្មខាងកុសល ធ្វើមនុស្ស ឲ្យត្រេកអរ ។ ពហុលកម្មខាងអកុសល ធ្វើឲ្យក្តៅក្រហាយក្នុងសន្តាន- ប៉ុន្តែ មិនកំណត់ការឲ្យផលមិនបានទេ ។ បើអកុសលកម្មមានកម្លាំង ច្រើនជាងកុសលកម្ម អកុសលកម្មក៏ឲ្យផលដឹកនាំទៅ ។ បើកុសល កម្មមានកម្លាំងច្រើនជាងអកុសលកម្ម កុសលកម្មក៏ឲ្យផលដឹកនាំទៅ ។ កម្មទាំងពីរនេះ បើខាងណាមានកម្លាំងច្រើនជាង ខាងនោះឲ្យផលដឹក នាំទៅ ប្រៀបដូចអ្នកចម្បាប់ពីរនាក់ចូលលេងចម្បាប់ជាមួយគ្នា សោ ពលវា ធម្មតាអ្នកចម្បាប់ទាំងពីរនាក់នោះ បើអ្នកចម្បាប់ណាមាន កម្លាំងខ្លាំងជាង អ្នកចម្បាប់នោះក៏ចាប់ផ្តោកដួលអ្នកចម្បាប់ម្ខាងដែល ខ្សោយជាងខ្លួនឲ្យដួលចុះ ក្នុងទីស្នាមយុទ្ធបាន សេចក្តីនេះមានឧបមា ដូចម្តេច ។ យំ ពហុលំ កម្មណាជាកម្មច្រើន មានកម្លាំងច្រើន ជាង ដោយអំណាចនៃអាសេវនៈគឺការសេពគប់ធ្វើញឹកញយ កម្មនោះ ក៏គ្របសង្កត់នូវកម្មមានកម្លាំងតិច ហាមឃាត់ឬរាំងកកម្មដទៃទៀតមិនឲ្យ ផលបាន មានឧបមេយ្យដូចអ្នកចម្បាប់ ដែលមានកម្លាំងខ្លាំង ចាប់ ផ្តោកអ្នកខ្សោយឲ្យដួលចុះដូច្នោះ ។

## រឿងនាយចុន្ទសូករិកបុរស

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ពហុលកម្មខាងអកុសលឲ្យផលដូចជា-

នាយចុន្ទសូករិកបុរស មានដំណាលថា ចុន្ទសូករិកោ នាយចុន្ទសូករិកបុរសនោះ តែងសម្លាប់ជ្រូកលក់ចិញ្ចឹមជីវិតខ្លួននឹងបុត្រភរិយា ទៅកាន់ជនបទដូរកូនជ្រូក ដោយអាហារ យកមកចិញ្ចឹមទុកខាងក្រោយផ្ទះរបស់ខ្លួន បំប៉នដោយអាហារឲ្យកូនជ្រូកធាត់ធំឡើង ហើយទើបសម្លាប់យកទៅលក់ ។ ឯផ្ទះរបស់នាយចុន្ទសូករិកនោះ នៅក្បែរព្រះវិហារ ប៉ុន្តែនាយចុន្ទសូករិកមិនដែលទៅថ្វាយបង្គំ សម្តេចព្រះបរមគ្រូដល់ម្តងសោះឡើយ ។

ថ្ងៃមួយ នាយចុន្ទសូករិកនោះមានជម្ងឺបច្ចុប្បន្ន (គ្រុនក្តៅខ្លាំង) អន្ទះអន្ទែងបម្រះនទៀលទៅមកក្នុងផ្ទះ ស្រែកថ្ងូរឮសូរដូចជាសម្លេងជ្រូក ។ ញាតិ ពិភាក្សាគ្នា ជនទាំងឡាយខ្លាចក្រែងនាយចុន្ទសូករិករមៀលធ្លាក់ពីលើផ្ទះមកដី ទើបនាំគ្នាបិទទ្វារផ្ទះចងឲ្យជាប់ ។

តស៊ូ ៧ ថ្ងៃ ក្នុងខណៈនោះ ភិក្ខុទាំងឡាយបានឮសម្លេងនៃនាយចុន្ទសូករិកស្រែកដូចជាសូរសម្លេងជ្រូកដូច្នោះ ក៏សំគាល់ថាគេសម្លាប់ជ្រូកធ្វើការជាមង្គល ។ ចំណែកនាយចុន្ទសូករិកនោះបានសោយផលអកុសលកម្មជាពហុលកម្ម ដូចកាលខ្លួនសម្លាប់ជ្រូកនោះដែរ ព្រោះហេតុតែផលនៃបាណាតិបាតនោះឲ្យផលឃើញជាក់ស្តែងនឹងភ្នែក ។ លុះនាយចុន្ទសូករិកដាច់ខ្យល់ស្លាប់ហើយ ទៅកើតក្នុងអវចីមហានរក ព្រោះខ្លួនប្រព្រឹត្តទុច្ចរិតលាមកសម្លាប់ជ្រូកជានិច្ច ។

បេតិ បដិក្កន្តា ចំណែកភិក្ខុទាំងនោះ ត្រឡប់ពីទីគោចរបិណ្ឌបាតមកវិញ ចូលគាល់សម្តេចព្រះសព្វញ្ញូ ក្រាបទូលថា ភន្តេ ភគវា បពិត្រព្រះទ្រង់ព្រះភាគ ថ្ងៃនេះក្នុងផ្ទះនាយចុន្ទសូករិកបុរស គេសម្លាប់ជ្រូកធ្វើការមង្គល សម្លេងជ្រូកស្រែកលាន់ឮចេញពីផ្ទះមកដល់ថ្នល់ជាទីគោចរភិក្ខាចារ ។

តំ សុត្វា សម្តេចព្រះបរមសាស្តាទ្រង់ព្រះសណ្តាប់ពាក្យភិក្ខុក្រាបទូលនោះហើយ ទើបទ្រង់ត្រាស់ថា សម្លេងដែលអ្នកពល់គ្នាបានឮនោះ មិនមែនសម្លេងជ្រូកស្រែកទេ គឺជាសម្លេងនៃចុន្ទសូករិកបុរសស្រែកដោយហេតុសោយផលនៃអកុសលកម្មដែលខ្លួនបានធ្វើ លុះក្ស័យជីវិតហើយ អកុសលកម្មនោះឲ្យផលនាំចុន្ទសូករិកបុរសទៅកើតក្នុងអវចីមហានរក ។

ភិក្ខុទាំងឡាយក្រាបទូលថា បុគ្គលធ្វើនូវអកុសលកម្មដ៏លាមកក្នុងជាតិនេះហើយ ក៏នឹងបានសោយផលនៃអកុសលកម្មនោះក្នុងជាតិខាងមុខ ។

លំដាប់នោះ សម្តេចព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា អាម ភិក្ខវេ អើភិក្ខុទាំងឡាយ ចាបការី បុគ្គលធ្វើនូវអំពើបាបអកុសលជាប្រក្រតី កាលរស់នៅក្នុងលោកនេះក៏រមែងក្តៅក្រហាយ ស្លាប់ទៅកើតក្នុងលោកខាងមុខ ក៏រមែងក្តៅក្រហាយទៀត គេតែង-

ក្តៅក្រហាយក្នុងលោកទាំងពីរ ដោយអំណាចសេចក្តីក្តៅក្រហាយ ព្រោះហេតុនៃកម្មនឹងផលរបស់កម្ម ដូចនាយចុន្ទសូករិកនេះឯង ។

អ្នកប្រាជ្ញគប្បីដឹងថា នាយចុន្ទសូករិកបុរស កាលរស់នៅក្នុងមនុស្សលោកនេះ ក៏បានសោយផលនៃអកុសលកម្មដ៏សហ័ស លុះអស់ជីវិតពីមនុស្សលោកនេះទៅហើយ ទៅកើតក្នុងអវិចីមហានរកនោះ ដោយអំណាចនៃអកុសលកម្មដែលកប់បញ្ចូលក្នុងពហុលកម្ម ។ ឯពហុលកម្មខាងអកុសលកម្មនេះ រមែងសម្រេចផលឲ្យបានសេចក្តីទុក្ខ ។

## រឿងនាងកុមារីទុគ៌ត

ចំណែកពហុលកម្មខាងកុសល រមែងឲ្យបានសោយនូវសេចក្តីសុខក្នុងជាតិនេះនិងជាតិមុខ ដូចនាងខ្ញុំបាសិកាម្នាក់ក្នុងវង្សនៃអនាថបិណ្ឌិកមហាសេដ្ឋី ។ កាលកន្លងយូរមក វង្សត្រកូលនៃអនាថបិណ្ឌិកមហាសេដ្ឋីដាច់អស់ហើយ នៅសល់តែនាងខ្ញុំបាសិកាម្នាក់នោះ ជានាងកុមារីមានចិត្តត្រេកអរក្នុងការកុសល ជាស្រីកំសត់ទុគ៌តអនាថា ប៉ុន្តែនាងមានសេចក្តីខ្សោហ៍ ប្រគេនសលាកភត្តខានដល់ព្រះសង្ឃមួយថ្ងៃមួយអង្គ ជាកល់ថ្ងៃ ។ នាងទៅសូមសង្ឃអំពីសំណាក់នៃសង្ឃជាមេបញ្ជី ។ នាងកុមារីនោះប្រគេនសលាកភត្តជាប់ជានិច្ចកល់ថ្ងៃ ។ ចំណេររបេរកាលមក នាងកុមារីគ្មានវត្ថុអ្វីនឹងប្រគេនសលាកភត្តនឹងធ្វើបិណ្ឌបាតទាន ទើបទៅកាន់ពេរវនគរស៊ីឈ្នួលគេធ្វើថាលព្រោះសំណាច

លុះបានទ្រព្យមកហើយក៏ធ្វើសលាកភត្តទានមួយថ្ងៃមួយអង្គ មិនលះបង់ការកុសលនេះឡើយ ។

ដំណើរនាងកុមារីធ្វើទានជាប់ជានិច្ចដូច្នេះ ក៏ល្បីខ្ចរខ្ចាយលេចឮទៅដល់ព្រះមហាក្សត្រ ព្រះអង្គទ្រង់ព្រះសោមនស្សណាស់ ត្រាស់ប្រើឲ្យរាជបុរសទាំងឡាយនាំយករថទៅទទួលនាងមកកាន់ព្រះរាជវាំង ដល់ហើយទ្រង់ត្រាស់សួររឿងធ្វើទាននោះចំពោះនាងកុមារី តើមែនដូចពាក្យគេថាឬមិនមែន ។ នាងកុមារីក្រាបទូលរៀបរាប់សេចក្ដីតាំងពីដើមដំ-បូងមកដូចជាពាក្យអ្នកផងថាមែន ។ ព្រះមហាក្សត្របានទ្រង់ព្រះសណ្ដាប់ហើយ មានព្រះរាជហឫទ័យជ្រះថ្លាក្រៃលែង ក៏ទ្រង់តាំងនាងកុមារីទុកក្នុងទីជាព្រះអគ្គមហេសី ព្រះរាជទានទ្រព្យក្នុងព្រះឃ្លាំង មានព្រះរាជឱង្ការត្រាស់ថា ម្នាលនាងទេវី នាងចូរធ្វើកងការកុសលតាមចិត្តប្រាថ្នាចុះ ទ្រព្យក្នុងថ្លៃព្រះឃ្លាំងទាំងអស់នោះ យើងប្រគល់ឲ្យនាងហើយ ។

តតោ បដ្ឋាយ តាំងដើមពីនោះមក នាងកុមារីកំសត់ទុគ៌តបានឡើងឋានន្តរសក្ដិជាព្រះរាជទេវី ជាមហាឧបាសិកា បានប្រគេនសលាកភត្តទានដល់ភិក្ខុទាំងឡាយកាន់តែច្រើន ៗ ឡើងជាលំដាប់ ទីងប្រគេនឧទ្ទិសភត្តដល់ភិក្ខុដែលសូត្របាដិមោក្ខ ប្រគេននិច្ចភត្តដល់ភិក្ខុដែលរៀននឹងបង្រៀនព្រះបរិយត្តិធម៌ ។ ព្រះរាជទេវីនេះ លុះរលត់សង្ខារហើយក៏បានទៅកើតក្នុងស្ថានឆកាមាវចរសួគ៌ ។

ការកុសលដែលព្រះពុទ្ធទ្រង់ធ្វើនោះឈ្មោះថាពហុលកម្ម ព្រោះហេតុធ្វើឲ្យច្រើន ៗ ឡើងជាលំដាប់ ៗ ការកុសលណាដែលបុគ្គលធ្វើឲ្យច្រើន ៗ ឡើងជាលំដាប់ដូច្នោះ ការកុសលនោះរាប់បញ្ចូលក្នុងពហុលកម្មទាំងអស់ ដូចសាធុជនបំពេញការកុសលរាល់ថ្ងៃខែ គឺសម្រាប់ស្តាប់ធម្មទេសនាមិនដាច់ ក៏ចាត់ជាពហុលកម្មខាងកុសលកម្ម ៗ ប៉ុន្តែ ពហុលកម្មជាកុសលនោះ បុគ្គលមិនងាយនឹងធ្វើបានគ្រប់គ្នាទេ ព្រោះអ្នកខ្លះមានសន្តានចិត្តជាពាលឥតសទ្ធាជ្រះថ្លា គឺមិនជឿកម្មមិនជឿផលរបស់កម្ម បើឃើញអ្នកសប្បុរសធ្វើកុសលអ្វី ៗ ក៏ចូលធ្វើជាមួយគេដែរ ធ្វើគ្រាន់តែឲ្យគេសរសើរខ្លួនប៉ុណ្ណោះកុំឲ្យគេតិះដៀលនិន្ទាខ្លួន ៗ អ្នកខ្លះមានសទ្ធាជឿកម្មផលមុតមាំ ។ សម្រាប់ធ្វើបុណ្យកុសលរាល់ថ្ងៃខែច្រើន ៗ ពេកទៅ អ្នកសទ្ធាដូចគ្នាតែងនិយាយសរសើរថាគេខំធ្វើបុណ្យកុសលជាប់ជានិច្ច គេនឹងបានសោយផលបុណ្យច្រើនណាស់ ៗ ចំណែកអ្នកឥតសទ្ធាវិញ បែរជានិយាយតិះដៀលថាគេខំធ្វើបុណ្យច្រើនពេកពាល់តែហួសកម្លាំងខ្លួន ធ្វើបុណ្យមិនដឹងប្រមាណខ្លួនសោះ ៗ ពាក្យសរសើរនឹងពាក្យនិន្ទាទាំងពីរចំពូកនេះតែងកើតមានឡើង ដល់សាធុជនជាសប្បុរសអ្នកខំបំពេញបុណ្យកុសលជាពហុលកម្មជាប់ជានិច្ចឥតខានឡើយ ៗ ហេតុនេះ សាធុជនអ្នកស្រឡាញ់ពហុលកម្មជាកុសលត្រូវដំកល់ចិត្តសទ្ធាឲ្យនឹងធឹង កុំឲ្យឡើងជារ

តាមពាក្យសរសើរ កុំឲ្យទោមនស្សអាក់អន់ចិត្តតាមពាក្យនិន្ទា គួរគប្បី-ខំអត់សង្កត់ដោយអធិវាសនខន្តីពិចារណាឲ្យឃើញច្បាស់ថា «មនុស្សកើតមកក្នុងលោកនេះមិនផុតពីពាក្យនិន្ទាគ្រប់គ្នា» ។ សមតាមព្រះពុទ្ធដម្រាស់ដែលអង្គសម្តេចព្រះពិជិតមារ ត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ នែអានន្ទ ឯតំ និន្ទនិយា បសំសនិយា ពាក្យនិន្ទានេះក្តី ពាក្យសរសើរនេះក្តី រមែងមាននៅក្នុងលោកនេះគ្រប់រូបមនុស្ស ។ អ្នកខ្លះនិន្ទា ឬសរសើរព្រះច័ន្ទ ព្រះអាទិត្យ ផែនដី មហាសមុទ្រ ខ្យល់ កំដៅថ្ងៃនឹងភ្លៀង ។ សូម្បីអង្គសម្តេចព្រះបរមទសពលដែលជាអគ្គបុគ្គលក៏នៅតែមិនផុត អំពីពាក្យនិន្ទានឹងពាក្យសរសើរដែរ ។ អដ្តមសោ ដោយហោចទៅ គ្រាន់តែរូបព្រះបដិមាករ ឬរូបព្រះ-ចេតិយ៍ ក៏គង់មានមនុស្សនិន្ទា ឬសរសើរមិនខាន ។ បើលោកនៅប្រព្រឹត្តទៅដរាបណា និន្ទានឹងសរសើរក៏នៅតែមានដរាបនោះ ។ ឯការដែលនឹងរួចផុតពីនិន្ទា ឬសរសើរនោះ មានតែសេចក្តីអត់សង្កត់ទប់ចិត្តដោយអធិវាសនខន្តីម្យ៉ាងប៉ុណ្ណោះ ។

ការដែលធ្វើចិត្តឲ្យនៅជាកណ្តាល ។ មិនសោមនស្សនឹងពាក្យសរសើរ មិនទោមនស្សនឹងពាក្យនិន្ទានោះជាការក្រណាស់ វិស័យសា-មញ្ញសត្វបុថុជ្ជនមិនងាយនឹងទប់ចិត្តឃាត់ចិត្តឲ្យនៅជាកណ្តាលៗបានទេ ។ ប៉ុន្តែ មានបុថុជ្ជនខ្លះខំធ្វើឲ្យចិត្តជាកណ្តាល ។ បាន មួយខណៈដែរ

ដោយការតាំងស្មារតីនឹករឭកពិចារណា កិច្ចការដែលជាកុសលជាប្រយោជន៍ដល់ខ្លួន ទំរក្សាកុសលនោះមិនឲ្យវិនាសសាបសូន្យទៅវិញ សមតាមព្រះពុទ្ធភាសិត ដែលទ្រង់ត្រាស់ទីងព្រះអត្តទត្ថេរថា៖

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថំ បសុតោ សិយា ។

សេចក្ដីថា បុគ្គលមិនញុំាងប្រយោជន៍របស់ខ្លួនឲ្យវិនាសទៅ ព្រោះតែប្រយោជន៍របស់អ្នកដទៃសូម្បីច្រើនទេ ទីងប្រយោជន៍របស់ខ្លួនហើយ គួរតែជាអ្នកខ្វល់ខ្វាយនូវប្រយោជន៍របស់ខ្លួន ។

បើបុគ្គលនឹករឭកដល់ព្រះពុទ្ធអង្គ ដែលទ្រង់ប្រោសប្រទានសទ្ធម្មទេសនា ដូចសំដែងមកខាងដើមនេះហើយ ក៏អាចអត់សង្កត់នូវចិត្តសោមនស្សឬទោមនស្សដែលកើតពីពាក្យ សរសើរឬតីពាក្យនិន្ទានោះបាន មុខជានឹងស្វែងរកធ្វើអំពើកុសលដាក់ខ្លួនជាប់ជាបទៅ មិនអាក់ខាន ។ កុសលដែលបុគ្គលបានធ្វើញឹកញយច្រើន ៗ ឡើងយ៉ាងនេះ តាត់ជាពហុលកម្មខាងកុសល ជាបច្ច័យឲ្យកើតក្នុងសុគតិភពបាន ។

## ពហុលកម្ម សង្ខេបប៉ុណ្ណោះ ។

# មហោសថជាតក

(តចប់)

មហារាជ បពិត្រមហារាជអើយ ស្រីប្រពន្ធអ្នកសោតមានសំដីនោះផ្អែមល្ហែមពីរោះ មុខគួរឲ្យអាសូរករុណា ស្រឡាញ់ពេញចិត្ត ជាអ្នកទៀងត្រង់ផ្គង់មារយាទគំនិតជាប្រក្រតី មានពពួកស្រីប្រសើរទាំងឡាយ សឹងមកសម្រាប់ជាបរិវារ ហើយជាអ្នកមានសីលអំពីក្មេង គាត់នៅនឹងខ្លួនស្រមោលនឹងរូបពុំដែលចេះខឹង ប្រាកដមានប្រាជ្ញាយល់អាថិជាប្រក្រតី ប្រកបនូវគុណនោះច្រើន ដោយនូវទោសនោះម្តេចអ្នកឲ្យទុក្ខគេស្រវាធិហ៊ះ ៗ

ព្រះបាទចុឡនីអ្នកសំដែងទោសនៃភរិយាថាជាឥតគុណនោះស្តេចបន្ទូលជាបទគាថាដូច្នេះ ៖

ខិឌ្ឌារតិសមាបន្នំ អនត្ថវសមាគតំ
សា មំ សកានិ បុត្តានិ អយាចំ យាចតេ ធនំ
សោហំ ទទាមិ សារត្តោ ពហុំ ឧច្ចាវចំ ធនំ
សុទុច្ចជំ ចជិត្វា បច្ឆា សោចាមិ ទុម្មនោ
ឧត្តរី តេន ទោសេន ឧជ្ឈាមិ ឧក្ការត្តិ ហោតិ ៗ

ហៃនាងភេរីបរិព្វាជិកាអើយ នាងខ្លួនទេវី ខេះ ជាអ្នកល្បងក្រសាលលុះអំណាចកិលេសផង ហើយធ្វើប្រយោជន៍តែទ្រព្យមិនគប្បី

សូមយកទៅប្រដាប់តាត្នា នាកូនទីងខ្លួននោះ ឲ្យមកកាន់អញ ៗ ក្រមិនបានឲ្យ ៗ ហើយអញស្រណោះផងវិញ អញប៉ងឲ្យទៅដោយចិត្តស្រឡាញ់ ដូច្នោះហើយមានពាក្យសំដីនោះថា តូច ៗ ធំ ៗ នោះច្រើន ឯក្រោយអញមានចិត្តនោះពុំស្រណុក វាកើតជាសោកស្ដាយទ្រព្យនោះវិញ ហេតុនោះ ទើបអញឲ្យទេករក្ខស្សអារក្សទឹកវាធី ៗ

លំដាប់នោះ នាងកេរីបរិញ្ញាជិកាទូលវិញថា មហារាជ បពិត្រមហារាជអើយ ឯប្រពន្ធអ្នកដោយទូវទោសដូច្នោះហើយ រីទៅតិក្ខុណកុមារមន្ត្រីកុមារប្អូនអ្នកនោះ តើគាត់មានគុណនោះច្រើនប្រការក្រៃពេក ដោយទូវទោសនោះ ម្ដេចអ្នកឲ្យអារក្សទឹកវាធីហ្នឹង ? ហើយនាងកេរីបរិញ្ញាជិកាទូលវិញថា មហារាជ បពិត្រមហារាជអើយ ! ស្រុកឯណាមិនចំណុះយើងក្ដី ទៅតិក្ខុណមន្ត្រីកុមារនោះ គាត់ប្រមូលនាំមកបំពេញរាជសម្បត្តិនៃអ្នក ហើយគាត់ប្រដាប់តម្កល់ទុកទ្រព្យនោះច្រើនប្រពៃ ពួជខ្នាន់ធ្មុផងសោត សឹងជំហានក្លាប្រសើរ រីប្អូនអ្នកនោះ តើដោយទូវទោសនោះដូចម្ដេច ក៏បានជាអ្នកឲ្យអារក្សទឹកវាធី នាដោយទូវយើងបានក្ដុរៀងមកថា ទៅតិក្ខុណមន្ត្រីកុមារ កាលទើបកើតនៅនាព្រះរាជមន្ទីរនោះ កាលនោះទៅតិក្ខុណមន្ត្រីចំរើនវ័យធំឡើង ឯធក្តិព្រាហ្មណ៍នោះសោត គាត់ឲ្យជាអ្នកកំណាន់តែងកាន់ងារ ហើយធក្តិព្រាហ្មណ៍ថាដូច្នេះ ហៃបាតិក្ខុណកុមារអើយ! ចូរ

បាកាន់ដាវនេះ ធ្វើការបរើអញហោង, ឯចៅតិក្ខណមន្ត្រីកុមារ
សោត តែងសំគាល់ថា ឯព្រាហ្មណ៍នេះ គាត់ជាឪពុក ហើយ
អញនឹងបំរើគាត់អំពីថ្ងៃនេះទៅហោង ។

លំដាប់នោះ, មានអាមាត្យមួយមកស្រដីប្រាប់តិក្ខណមន្ត្រីកុមារ
ថា ហៃចៅតិក្ខណមន្ត្រីកុមារអើយ ! អ្នកឯងសោត មិនមែនជា
ជាកូនចៅព្រាហ្មណ៍នេះឡើយ, អ្នកអើយ ! កាលប្រសូតអ្នកចេញ
មកអំពីផ្ទៃមាយអ្នកហើយ សលាកទេវឯងគាត់បំពុលសម្លាប់នៃស្តេចម-
ហាចុទ្យទីកជ ជាព្រះជនកអ្នកហើយនាំងបង្វែរកជសម្បត្តិស្តេចទ្រង់ឲ្យ
ព្រាហ្មណ៍សោយរាជសម្បត្តិវិញហោង, រស្តេចមហាចុទ្យទីកជ មែន
ពិតប្រាកដជាព្រះបិតាអ្នកហោង ។ រចៅតិក្ខណមន្ត្រីកុមារសោត
កាលណាបើបានស្តាប់ពាក្យអាមាត្យនោះ ដឹងជាក់ច្បាស់ប្រាកដដូច្នោះ
ហើយ ខឹងនឹងព្រាហ្មណ៍នោះមហិមាក្រៃពេក ហើយគិតពិចារណាថា
បើដូច្នោះអញអត់អង្កាល់ឡើយ អញនឹងសម្លាប់ព្រាហ្មណ៍នេះពេលបង់
មៀត ដោយនូវឧបាយកលអ៊ីមួយ ដោយនូវចំណេះប្រាជ្ញាអញ
ហោង ។ កាលនោះ ចៅតិក្ខណមន្ត្រីកុមារ កាលនឹងចូលទៅ
គាន់ត្រកូលស្តេចហើយ ឲ្យដាវមួយទៅអាមាត្យតែងបំរើ ហើយទៅ
ស្រដីនឹងអាមាត្យដទៃថា ម្នាលព្រះស្តែងអើយ ! ចូរព្រះស្តែងទៅនា
ទ្វារស្តេច ហើយដណ្តើមដាវនេះមួយថា ដាវអញ ហើយព្រះស្តែងធ្វើ

ជាជំលោះប្រកែកផងគ្នា តៀតតែជាវនេះអ្នកផ្ដាំផ្ញើទោះហើយ អ្នកចូល ទៅ ឯបុរសទាំង ២ នាក់ធ្វើជាឈ្លោះគ្នា ឯចៅតិក្ខណមន្ត្រីកុមារ កាលណាឃើញអ្នកទាំង ២ នោះ ឈ្លោះគ្នាផ្ទួនៗហើយថា : អស់ អ្នកទាំង២ឈ្លោះគ្នាប្រកែកអ្វី ? បុរសទាំង២ឮហើយឆ្លើយថា អ្នកអើយ! យើងជណ្ដើមជាវគ្នា ! ទើបអាមាត្យក្រឡាប់មកវិញប្រាប់ថា អម្ចាស់ គេឈ្លោះប្រយោជន៍ជណ្ដើមជាវផងគ្នាអម្ចាស់ ទើបចៅតិក្ខណមន្ត្រីនោះ ប្រើឱ្យអាមាត្យនោះទៅហៅ ឯធក្កព្រាហ្មណ៍នោះសោត ឮហើយ ជណ្ដឹងថា វៃហបាតិក្ខណមន្ត្រីកុមារអើយ ! ពាក្យនោះថាអ្វី ? ចៅ តិក្ខណមន្ត្រីទូលថា ទេវ បពិត្រអម្ចាស់អើយ ! ដោយទូលអញខ្ញុំឮ គេប្រាប់ថា ជាវដែលអម្ចាស់ឱ្យខ្ញុំកាន់នោះ មានបុរសមួយពីមកជណ្ដើម ថាជាជាវកំ ព្រាហ្មណ៍ថា ម្នាលតិក្ខណមន្ត្រីកុមារអើយ! បើដូច្នោះ ចូរបាឱ្យទៅយកជាវនោះមកអញនឹងមើលផង ថាបើជាវនោះហើយអញ ស្គាល់ឯងអេះ ចៅតិក្ខណកុមារ ក៏ឱ្យទៅយកជាវនោះមកដល់ហើយ ហូតចេញអំពីស្រោមស្រេចហើយ ទើបចៅតិក្ខណមន្ត្រីកុមារទូលថា ទេវ បពិត្រអម្ចាស់អើយ ! ចូរអម្ចាស់ទតមើលមើលហោង ហើយ ធ្វើហាក់ដូចនឹងបង្ហាញឱ្យជិតទៅទៀបហៀបដល់ ហើយលើកឡើងសំ ពងវង់ទៅតែម្ដង ដាច់កព្រាហ្មណ៍ធ្លាក់ក្បាលតូងចុះខាងជើងអាត្មានោះ ហោង ។

តតោ រាជគហតោ នីហរិត្វា រាជគេហំ បដិជគ្គិត្វា ឆត្តំ អលង្ករិត្វា តស្ស អភិសេកោ ឧបនីតោ មាតា ចូឡនីកុមារស្ស មទ្ទរដ្ឋេ វស-នភាវំ អាចិក្ខិ ។ លំដាប់នោះ រីចៅតិក្ខណមន្ត្រីកុមារ អ្នកឲ្យដំរះព្រះរាជមន្ទីរស្តេចស្រេចហើយ អ្នកឲ្យប្រដាប់ព្រះឆត្រប្រៃត ហើយនៃ ទើងឲ្យទៅយកអ្នកមកអភិសេកឲ្យសោយរាជសម្បត្តិជាស្តេច រីព្រះមាតាអ្នកនោះសោត ប្រាប់ចៅចុឡនីកុមារនោះទូវសភាព នៃការឲ្យទៅនៅស្រុកមទ្ទរដ្ឋនាយ ៗ ឯចៅតិក្ខណមន្ត្រីកុមារ បានឮពត៌-មាននោះហើយ អ្នកទៅកាន់ស្រុកមទ្ទរដ្ឋ ទើងអស់សេនាយោធាផងទាំងឡាយ តាមកេមជាបរិវារ ហើយទៅយកអ្នកជាបងនាំមក បង្វែរស្វេតច្ឆត្រកជសម្បត្តិឲ្យបងសោយរាជវិញ ៗ ចាប់ដើមអំពីនោះទៅ រីចៅតិក្ខណមន្ត្រីនោះសោត សន្មតឲ្យហៅជាចៅតិក្ខណមន្ត្រីវិញហោងៗ ឯនាង ភេរីបរិព្វាជិកាទូលដណ្តឹងថា មហារាជអើយ ! រីចៅតិក្ខ-ណមន្ត្រីកុមារ ប្អូនអ្នកមានគុណសភាពបណ្ឌិតអម្បាលនេះ ដោយទូវទោសនោះម្តេច? អ្នកទើងឲ្យគារក្សាទឹកចាំងនោះហ៊ឹង ?

ព្រះបាទចុឡនីរាជ ស្តេចទើងសំដែងទោសចៅតិក្ខណមន្ត្រីកុមារនោះហើយ ស្តេចបន្ទូលសូត្រជាបទគាថាដូច្នេះ :

មយោចិតា ជានបទា អានីតា ច បដិគ្គហំ

អាភតំ បររេដ្ឋកិ អកិដ្ឋាយ ពហុធនំ ។
ធនុគ្គ-ហានំ បវរេ សូរេ តិក្ខណាមន្តិ ច
មយាយំ សុចិតោ ភជា ឥតិ បញ្ញាតិ ធារកោ ។
ឧបដ្ឋានំបិ មេ អយ្យេ ន សោ ឃតិយថាបុរេ
ភាតរំ កេន ទោសេន ឧដ្ឋាហំ ឧការត្ថិ ជោតិ ។

ហៃនាងកេរីបរិព្វាជិកាអើយ ! អញប្រមូលនាំមកនូវភជសម្បត្តិផង អំពីនគរដទៃមករណ្តាប់ដំកល់ទុកនូវទ្រព្យច្រើនឯណា ខ្មាន់ធ្នូផង សឹងជំក្លាហាន អញទុកជាទាហានប្រសើរ ហើយសោយភជសម្បត្តិឲ្យស្រណុកចិត្ត តិក្ខណកុមារនេះ បបួលគ្នានាំចេញទៅនៅស្រុកជនបទក្រៅវិញ ហើយគាត់មើលងាយអញនូវប្រការដូច្នោះឯង នាងអើយ សូម្បីអ្នកផងទាំងឡាយតែងបំរើអញក្តី ចៅតិក្ខណមន្ត្រីកុមារនេះ មិនឲ្យមកកាន់អញដូចអំពីមុននាយឡើយ នាងអើយ ! រំប្អូនអញនេះ ដោយនូវទោសដូច្នេះហោង ទើបអញឲ្យអារក្សទុកវាំងនេះ ។

នាងកេរីបរិព្វាជិកាទូលវិញថា មហារាជ បពិត្រមហារាជអើយ ! រំទោសប្អូនអ្នកទាំងអម្បាលនោះ យើងទុកស្មេះនៅនេះហោង មហារាជអើយ ! រំចៅធនុសេខកុមារ តើគាត់ជាសំឡាញ់នឹងអ្នក ប្រកបនូវគុណមានប្រការច្រើនក្រៃពេក ទោះអ្នកឯងក្តី ចៅធនុសេខកុមារក្តី ឯអ្នកទាំងពីរនេះ សឹងកើតឆ្នាំ ១ ខែ ១ ថ្ងៃមួយផងគ្នា អ្នក

ទាំងពីរនេះកើតនៅបញ្ចាលនគរហើយសឹងជាសំឡាញ់ផងគ្នា សឹងមានច្បាប់ មានមារយាទប្រពៃ អាល័យតែងដើរតាមរួមទុក្ខរួមសុខនឹងគ្នាពុំដែលខ្ជិលឡើយ ហើយអ្នកខ្វល់ខ្វាយពព្យាយាមបំរើគំនិតប្រព្រឹត្តនឹងអស់ក្រឹត្យផងគ្នា ទោះថ្ងៃទោះយប់ក្តី ហេតុជាសំឡាញ់នឹងគ្នា ទោសនោះម្តេចក៏អ្នកឲ្យទករក្ខស្សៈរាធីហ្នឹង ?

លំដាប់នោះ ព្រះបាទចុឡនីព្រហ្មទត្តរាជ ស្តេចសំដែងទោសនៃធនុសេខកុមារហើយបន្លូលសូត្រជាបទគាថាដូច្នេះ :

ចរិយា មំ អយំ អយ្យេ សញ្ញត្តោ មយា សមា
អដ្ឋាបិ តេន វណ្ណេន អតិវេលំ បជគ្ឃតិ ។
ឧត្តរិយាបិ មេ អយ្យេ មន្តយាមិ រហោគតោ
អនាមន្តា បវិសតិ បុព្វេ អប្បដិវេទិតោ ។
លទ្ធទ្វារេ កតោកាសោ អហិរិកំ អនាទរំ
សហាយំ តេន ទោសេន ឧដ្ឋាហុំ ឧគ្គវត្តិនោតិ ។

ប្រែថា ម្នាលនាងភេរីបរិព្វាជិកាអើយ ! ធនុសេខកុមារនេះវាតែងធ្វើអំពើជាល្បែង មិនដឹងអធ្យាស្រ័យនៃអញជាកូនស្តេចឡើយ ហើយជាអ្នកលលេញតិះដៀលទៅមកជាមួយនឹងអញ ជាអ្នកមើលងាយពុំកោតក្រែងអញ វានេះធ្វើខុសគន្លងពេលាពេក នាងអើយ ! អញនឹងស្រដីនាមិនគួរបើស្រដីនោះ លុះអញទៅនៅនាឋានស្ងាត់ នឹងចូល

ផ្គាល់ផ្គាប់ស្និទ្ធដឹងចិត្តមុននោះហើយ ក៏ធ្វើឧបការឲ្យបានជានាទូរបើបើក មិនគួរបើបើក ជាអ្នកឥតខ្លាសហើយឥតពិចារណាផង ក៏ជាសំឡាញ់នឹងអញនេះ យល់ស្និទ្ធជិតពេក ហេតុដោយទូវទោសដូច្នោះហោង អញឲ្យទករក្ខស្រុះក៏ធីហោង ។

លំដាប់នោះ នាងកេរីបរិព្វាជិកាទូលវិញថា បពិត្រមហារាជ-អើយ ! ទោសនៃចៅធនុសេខកុមារនេះ យើងស្ទះទុកនៅនេះសិនដូច្នោះ ព្រាហ្មណ៍បុរោហិត តើគាត់មានគុណប្រការច្រើននឹងអ្នកពេកក្តាត់ ហើយនាងទើបសំដែងគុណព្រាហ្មណ៍បុរោហិត ស្ងួតជាបទព្រះគាថា ដូច្នេះ :

កុសលោ សព្វនិមិត្តានំ រុតញ្ញូ អាគតាគមោ
ឧប្បាតេ សុបិនេ យុត្តោ និយ្យានេ ច បវេសនេ ។
បហោ អន្តលិក្ខស្មិំ នក្ខត្តបទកោវិទោ
ព្រាហ្មណំ កេន ទោសេន និជ្ឈាសិ នក្ខត្តកោវិទោ ។

មហារាជ បពិត្រមហារាជអើយ ! ព្រាហ្មណ៍បុរោហិតនេះជាអ្នកឈ្លាសដឹងនូវសារៈពីនិមិត្តផង មានហេតុកេតុទំនើបជាដើម គឺបន្ទូរគ្រាស ស្សូវគ្រាស អ្នកមានគំនិតវិសេសនេះ ឧបទេសឧបទ្រពទុក្ខភ័យចង្រៃផង ចូរកេន្ទង់ផ្ទះ ជាអ្នកចេះប្រកបកំចាត់បំបាត់ឧបទ្រពផង ហើយជាអ្នកដឹងប្តូរយាមនានឹងបញ្ចូលទ្រព្យធនទុកក្នុងឃ្លាំង ជា

អ្នកល្ហាសដីនហោរទាយ ដីនកិច្ចកលផ្លែក្រោម ហើយដឹងដល់អាកាសនាយនោះ មហារាជអើយ ! ព្រាហ្មណ៍បុរោហិតនោះ គាត់មានគុណច្រើនប្រការម៉្លេះនោះ តើដោយខ្វះទោសនោះម្ដេច អ្នកទើបឲ្យទករត្ថុសបាធំហីន ? ។

ទើបព្រះបាទចុឡនី ស្ដេចសំដែងទោសនៃព្រាហ្មណ៍បុរោហិតបន្ទូលសូត្រជាបទព្រះគាថាដូច្នេះ ៖

បរិភាយិំបិ មេ អយ្យេ ឧម្មិលិត្វា ឧទិក្ខតិ

តស្មា អច្ឆកម៌ លុទ្ទំ ឧជ្ជាហំ ឧការត្ថិ ឆោតិ ។

ប្រែថា ហៃនាងភេរីបរិព្វាជិកាអើយ ! សូម្បីអញអង្គុយនៅនាកណ្ដាលជំនុំបរិស័ទមាត្យទាំងឡាយក្ដី នាងអើយ ! ព្រាហ្មណ៍បុរោហិតនោះ គាត់ក្រៀកក្អែក ធ្វើភ្នែកក្រឡេវទៅដូចគេខឹង ហើយរមិលមើលហាក់ដូចគេខមមកអញកាំងកិតភ័យ ហើយអញចុះទៅដីហេតុទោសនោះហោង អញឲ្យទករត្ថុសបាធ ។

លំដាប់នោះ នាងភេរីបរិព្វាជិកាទូលវិញថា មហារាជ បពិត្រមហារាជអើយ ! អ្នកទាំង ៤ នេះ ហេតុទោសដូច្នោះហើយ ហើយអ្នកសូមឲ្យទករត្ថុសបាធខ្លួនអ្នកឯង បើដូច្នោះ អញនឹងជណ្ដឹងអ្នកវិញទៀត អ្នកយល់គុណហៅមហោសថមានប្រការនោះតើដូចម្ដេច ? នាងភេរីបរិព្វាជិកាទូលជណ្ដឹងសូត្រជាបទព្រះគាថាដូច្នេះ ៖

សសមុទ្ទបរិសាសំ មហិសាគរកុណ្ឌលំ
ពសុន្ធរំ អាវសសិ អមច្ចបរិវារិតោ ។
ធាតុរដ្ឋោ មហារដ្ឋោ វិជិតាវី មហព្វលោ
បថព្យា ឯករាជាសិ យសោ តេ វិបុលំ គតោ ។
សោឡសិត្ថីសហស្សានិ អាមុត្តមណិកុណ្ឌលា
នានាជនបទា នារី ទេវកញ្ញូបមា សុភា ។
ឯវំ សព្វង្គសម្បន្នំ សព្វកាមសមិទ្ធិនំ
សុខិតានំ បិយំ ទីឃំ ជីវិតំ អាហុ ខត្តិយ ។
អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
បណ្ឌិតំ អនុរក្ខន្តោ បាណំ ចជសិ ទុច្ចជន្តិ ។

ប្រែថា មហារាជអើយ ! ឥឡូវនេះ អ្នកជាស្តេចប្រសើរតែម្នាក់ឯង នៅនាផ្ទៃក្រោមនេះជាឥស្សរកំពូលអស់ទ្វីបទាំង ៤ ដ៏មានទីទៅនូវអាមាត្យមុខមន្ត្រីសេនាបតីផងទាំងឡាយជាបរិវារ ឯអស់អ្នកផងនៅសព្វថ្ងៃដ៏ផ្ទៃក្រោមនេះ មានអ្នកដ៏ជាតិស្សរអស់នាហ៊ានលំនៅបុរសផងទាំងឡាយ ទៅដល់ឆ្នេរមហាសមុទ្ទជាបរិក្ខេប: រីសមុទ្ទសាគរនោះសោត តែងជាគ្រឿងប្រដាប់ផ្ទៃក្រោមនេះ ហើយមានកំលាំងនោះច្រើន អ្នកមានជ័យឈ្នះសង្គ្រាមចម្បាំងនោះផង រីកេរ្តិ៍យសអ្នកសោត ដ៏ឆលាយ មាននីទៅនូវស្រីស្នំផងទាំងឡាយ មួយម៉ឺនប្រាំមួយពាន់

សឹងពាក់នៅនូវកងកុណ្ឌលផង សឹងកែវមណីរ័តន៍ពិចិត្រប្រពៃ ស្រីជនបទផងផ្សេងៗ សឹងល្អប្រពៃ ដូចស្រីស្នំទេពកញ្ញា ហើយអ្នកប្រកបនូវឥស្សរសម្បត្តិទាំងអម្បាលនេះ ទើបលោកហៅមហាក្សត្រសេជីវិតហើយតែងនឹងប្រកបនូវសុខសួស្តីសំរិទ្ធី លុះដោយនូវចំណង់ទាំងពួងនោះអ្នកផងទាំងពួងនឹងស្រឡាញ់អស់កាលដ៏លង់ទៅហោង ហើយម្ដេចក៏អ្នកមកក្រោងហៅមហោសថអ្នកប្រាជ្ញនេះ ហើយថាសូមចង់ជីវិតអាត្មាឯងវិញដូច្នេះ តើមួយទីសោត ហេតុដោយវណ្ណៈអ្វី ដោយហេតុប្រយោជន៍នោះតើឈ្មោះអ្វី ក៏អ្នកថាសូមចង់ជីវិតអ្នកឯងវិញនោះហ៎ន ។

ឯព្រះបាទចុល្លនីព្រហ្មទត្តនោះមិញ អ្នកស្ដាប់នាងកេវដ្តាជិកាហើយ ស្ដេចខឹងសម្ដែងគុណនៃហៅមហោសថអ្នកប្រាជ្ញ ទើបសូត្រជាបទគាថាដូច្នេះ :

# ជូនចាស់ម្នាក់ឈ្មោះ កញ្ញានី សែនឧទ្ទិសផល

# ជូនទៅឱ្យខ្មោចធម៌សុចរិត

*រៀបរៀងដោយព្រះសាសនមុនី គឹម - ទូ*

---

រឿងនេះជាប្រវត្តិមួយដែលកើតឡើងកន្លងទៅជាយូរឆ្នាំហើយ: មានបុរសកម្លោះម្នាក់នៅក្នុងក្រុងពារាណសី កាលដែលឪពុកទទួលអនិច្ចកម្មទៅហើយ ក៏លើកតម្កើងម្ដាយទុកក្នុងឋានៈដ៏ខ្ពង់ខ្ពស់ដូចជាទេវតា ខំប្រតិបត្តិថែទាំបំរើម្ដាយដោយកិច្ចវត្តគ្រប់យ៉ាង មានជូនទឹកក្ដៅទឹកត្រជាក់សម្រាប់ងូត លុបមុខនឹងឈើស្ទន់ជាដើម ជូនចំណីអាហារមានបបរនឹងបាយជាដើមគ្រប់វេលា ៗ យាយកញ្ញានីជាម្ដាយ ដោយហេតុមានកូនប្រុសតែមួយជាទីស្រឡាញ់ ឃើញកូននោះធ្វើការនៅព្រៃផង នៅផ្ទះផង ដែលមានសេចក្ដីទុក្ខលំបាកនឿយហត់ខ្លាំង នឹកអាណិតកូនយ៉ាងក្រៃលែងហើយនិយាយនឹងកូននោះថា នែកូន! សព្វថ្ងៃ ម្ដាយឃើញកូនឯងនឿយហត់ណាស់ ណាធ្វើការព្រៃផង ណាផាកមកធ្វើការផ្ទះផងៗ ម្ដាយគិតថា នឹងរកប្រពន្ធឲ្យកូនឯងក្នុងពេលឆាប់ ៗ នេះ ដើម្បីឲ្យវាធ្វើការនៅផ្ទះ ជំនួសកម្លាំងកូនឯងខ្លះ តើកូនឯងយល់ថាម៉េច? កូនប្រុសឆ្លើយថា ខ្ញុំមិនសូវជាចង់បានប្រពន្ធទេ ព្រោះគិតឃើញថា យកគេមកនៅក្នុងផ្ទះ ឲ្យគេបំរើម្ដាយខ្លួនក្រែងមិនដូចខ្លួនខ្ញុំ ខ្ញុំតាំងចិត្តថា យកខ្លួនបំរើម៉ែអស់មួយជីវិត កុំឲ្យម៉ែព្រួយ ៗ យាយកញ្ញានី ទោះឮពាក្យកូន

និយាយប្រកែកដោះសាយ៉ាងណា ក៏នៅតែមិនអស់មិនហើយពីក្នុងចិត្ត សោះ ចេះតែខ្ទូចនិយាយហើយ និយាយទៀត អស់វារៈជាច្រើនដង ៗ ឯបុរសជាកូននោះ ពាល់គំនិតក៏នៅស្ងៀមឥតមានប្រកែកថាអ្វីទៀតឡើយ ដោយតាំងចិត្តគោរពចំពោះម្តាយរបស់ខ្លួន ៗ យាយកញ្ចានី កាលបើដឹងថាកូនលែងប្រកែកហើយ ក៏ទៅកាន់ត្រកូលមួយ និយាយដណ្តឹងកូនស្រីគេដែលមានជាតិត្រកូលប្រហែលគ្នានឹងខ្លួន ត្រកូលនោះក៏ព្រមព្រៀងប្រគល់ឲ្យ ហើយក៏នាំគ្នាធ្វើអាពាហមង្គលតាមប្រពៃណីរួចសព្វគ្រប់ហើយ យាយកញ្ចានី ក៏នាំកូនប្រសាស្រីនោះមកឲ្យនៅក្នុងផ្ទះរបស់ខ្លួន ៗ នាងកូនប្រសានោះ តាំងពីចូលមកនៅក្នុងផ្ទះម្តាយក្មេក នៅរួមសុខទុក្ខជាមួយនឹងប្តីរបស់ខ្លួន មុនដំបូងក៏យកចិត្តទុកដាក់ធ្វើកិច្ចការក្នុងផ្ទះបំរើគោរពម្តាយក្មេកឥតមានការមោះហ្មងអ្វីឡើយ ៗ លុះកាលជាខាងក្រោយមកនាងនោះក៏មានគំនិតអាក្រក់កើតឡើង ចង់បណ្តេញបំបរបង់ម្តាយក្មេកចាស់នោះឲ្យចេញពីផ្ទះ ព្រោះថាបើទុកឲ្យយាយចាស់នៅក្នុងផ្ទះនេះតទៅនាំឲ្យអញលំបាកបំរើផ្គាប់ផ្គុណគាត់ណាស់ បើរកឧបាយធ្វើឲ្យគាត់នេះឃ្លាតចេញពីផ្ទះទៅ អញនឹងបានសុខស្រួល មិនសូវលំបាកប៉ុន្មានផង ៗ

ថ្ងៃមួយ នាងនោះនិយាយនឹងប្តីរបស់ខ្លួន ដោយប្រើឧបាយទុច្ចរិតញុះញង់មួលបង្កាច់បំផ្លើសពីសេចក្តីពិត ទម្លាក់ទោសកំហុសទៅលើយាយ កញ្ចានីជាម្តាយក្មេក ដើម្បីឲ្យប្តីជឿថា បង! បងឯងចេញពីផ្ទះ

ទៅធ្វើការខាងក្រៅបាត់ទៅ ម្ដាយបងឯង មិនដឹងជាហេតុអ្វីទេ ស្រាប់តែដេរបញ្ចោរខ្ញុំតែម្ដង ៗ បុរសជាប្ដីនោះ ឮពាក្យប្រពន្ធនិយាយប្រាប់ដូច្នោះ មុនដំបូងនៅស្ងៀម ៗ ក្រោយមក ប្រពន្ធក៏និយាយទៀត ៗ ចាប់ដើមពីថ្ងៃនោះ នាងប្រពន្ធចេះតែបង្កហេតុផ្សេង ៗ ជួនកាលដួសយកបបរដែលកំពុងក្ដៅខ្លាំងទៅបន្ទំម្ដាយក្មេកឲ្យបរិភោគ កាលបើម្ដាយប្រាប់ថា បបរនេះនៅក្ដៅណាស់កុំគាលសិន ក៏ទៅយកទឹកត្រជាក់មកចាក់បំពេញក៏មាន ជួនកាលយកបបរត្រជាក់ស្រេងទៅបន្ទំឲ្យបរិភោគ បើម្ដាយក្មេកប្រាប់ថា បបរនេះត្រជាក់ណាស់ ទៅយកទឹកក្ដៅកំពុងពុះមកចាក់បំពេញក៏មាន ជួនកាលយកបបរប្រៃពេក សាបពេក ទៅបន្ទំឲ្យបរិភោគក៏មាន កាលបើម្ដាយក្មេកប្រាប់ថា បបរប្រៃពេកឬសាបពេក ក៏ស្រែកគំហកគម្រាមដោយសំដីទ្រគោះបោះបោកថា គ្មានអាណាផ្គាប់ចិត្តកញ្ចាស់ឯងត្រូវទេ ម្ដងអីចេះ ម្ដងអីចុះ គេយកបបរក្ដៅមកឲ្យថាក្ដៅពេក បបរត្រជាក់ថាត្រជាក់ពេក យកបបរប្រៃមកឲ្យថាប្រៃពេក បបរសាបថាសាបពេក បើចេះតែយ៉ាងហ្នឹង អាណាផ្គាប់ត្រូវ ៗ នាងនោះចេះតែរអ៊ូទាំ ធ្វើអាការបញ្ឆោះបន្សៀកបង្កហេតុឈ្លោះប្រកែកជាមួយនឹងម្ដាយក្មេកដូច្នេះតែរាល់ថ្ងៃ ដោយគំនិតមិនចង់ឲ្យម្ដាយក្មេកនៅក្នុងផ្ទះជាមួយ ៗ

កាលណាបើប្ដីត្រឡប់មកពីធ្វើការវិញម្ដង ៗ នាងប្រពន្ធតែងនិយាយត្អូញត្អែររៀបរាប់ប្រាប់ប្ដីដូច្នេះខ្លះ ដូច្នោះខ្លះ តាមដែលខ្លួនទឹក

ឃើញ ហើយក៏និយាយថែមទៀតថា ខ្ញុំមើលទៅប្រហែលជាត្រាំនៅក្នុងផ្ទះនេះជាមួយនឹងយាយកញ្ចាស់ចង្រៃកាឡកណ្ណីបែបនេះទៀត ពុំបានទេ បើបងឯងមិនជឿ មិនស្ដាប់ខ្ញុំទេ ខ្ញុំមុខជានឹងចុះចេញទៅនៅខាងផ្ទះម្ដាយឪពុកខ្ញុំវិញ នៅថ្ងៃណាមួយជាមិនខាន ៗ បុរសជាប្ដី កាលបើប្រពន្ធនិយាយប្រាប់អំពីទោសម្ដាយរបស់ខ្លួនញយ ៗ ហើយ ក៏ជឿតាមពាក្យប្រពន្ធ ហើយទៅនិយាយរករឿងបណ្ដេញម្ដាយខ្លួនថា ម៉ែឯងចុះចេញពីផ្ទះនេះទៅ ចូរទៅនៅទីណាដែលពេញចិត្តចុះ ៗ យាយកច្ចានីជាម្ដាយ លុះឮសំដីកូននិយាយបណ្ដេញខ្លួនដូច្នោះ ក៏កើតទុក្ខទ្រហោយំ ចុះចេញពីផ្ទះ ហើយទៅធ្វើការស៊ីឈ្នួលអាស្រ័យ នឹងត្រកូលដ៏សុគតម្នាក់មួយរកស៊ីចិញ្ចឹមជីវិតដោយលំបាក ៗ កាលដែលម្ដាយក្មេកនោះចេញពីផ្ទះទៅហើយ ខាងក្រោយមក កូនប្រសាស្រីនោះមានគភ៌ បានកើតកូនប្រុសមួយក៏និយាយនឹងប្ដីថា នែបង! បងឯងឃើញទេ ម្ដាយបងឯងពេញជាស្រីចង្រៃមែន កាលដែលម្ដាយបងឯងនៅក្នុងផ្ទះជាមួយខ្ញុំ មិនដែលមានកូនសោះ ឥឡូវស្រាប់តែខ្ញុំមានកូន បងឯងចូរដឹងថាម្ដាយបងឯងនោះពិតជាស្រីកាឡកណ្ណីប្រាកដមែនហើយ ៗ

ចំណែកខាងយាយកច្ចានីបានដំណឹងថា កូនប្រសាមានកូន ខាងក្រោយដែលខ្លួនថយចេញពីផ្ទះហើយបានចាំងឮទៀតថា ចង្រៃមកពីខ្លួន ទើបបានជាគេគ្មានកូន ៗ យាយកច្ចានីគិតថា: ឱពុទ្ធោអើយ! បើរឿងនេះពិត

ដូច្នោះមែន គួរឲ្យអស់សំណើចណាស់ ជេដ្ឋាបចាយនធម៌ (ធម៌សម្រាប់ធ្វើសេចក្តីគោរពកោតក្រែងរវាងគ្នានិងគ្នា ក្នុងត្រកូលគ្រួសារ) និងធម៌សុចរិតទាំងប៉ុន្មានក្នុងលោកនេះ ប្រហែលជាស្លាប់បាត់ទៅហើយទេដឹង? បើធម៌សុចរិតទាំងនេះមិនទាន់ស្លាប់នៅឡើយទេ កូនដែលកជេរ បណ្តេញម្តាយឲ្យចេញពីផ្ទះ មុខជាមិនបានកូនទេ មុខជាមិនបានសុខទេ ដូច្នេះឃើញថា ជេដ្ឋាបចាយនធម៌និងសុចរិតធម៌ ស្លាប់បាត់ជាប្រាកដហើយ ៗ បើយ៉ាងហ្នឹងមែន អញគួរតែធ្វើបុណ្យឧទ្ទិសផលបញ្ជូនទៅឲ្យខ្មោចធម៌ទាំងនោះ ។ លុះគិតដូច្នោះហើយ យាយកត្តានី ក៏រៀបចំយកឆ្នាំងនិងអង្ករ ព្រមទាំងម្ហូបខ្វះបន្តិចបន្តួច ដើរចូលទៅក្នុងព្រៃខ្មោច ដល់ហើយក៏រើសប្រមូលក្បាលខ្មោចមនុស្ស៣ មកដាក់តំកល់ធ្វើជាមុំជើងក្រានតាំងដណ្តាំបាយ ចំអិនម្ហូប រួចហើយក៏បេះស្លឹកឈើយកមកដាក់បាយខ្វះម្ហូបខ្វះ រៀបចំសែនឧទ្ទិសទៅឲ្យខ្មោចធម៌ថា ឱ ជេដ្ឋាបចាយនធម៌ និងសុចរិតធម៌ អើយ! អ្នកប្រាកដជាស្លាប់បាត់ទៅហើយ បានជាខ្ញុំត្រូវកូនធ្វើទុក្ខបុកម្នេញ ជេរបណ្តេញឲ្យចេញពីផ្ទះ ហើយមកនៅរងទុក្ខលំបាកតែម្នាក់ឯងយ៉ាងនេះ បើអ្នកនៅរស់មិនស្លាប់ទេ ប្រហែលជាខ្ញុំបានសុខ នៅរួមជាមួយនិងកូន មិនមែនមកទទួលទុក្ខវេទនាដូច្នេះឡើយ ខ្ញុំជឿជាក់ថា សុចរិតធម៌ប្រាកដជាស្លាប់មែនហើយ ឥឡូវខ្ញុំសូមឧទ្ទិសកុសលនេះ ជូនទៅឲ្យខ្មោចធម៌សុចរិតឯង សូមឲ្យអ្នកទទួលយកចុះ ។ ខណៈនោះ មានទេវតាមួយ

អគ្គ ឃើញយាយកត្តានី ដែលដល់នូវសេចក្ដីទុក្ខលំបាក កំពុងតែធ្វើកិច្ច សែនទក្ខិណកុសលជូនទៅឲ្យវិញ្ញាណខន្ធនៃខ្មោចធម៌សុចរិត ដោយសំគាល់ថា ធម៌ស្លាប់ហើយ ក៏ជំណែងភេទជាព្រាហ្មណ៍ចាស់ម្នាក់ដើរចូលទៅសួរថា នែយាយ! យាយឯងរៀបចំធ្វើអ្វីហ្នឹង?-ចាសតា! ខ្ញុំសែនជូនបុណ្យទៅឲ្យខ្មោចធម៌សុចរិត ។ តាព្រាហ្មណ៍សួរថា យី! សែនជូនបុណ្យទៅឲ្យខ្មោចធម៌សុចរិតយ៉ាងម៉េចអីចេះ ចំឡែកណាស់តើ ខ្ញុំតាំងពីកើតមកដល់ចំណាស់នេះ មិនដែល ៗ មិនដែលឃើញបែបនេះសោះទេ ធ្លាប់ឃើញតែគេសែនជូនទៅឲ្យខ្មោចមនុស្ស ចុះរឿងនេះវាមានហេតុភេទដូចម្ដេចខ្លះទៅ ចូរយាយប្រាប់ឲ្យហូរហែមកមើល?-ទេតាអើយ! រឿងនេះ គឺវាកើតលេចចេញមកពិសាច់ឈាមឯងតែម្ដង មិនមែនអ្នកដទៃក្រៅមកឲ្យទេ ដ្បិតខ្ញុំ មានកូនប្រុសតែមួយជាទីស្រឡាញ់របស់ខ្ញុំ លុះឥតអំពីប្ដីរបស់ខ្ញុំទៅ កូនប្រុសខ្ញុំនោះ មានដេញបងាយនធម៌ នឹងសុចរិតធម៌ រស់រវើកមកលើរូបខ្ញុំ គឺចេះគោរពប្រតិបត្តិទំនុកបំរុងគ្រប់បែបយ៉ាង មានជូនទឹកក្ដៅទឹកត្រជាក់ នឹងចំណីអាហារជាដើមដល់ខ្ញុំគ្រប់វេលា គ្មានដែលមោះហ្មងអ្វីឡើយ ខ្ញុំគិតឃើញថាសព្វថ្ងៃកូនមានសេចក្ដីនឿយហត់លំបាកណាស់ ធ្វើការនៅក្រៅផ្ទះផង ធ្វើការក្នុងផ្ទះផង លុះគិតឃើញយ៉ាងនេះហើយ ក៏និយាយនឹងកូនថា នែកូន! ម្ដាយគិតរកប្រពន្ធឲ្យកូនឯងគ្រាន់នឹងបានឲ្យគេជំនួសកម្លាំងកូន

ឯងខ្លះ ៗ មុនដំបូង កូនខ្ញុំប្រកែកមិនព្រមយកដែរ ប៉ុន្តែដល់និយាយបង្ខំញយៗទៅ ក៏ព្រមតាមខ្ញុំ ខ្ញុំទៅនិយាយដណ្តឹងកូនស្រីគេបានហើយ ធ្វើមង្គលការរួចសព្វគ្រប់ ក៏នាំយកមកឲ្យនៅក្នុងផ្ទះជាមួយ ៗ នាងកូនប្រសារនោះ មុនដំបូងមានអ៊ីស្រួលបួលល្អណាស់ ពេះមានជេដ្ឋាបចាយនធម៌ និង សុចរិតធម៌ គួរសម រស់រវើកមកលើរូបខ្ញុំជាម្តាយក្មេកដូចជាកូនប្រុសបង្កើតដែរ ៗ ខាងក្រោយមក មិនដឹងជាទោសកាលអ្វី មេកូនប្រសានោះ វាក្តៅក្រហាយធ្វើទុក្ខបុកម្នេញ បញ្ចោះបញ្ចៀតដល់ខ្ញុំតែរាល់ថ្ងៃ លែងមានជេដ្ឋាបចាយនធម៌ និងសុចរិតធម៌ មកលើរូបខ្ញុំទាល់តែសោះ មិនតែប៉ុណ្ណោះ វានិយាយញុះញង់ដឹកនាំកូនប្រុសខ្ញុំដែលត្រូវជាប្តីវា ឲ្យជួយវាយប្រទូស្តនឹងខ្ញុំថែមទៀត ឯកូនប្រុសខ្ញុំនោះសោត ដែលជាកូនធ្លាប់តែមានជេដ្ឋាបចាយនធម៌និងសុចរិតធម៌ គួរសមមកលើរូបខ្ញុំជាម្តាយជានិច្ចកាលពុំដែលមានទោសជាទម្ងន់សោះ ក៏ត្រឡប់ទៅសម្លាប់ជេដ្ឋាបចាយនធម៌ និងសុចរិតធម៌ឲ្យស្លាប់អស់រលីង ដោយការញុះញង់ពីមេកូនប្រសារនោះ ម្លោះហើយក៏ព្រួតដៃគ្នា ដេញបណ្តេញបំបរបង់ខ្ញុំជាម្តាយឲ្យចុះចេញពីផ្ទះ ខ្ញុំពុំអាចទ្រាំនៅតទៅទៀតបាន ក៏ចុះចេញពីផ្ទះដើរទៅរកសុំទានគេខ្លះ ស៊ីឈ្នួលគេខ្លះ ដោយសេចក្តីទុក្ខលំបាកយ៉ាងខ្លាំង គ្រាន់តែឲ្យរស់នៅទាំងគ្រដរ ដរាបមកដល់សព្វថ្ងៃនេះ ៗ

ពីដើមខ្ញុំធ្លាប់បានទទួលជេដ្ឋាបចាយនធម៌ និងសុចរិតធម៌អំពីកូន

របស់ខ្ញុំ ឥឡូវ ជេដ្ឋាបចាយនធម៌ និងសុចរិតធម៌នោះស្លាប់ទៅហើយ ទើបបានជាខ្ញុំរៀបចំធ្វើកិច្ចសែនបញ្ចូនបុណ្យនេះ ទៅឲ្យខ្មោចធម៌ដែលស្លាប់ទៅហើយនោះ សូមតាជ្រាបចុះ ។

-ឱអ៊ីចឹងទេឬ! បើតាមខ្ញុំយល់ថា ជេដ្ឋាបចាយនធម៌និងសុចរិតធម៌មិនទាន់ស្លាប់ទេ គឺរស់រវើកគាំងនៅជាប្រក្រតី ប៉ុន្តែមកពីកូនយាយឯងទេតើ ដែលលះបង់ចោលមិនកាន់ ។ អើមិនអីទេយាយ យាយឯងកុំព្រួយ ចាំខ្ញុំនឹងជួយស្រោះស្រាំ ធ្វើឲ្យជេដ្ឋាបចាយនធម៌ និង សុចរិតធម៌ក្នុងគ្រួសាររបស់យាយឯងរស់ឡើងវិញ ហើយនឹងជួយឲ្យយាយឯងបានទៅនៅផ្ទះវិញផង ដោយឧបាយរបស់ខ្ញុំជាមិនខាន ។

- សូមអរគុណនិងប្រសាសន៍របស់តាណាស់ ប៉ុន្តែខ្ញុំមើលទៅប្រហែលជាគ្មានទិស្សយេសង្ឃឹមថា នឹងបានទៅនៅផ្ទះនោះវិញទេ តា! ។

ទេព្តាដែលតំណែងគេជាព្រាហ្មណ៍នោះ បានទៅកាន់ផ្ទះកូនរបស់យាយកច្ចានីនោះ ហើយក៏និយាយពន្យល់អំពីគុណនិងទោសរបស់កូនដែលគោរពនិងមិនគោរពចំពោះមាតានិងបិតារបស់ខ្លួន ឲ្យកូនប្រុសព្រមទាំងកូនប្រសាស្រីនោះស្តាប់សព្វគ្រប់ហើយ ក៏ត្រឡប់ទៅកាន់វិមានរបស់ខ្លួនវិញ ។

ក្រោយដែលបានស្តាប់ទំនាស់របស់ទេព្តានោះមក ជនទាំងពីរនាក់គឺប្តីនិងប្រពន្ធ មានសេចក្តីភិតភ័យតក់ស្លុតនិងកំហុសរបស់ខ្លួន ក៏បានញុំាង

ដេជ្ញាបចាយនធម៌ នឹងសុចរិតធម៌ ឲ្យកើតពោរពេញស់រើកក្នុងសន្ដាន ចិត្តឡើងវិញ ហើយនាំគ្នាទៅអញ្ជើញយាយកញ្ចានីជាម្ដាយអំពីព្រៃខ្មោច នោះមកឲ្យនៅផ្ទះ ហើយនាំគ្នាគោរពប្រតិបត្តិ ទំនុកបំរុងតាមឋានៈនៃខ្លួនជាកូនដូចដើមឡើងវិញ ។

# អំពីចោរកម្ម

(វិចារណកថា)

រៀបរៀងដោយលោក ដេង-ជ្រឹវ

---

អំពីរឿងចោរកម្មនេះ ប្រទេសណាក៏មាន គ្រាន់តែប្លែកគ្នាត្រង់ច្រើននឹងតិចប៉ុណ្ណោះ ។ គួរគិតគួរត្រិះរិះដែរ ចំពោះរឿងនេះ ព្រោះជាឧបសគ្គដ៏ធ្ងន់ដល់ប្រទេសជាតិ ។ ច្បាប់សម្រាប់រដ្ឋនីមួយ ៗ មានបញ្ចូលបទចោរកម្ម នៅក្នុងមាត្រាស្ដីពីការហាមឃាត់ និងស្ដីពីការផ្ដន្ទាទោស ។ ច្បាប់សាសនាក៏មានលើកយកបទចោរកម្ម មកដោះស្រាយ មានតាំងប្រាប់អានិសង្សដ៏លាមក តាំងខាងបច្ចុប្បន្ន តាំងខាងបរលោក តែចោរកម្មនៅតែមានជាដរាប ។

មានបញ្ហាចោទឡើងថា: ចោរកម្មមកអំពីអ្វី ? និងអាចចៀសវាងបានឬមិនបាន ?

តាមការត្រិះរិះ និងការសង្កេត ឃើញថាចោរកម្មកើតមកពីសេចក្ដីត្រូវការ និងសេចក្ដីត្រូវការហួសប្រមាណ ។

ចំពោះន័យនេះ គេជ្រៀតចូលមកទៀតថា មានជនខ្លះ មានសេចក្ដីត្រូវការដែរ តែគេមិនអាចធ្វើចោរកម្មបាន ។ បើដូច្នេះ ឃើញថាសំនួរទី ២ ត្រូវដោះស្រាយនៅឯង ព្រោះមនុស្សអាចចៀសវាងចោរកម្មបាន ។ ពាក្យដែលថា « សេចក្ដីត្រូវការ និងសេចក្ដីត្រូវការហួសប្រមាណ » ជាការណ៍ពិត តែការណ៍ពិតនេះ រមែងពឹងផ្អែក

រមែងសឹកផ្តេក តែទៅលើចរិយារបស់ជនម្នាក់ ៗ ប៉ុណ្ណោះ មិនមែនជាការណ៍ ទូទៅឡើយ ព្រោះភោគៈអាចនឹងរកតាមផ្លូវសុចរិតបាន ។

តទៅនេះ នឹងល្បងវែកញែកនូវប្រភេទនៃចោរកម្ម តើដូចម្ដេចខ្លះ?

ចោរកម្មចែកជាមេចម្បងមានពីរ ដែលខ្ញុំសន្មតឈ្មោះថា: ចោរកម្មព្រោះភ្លើង និងចោរកម្មស៊ីស្ករ ។

ឯចោរកម្មព្រោះភ្លើងចែកជាមែកធាងច្រើនប្រការ: ការកាន់យកដោយស្ងាត់កំបាំងក្នុងទីងងិត ការឆក់យក ការប្លន់យក ការប្រវញ្ចបោកបញ្ឆោត ការប្លន់ ។ល។ ទាំងនេះហៅថាចោរកម្មព្រោះភ្លើង ។

ចុះចោរកម្មស៊ីស្ករដូចម្ដេច? ចោរកម្មនេះឃុំយក: ការលក់ដូររបស់ដោយការបន្លំ ការលក់ដូរវត្ថុក្លែងក្លាយ ការលក់ដូរដោយវិធីបំបាត់ក្អែកជញ្ជីង ឬ ដោយជញ្ជីងក្លែង ការបំពេញមុខងារមិនយកចិត្តទុកដាក់ ការបំពេញមុខងារដោយប្រចុបប្រចែង ឡេបឡប ឡេមឡឺម ការកាន់មុខងារមិនស្មោះត្រង់ ការប្រព្រឹត្តធម៌មិនតាមគន្លង ទាំងនេះហៅថា « ចោរកម្មស៊ីស្ករ » ។

សូមមិត្តអ្នកអានទាំងឡាយជួយពិចារណាមើល តើចោរកម្មព្រោះភ្លើងនិងចោរកម្មស៊ីស្ករទាំងពីរនេះ មួយណាមានអានុភាពនឹងឲ្យផលអាក្រក់ដល់ទូលំទូលាយជាងមួយណា? តើគួរខ្លាច គួរខ្ពើមរអើមមួយណាជាងមួយណា?

បើតាមការសង្កេត និងការធ្លាប់ដឹងឮ ព្រោះភ្លើងនឹងស៊ីស្ករ មានសភាពស្ទើរប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែ បើជញ្ជីងត្រិះរិះឲ្យជ្រៅបន្តិចទៅទៀត ឃើញថាស៊ីស្ករខ្លាំងជាង សមដូចពាក្យថាៈ «ភ្លើងក្តាំងស៊ីទឹកពក់ ហ៊ឹម ៗ ស៊ីទឹកជ្រៅ» ។ បើពោលជាឧភល គួរតែខ្ពើមរអើមទាំងពីរ កុំថាឡើយអ្នកសុចរិតដែលមិនចង់ឃើញចង់យល់ នូវចោរកម្ម សូម្បីចោរខ្លួនឯងហ្នឹង ក៏មិនត្រូវការចោរកម្មដែរ ដូចមនុស្សម្នាក់ធ្វើចោរកម្ម ហើយមានម្នាក់ទៀតមកបន្តធ្វើចោរកម្មពីលើអ្នកខាងដើម អ្នកនេះក៏មិនសប្បាយចិត្តឡើយ ។

ដូច្នេះ តាមតែព្រោះភ្លើងក្តី ស៊ីស្ករក្តី ត្រូវតែចៀសវាង ត្រូវតែស្អប់ខ្ពើម ។

តទៅនេះ គឺវែកញែក រកសេចក្តីអន្តរាយ សេចក្តីទុក្ខវេទនា សេចក្តីល្ហិតល្ហៃ ដែលបណ្តាលមកពីចោរកម្មទាំងពីរ តើមួយណាស៊ីពលធំជាងមួយណា ? មួយណាជាភ្លើងឆេះព្រៃ មួយណាជាភ្លើងឆេះផ្ទះ ។

បើពិចារណាឲ្យសព្វគ្រប់ បើសង្កេតឲ្យដិតដល់ ឃើញថាព្រោះភ្លើងខ្សោយជាងស៊ីស្ករ ។ ព្រោះភ្លើងធ្វើឲ្យអន្តរាយ ធ្វើឲ្យខូចប្រយោជន៍ចំពោះបុគ្គល បើយ៉ាងធំណាស់ត្រឹមតែគណៈ ចំណែកស៊ីស្ករ ធ្វើឲ្យរងទុក្ខវេទនាដល់សង្ឃ ប្រៀបបាននឹងភ្លើងឆេះព្រៃ ដូចអស់លោកអ្នកមានជ្រាបស្រាប់ មិនធ្វើឲ្យវិនាសត្រឹមតែដើមឈើដែលជាសម្បត្តិជាតិ

ប៉ុណ្ណោះទេ គឺស្លាប់តាំងពីស្រមោចសង្អាឡើងទៅ គឺជាជីវិតសត្វរាប់មិនអស់ដែលត្រូវធ្លាក់ក្នុងមហាមាត់ ប្រកបដោយចង្កូមដ៏មុតសាហាវនៃភ្លើងព្រៃ ៗ ត្រូវប្រគល់ដល់មនុស្សនិងសត្វនានា នូវផលមួយទៀតដ៏សែនអាក្រក់គួរឲ្យសង្វេគ គួរឲ្យអាណោចអាធ័ម គឺការខ្វះភ្លៀងនិងទឹកហូរព្រោះ ដែលជាបច្ច័យដល់អាយុជីវិតនៃមនុស្សក្នុងប្រទេសទាំងមូល ៗ ចោរកម្មស៊ីស្ករ ពិតជាធ្វើឲ្យវិនាសប្រយោជន៍ដល់សង្ឃតែម្ដងដូចជាភ្លើងឆេះព្រៃនេះឯង ៗ តាមលទ្ធិពុទ្ធសាសនា ត្រង់នេះគឺលើកយកអានិសង្សជាកុសលមកបរិយាយប្រៀបធៀប : ធ្វើទានចំពោះបុគ្គលបានអានិសង្សមិនស្មើនឹងគណៈ ធ្វើទានចំពោះគណៈ បានអានិសង្សមិនស្មើចំពោះសង្ឃ ៗ ពាក្យថា « បុគ្គល » សំដៅយកតែមនុស្ស-ម្នាក់ ពាក្យថា « គណៈ » សំដៅយកចំនួនរូបមនុស្សពីពីរនាក់ទៅត្រឹមបីនាក់ ឯ « សង្ឃ » វិញ សំដៅយកចំនួនរូបមនុស្សពីបួននាក់ឡើង-ទៅ អ្នកណាធ្វើទានចំពោះសង្ឃនឹងបានផលានិសង្សច្រើនអនេកអនន្ត ៗ នេះចំពោះផ្លូវជាកុសល ឯផ្លូវជាអកុសលវិញក៏យ៉ាងនោះដែរ ដូចចោរ-កម្មស៊ីស្ករ គឺពិតជាធ្វើចំពោះសង្ឃហើយ ៗ អំពើណាដែលបណ្ដាលឲ្យមានសេចក្ដីទុក្ខធំទូលំទូលាយ ការផ្ដន្ទាទោសក៏គួរតែឲ្យធំស្មើគ្នា ទើប-សម ៗ ក៏ប៉ុន្តែ ត្រូវចាត់វិធានការណ៍ដូចម្ដេច ដើម្បីអាចផ្ដន្ទាទោសដល់ចោរកម្មស៊ីស្ករបាន? ព្រោះស៊ីស្ករ គាត់ច្រើនស្ទើរតែទាំងអស់ មិនសូវ-

ដែលពុថាបានទទួលទណ្ឌកម្មសោះ ៗ គឺចំណុចត្រង់នេះហើយដែល មានសេចក្ដីលំបាកយ៉ាងខ្លាំងមិនអាចដោះស្រាយរួច ព្រោះស៊ីស្កទឹង ស៊ីស្កជួបគ្នា ឧបមាដូចជាសាច់ញាតិ នឹងសាច់ញាតិជួបគ្នា ត្រូវតែ-ស្រឡាញ់គ្នា រាប់រកគ្នា តិចណាស់ដែលបងប្អូនធ្វើបាបបងប្អូនឯង ៗ បើដូច្នេះត្រូវចាត់ការយ៉ាងណា ដើម្បីបំបាត់ទោរកម្មស៊ីស្កបាន ? តាមយោបល់ខ្ញុំមានមធ្យោបាយបី គឺទី ១ យកសតិសម្បជញ្ញៈជាប្រមាណ ទី ២ បង្ក្រាបដោយកំណត់ក្នុងការចំណាយ ទី ៣ ត្រូវបញ្ជូនទៅបរលោក ៗ

# ដើមកំណើត និង ការវិវត្តន៍នៃអារ្យធម៌ខ្មែរ

ដោយ លី-ធាមតេង

នៅពុទ្ធសាសនបណ្ឌិត្យ

---

យើងដឹងហើយថាដែលគេហៅពេញលេញថា «អារ្យធម៌» មួយ បានលុះណាតែអារ្យធម៌នោះ មានលក្ខណៈគ្រប់គ្រាន់ បញ្ជាក់ឲ្យឃើញនូវការបេះដឹងកុះចេញមកពីជាតិនោះ ច្បាស់ប្រាកដប្រជាសំរាប់ជាគ្រឿងសំគាល់នូវចំណេះវិជ្ជាឬលក្ខណៈនៃសេចក្ដីចំរើនរបស់ជាតិ ៗ រីឯអារ្យធម៌ខ្មែរយើងមានរូបរាងឡើងបន្តិចម្ដង ៗ មកជាអង្វែងហើយ, បើគិតតាមប្រវត្តិសាស្ត្រយើងឃើញថា ចាប់ផ្ដើមមានមកតាំងពីមុន គ្រិស្ដសតវត្សទៅទៀត ។ អារ្យធម៌ដំបូងនោះគឺគម្រង់ការបេះដឹងផ្សេង ៗ មានភាសា-ភេទ-ចំរៀង-ទំនៀមទំលាប់របស់ជនជាតិដើម គឺកុលសម្ព័ន្ធផ្សេង ៗ ជាពួក ផ្ទក់សី (Autochtones) ដែលរស់នៅលើផែនដីខ្មែរយើង ដូចជាគួយ-សំរែ-ពរ-ព្នង ហើយដែលបព្វថ្ងៃពិតមែនតែពួកនេះទៅជាអ្នកនៅដោយព្រៃ ហាក់ដូចគ្មានវប្បធម៌សោះ តែជនជាតិទាំងនេះបានទុកកេរ្ដិ៍អារ្យធម៌ឲ្យយើងច្រើនណាស់ ដូចជាទំនៀមទំលាប់, សិល្បៈ, ភាសា ។ល។ ក្រោយពេលដែលកសាងបានជារូបរាងហើយ អារ្យធម៌យើងក៏ត្រូវទទួលឥទ្ធិពលខ្លះ ៗ អំពីអារ្យធម៌ជនជាតិផ្សេង ៗ ដែលចូលមកអាស្រ័យនៅក្នុងស្រុកយើង ព្រោះជាធម្មតា តាមគតិមនុស្ស

បុរាណ ឬ សព្វថ្ងៃសុទ្ធតែត្រូវការបញ្ចូលបន្ថែមយ៉ាងនេះ ដូចមានសេចក្តីបញ្ជាក់តទៅ នូវដើមកំណើតឥទ្ធិពលដែលផ្សាយចូលមកគឺ៖

## ក – អារ្យធម៌ឥណ្ឌា

អារ្យធម៌ឥណ្ឌាជាអារ្យធម៌ខ្លាំងក្លា ព្រោះមានមកក្នុងអាណាចក្រឥណ្ឌាជាច្រើនពាន់ឆ្នាំមុនគ្រិស្តសករាជ បានឆ្លងចូលមកក្នុងប្រទេសយើងតាមរយៈ ព្រាហ្មណ៍កៅណ្ឌិន្យ កាលពីសតវត្សទី ១ នៃគ្រិស្តសករាជ ហើយបានផ្សាយពាសពេញលើប្រទេសយើងតាំងពីកាលនោះមក ដូចជាភាសាសំស្ក្រឹត, លទ្ធិ, សាសនា និង ទំនៀមជាច្រើនដែលក្លាយទៅជាទំនៀមទំលាប់សមញ្ញរបស់អ្នកស្រុកយើងរហូតដល់សព្វថ្ងៃ ៗ ដោយហេតុពួកព្រាហ្មណ៍ទាំងនោះ បានឡើងជាក្សត្រគ្រងរាជ្យលើទឹកដី ក៏ចាត់ចែងផ្សាយអារ្យធម៌បន្ថែមនេះ ឲ្យបានរីកជាមួយអារ្យធម៌ដើមនៃយើង ៗ

## ខ – អារ្យធម៌ចិន

តាមការសង្កេតអារ្យធម៌ចិនបានចូលមកកាន់ស្រុកយើង ក្នុងរវាងសតវត្សទី ៣ តាមរយៈពួកអន្តោប្រវេសន៍ជាតិចិន ដែលនាំទំនិញចេញចូល ហើយខ្លះក៏មកតាំងទីនៅជាប់លាប់នឹងស្រុកយើងព្រមទាំងមានប្រពន្ធកូនពង្រីកគ្រួសារ ហើយបង្កាត់ហ៊ុកហ៊ុនអារ្យធម៌ចិនតាមរយៈក្រុមញាតិ ព្រោះចិនបានមកពង្រីកគ្រួសារបន្តិចម្តង ៗ ជាពិសេសគឺទំនៀមទំលាប់, ការប្រតិបត្តិក្នុងការរស់នៅប្រចាំថ្ងៃ និងជំនឿផ្សេង ៗ

ច្រើនទៀត ៗ ដូច្នេះឥទ្ធិពលអារ្យធម៌ចិន ក៏រលាយចូលក្នុងអារ្យធម៌ដើមរបស់យើង ហើយកែសាយព្រមគ្នាជាលំដាប់មក ៗ

ក - អារ្យធម៌បស្ចិមប្រទេស

អារ្យធម៌នេះ បានហូរចូលមកស្រុកយើងនៅចុងសតវត្សទី ១៩ តែមានកំឡាំងខ្លាំងក្លាណាស់ ព្រោះជាប់មកជាមួយពួកអ្នកមានអំណាចធ្វើជាអាណាព្យាបាលប្រទេសយើង ៗ ហេតុនេះទើបមានសន្ទុះយ៉ាងហើសនាំឲ្យយើងរើសយកសុជីវធម៌, សំលៀកបំពាក់ទីងបែបបទសិល្បៈខ្លះមកបញ្ចូលថែមក្នុងអារ្យធម៌ដើម ហើយកាន់តែរីកចំរើនឡើងរហូតសព្វថ្ងៃនេះ ៗ

ដូច្នេះ យើងបញ្ជាក់បានថា ទោះបីជាអារ្យធម៌កំណើតដើមរបស់យើង ត្រូវទទួលឥទ្ធិពលអារ្យធម៌ពីទីនានាខ្លះមកបន្ថែមក៏ដោយ ក៏យើងនៅតែមានលក្ខណៈមួយ ជាលក្ខណៈជាតិយើង ឥតឲ្យបាត់បាត់ឡើយ ហើយអារ្យធម៌នានានោះ គ្រាន់តែជារណបឬជាវត្ថុធាតុសំរាប់ធ្វើឲ្យអារ្យធម៌ដើម របស់ខ្លួនយើង រឹតតែមានទ្រង់ទ្រាយល្អឡើងប៉ុណ្ណោះ ៗ ហេតុនេះ ទើបយើងទទួលស្គាល់បានថាខ្មែរមានអារ្យធម៌មួយប្រាកដរបស់ខ្លួនពុំមែនទើបតែយកតាមគេទេ ហើយគេក៏ស់ណាល់អារ្យធម៌ដើមនោះ អ្នកប្រាជ្ញសព្វថ្ងៃទទួលស្គាល់គ្រប់គ្នា គេឲ្យឈ្មោះថាអារ្យធម៌អូស្ត្រូ-អាស៊ី (Austro-Asiatiques) ដែលមានកំណើតដើមនៅលើដែនដីនានា ជាកោះជាជ្រោយ នៅតាមសមុទ្រប៉ាស៊ីហ្វិក គឺភូមិភាគ

ស្រុកយើង; ត្រួយពីអារ្យធម៌ឥណ្ឌូ-អឺរ៉ុប (Indo-Européenes) ដែលមានកំណើតនៅឥណ្ឌានិងនៅអឺរ៉ុប ។

បើគេឃើញនូវកំណើត និងរូបរាងច្បាស់នៃអារ្យធម៌ខ្មែរយើងដែលប្រតិស្ឋានឡើងជាក់ប្រាកដលើដីយើងដូច្នោះហើយ យើងគង់តែតាមដានសង្កេតមើលថាតើ តាំងពីមានរូបរាងមករហូតសព្វថ្ងៃនេះ អស់រយៈវេលាជាងពីរពាន់ឆ្នាំមកហើយ មានការវិវត្តន៍យ៉ាងណាខ្លះ ។ យើងដឹងមកហើយថា ពិតមែនតែមានឥទ្ធិពលនៃអារ្យធម៌នានាជាតិជាពិសេសគឺជាតិដែលទាក់ទងនឹងខ្មែរយើងមែន, ប៉ុន្តែឥទ្ធិពលទាំងនោះរឹងរិតតែធ្វើជាមធ្យោបាយ ជួយរុញច្រានឲ្យអារ្យធម៌មានកំឡាំងនឹងមានរូបរាងបែកសាច់ឈាមពេញលេញបរិបូណ៌ឡើងទៅវិញ ។ ដូច្នោះយើងអាចចែកវិភាគនូវអារ្យធម៌យើងតាមបែបប្រវត្តិសាស្ត្រ ជាបីសម័យកាលធំៗ គឺ:

## ១ - អារ្យធម៌ខ្មែរសម័យអង្គរ

សម័យកាលដ៏ធំនេះ យើងរាប់តាំងពីចាប់ផ្ដើម មកទល់គ្នានឹងកាលខ្មែរលះបង់រាជធានីអង្គរ ក្នុងសតវត្សទី ១៤ នៃគ្រិស្តសករាជ ។ វេលានេះជាពេលកសាងឥតឈប់ឈរ ធៀបឧបមាបីដូចជាឈើដែលទើបតែដុះហើយលូតលាស់ជាលំដាប់រហូតទាល់បានជាទ្រង់ទ្រាយរុក្ខជាតិមួយ ធុនល្មម ។ ចាប់ពីមុនគ្រិស្តសករាជមកទល់គ្នានឹងសតវត្សទី ៧ អារ្យធម៌ខ្មែរពុំទាន់លេចឈ្មោះពេញទីនៅឡើយមែន ប៉ុន្តែបើមើលពីគ្រឿងដំណាល

ជាសក្ខីភាពគឺគង់ឃើញនៅសេសសល់ច្រើនណាស់ ដូចជាប្រាសាទថ្មតូចតាចនៅភូមិភាគអង្គរបុរី ។ ល្បែងប្រពៃណីផ្សេង ៗ និងភាសានិយាយស្តីជាដើម ។ លុះចាប់ពីសតវត្សទី ៨ មកស្ថាបត្យកម្មធំ ៗ របស់យើងកំលេចចេញ ៗ ឡើង របៀបរៀបចំស្រុកទេសក៏ចេះតែកើតជាលំដាប់ ៗ របបជីវភាព (Mode de vie) របស់ខ្មែរក៏ផ្លាស់ប្តូរទៅរកវិត្ថារភាពសមសួនដូចមានរូបចំឡាក់នៅជាប់នឹងជញ្ជាំងប្រាសាទអង្គរដំទុកជាដានស្រាប់ ៗ មែកធាងគ្រប់វិស័យ បានចំរើនឥតឧបមាៈស្មើ ៗ គ្នាហេតុបានទៅជាអារ្យ-ធម៌ជាតិខ្លាំងពូកែមួយនៅចុងបូព៌ាប្រទេសនេះ ។ អាស្រ័យហេតុនេះហើយ បានជានៅសម័យនេះ ជាតិថ្មីៗ នៅជិតខាងយើងបានចំឡងប្រឌិតយកបែបអារ្យធម៌យើងទៅធ្វើជាអារ្យធម៌ជាតិខ្លួនផង ។

## ២ – អារ្យធម៌ខ្មែរសម័យកណ្តាល

សម័យកាលនេះ យើងរាប់ពីសតវត្សទី ១៥ រហូតមកដល់ទី ១៩ នៃគ្រិស្តសករាជ ។ គ្រានេះប្រវត្តិសាស្ត្រប្រាប់យើងថា ស្រុកទេសកើតវឹកវរដោយសង្គ្រាមឧទ្ទានស្រុកមកពីបច្ចាមិត្រឯក្រៅ ៗ ផង និងមានសង្គ្រាមក្នុងស្រុករុកគួនខ្លះទៀតផង នាំឲ្យផ្លែផ្កាអារ្យធម៌ធ្លាក់ចុះត្រឡប់ទៅវិញ ។ កាលណាមានអាសន្នឬកោលាហលយ៉ាងនេះ ផ្លូវវប្បធម៌ក្តី ផ្លូវសង្គមធម៌ក្តី ដែលជាមែកធាងធំ ៗ នៃអារ្យធម៌យើងនោះ ក៏វិលត្រឡប់ជាស្ងប់ស្ងៀម គឺពុំបានលូតលាស់ឡើងថែមទៀតទេ និងថែម

តាំងចង់ថយក្រោយទៅវិញទៀតផង ដ្បិតអ្នកស្រុកអ្នកទេសគ្មានឱកាសនឹងកសាង ហើយបើសាងបានហើយ ក៏គ្មានលទ្ធភាពនឹងរក្សាគ្រងទុកឲ្យគង់វង់បាន ដោយសារតែការចលាចលបុករុកជារឿយ ៗ រីឯអ្នកទន្ទ្រានទឹកដីមកពីក្រៅសោត ក៏ព្យាយាមដឹកជញ្ជូនប្រមូលយកអារ្យធម៌យើងទៅ ហើយលួចបញ្ចូលអារ្យធម៌គេឲ្យស្រោចចូលមកផែនដីយើងទៀតផង ។ ហេតុនេះ យើងមិនត្រឹមតែលំបាកដោយរក្សាទ្រព្យមត៌កអារ្យធម៌ខ្លួនប៉ុណ្ណោះទេ ថែមទាំងពិបាកទប់ទល់នឹងកំឡាំងអារ្យធម៌ក្លាយរបស់គេ ចូលមកប្រៀតជ្រែកថែមទៀត ។ សង្ខេបទៅឃើញថាក្នុងសម័យកាលនេះ ជាពេលគ្រោះជាតគ្រោះដាំធ្លាក់មកលើអារ្យធម៌យើងក្នុងប្រវត្តិសាស្រ្ត ។

### ៣ - អារ្យធម៌ខ្មែរសម័យបច្ចុប្បន្ន

សម័យនេះយើងពុំបាច់រប់រៀបច្រើនទេ ព្រោះជាពេលដែលយើងគេបានឃើញបានយល់នឹងភ្នែកសព្វ ៗ ខ្លួនហើយ ។

ប៉ុន្តែគួរសង្កេតតែមួយចំណុច គឺត្រង់សម័យកាលនេះ មានចែកជាពីរភាគ គឺ សម័យអាណាព្យាបាលបារាំង និង សម័យឯករាជ្យ ។

សេចក្តីបរិយាយមកនេះ គ្រាន់តែឲ្យយើងរកឃើញថា ខ្មែរយើងពិតជាមានអារ្យធម៌មួយរបស់ខ្លួន និងមានតាំងប្រវត្តិច្បាស់លាស់ផង ពុំមែនដូចពាក្យស្មានខ្លះថា ខ្មែរចំឡង ឬ យកឫសគល់ពីអារ្យធម៌ណាមួយតាំងស្រុងនោះឡើយ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចា៉ង-ខាត់ រៀបរៀង*

(តមក)

---

អធិជនន នបុំ. កិរិយាកើត កំណើត ។

អធិជានុ ក្រិ.វិ. ដល់ក្បាលជង្គង់ ។

អធិជ្យ គុ. (ធ្នូ) ដែលមានខ្សែចងហើយ ។ – តា ស្រី. ការនៃធ្នូដែលមានខ្សែចងហើយ ។

អធិជ្យោតិមមិ ក្រិ.វិ. មានពន្លឺក្រៃលែង ។

អធិគត គុ ដែលគ្រប ដែលប្រក ។

អធិតល្បម៌ ក្រិ. វិ. ដល់កំពែង ដល់ប្រាការ ។

អធិត្យកា ខ្ពង់បព្វតា ។

អធិទណ្ឌនេតា បុំ. អ្នកកាន់នូវអាជ្ញាដ៏ក្រៃលែង យមៈ ។

អធិទីធិតិ គុ. ដែលផ្សាយពន្លឺក្រៃលែង ។

អធិទេវតា ស្រី. ទេវតាក្រៃលែង ទេវ នបុំ. ទេវតាក្រៃលែង, ទេវតមី តាមបង្គាប់អធិទេព ។

អធិទៃវត នបុំ. ទេវតាក្រៃលែង ទេវនិករ ។

អធិនាគមិ ក្រិ. វិ. លើឬពួងធំរី ឬ នាគធំក្រៃលែង

អធិនិវាសិ ក្រិ ស្វែះរកលំនៅ ។

អធិនិគមិ ក្រិ. វិ. រាល់យប់ ។

អធិប នុំ. អ្នកគ្រប់គ្រងក្រៃលែង គ្រូ នាយ ម្ចាស់ផែនដី ។ អធិបតិ

បុំ អធិបតី អធិបតិវតី គុ. ដែលមានគ្រូ ដែលមានចៅហ្វាយ ។

អធិបាណិ ក្រិ. វិ. ពួងដៃ ។

អធិបុរស្ត្រី ក្រិ. វិ. ចំពោះស្ត្រី ។

អធិបៅរុម នបុំ. សេចក្ដីក្លាហានក្រៃលែង ។

អធិប្រជមិ ក្រិ. វិ តាមកំណើត ។

អធិប្រាជ្ញមិ ក្រិ វិ ដោយអធិប្រាជ្ញា ។

អធិផាណិត គុ. ដែលមានផាណិតក្រៃលែង ដែលមានកើតអំពៅច្រើន ។

អធិពាធិ ក្រិ. បៀតបៀនក្រៃលែង ញាំញីក្រៃលែង ។

អធិភុជិ ក្រិ. បរិភោគក្រៃលែង ស៊ីច្រើន ។

អធិភូ បុំ. នាយ អ្នកគ្រប់គ្រង ។

អធិភូត នបុំ. សត្វក្រៃលែង ព្រះព្រហ្ម ។ ភូតម ក្រិ. វិ. ទាក់ទង

ដោយសត្វ ឬ ដោយវត្ថុ ។

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ ។
> យូរ-អ៊ុន

ទៀវយិមឮឡៀវពីនិយាយដូច្នោះក៏ខឹងណាស់ មិនបានខ្លាចដល់សេចក្ដីស្លាប់ ស្រែកគំហកថា ខ្លួនយើងជាជាតិទាហានមិនមានខ្លាចអន្តរាយស្លាយជីវិត គិតត្រឡប់ទៅចំណុះចុះចូលដល់អ្នកដទៃ ប្រាថ្នានឹងរក្សាជីវិតវិញ មិនស្រឡាញ់ស្រុកនោះក៏មិនគួរជាមនុស្សទៀងត្រង់នឹងនាយចៅហ្វាយ ធម្មតាជាតិទាហាន ហើយមកមាននាយចៅហ្វាយពីរនោះក៏មិនត្រូវតាមប្រពៃណី ធម្មតាស្រីដែលល្អក៏មិនត្រូវប្រាថ្នាស្វាមីដល់ ២ បើលោកនឹងបង្ខំឲ្យយើងចំណុះចុះចូលនោះ បើទុកទឹងពុំឈ្នះក៏ត្រូវតែគំនាប់ទៅ តែយើងនៅមិនមានចិត្តនឹងគិតកក្ដីមេត្រីដល់លោកទេ ហើយក៏ជេរឡៀវពីជាពាក្យទ្រគោះអសុរោះខ្លាំងណាស់ ខុងបេងឮដូច្នោះក៏ខឹងណាស់ បង្គាប់ឲ្យទាហាននាំខ្លួនទៀវយិមទៅប្រហារជីវិតបង់ ។

ឡៅពីឃើញថាខៀវយ៉ែម ជាមនុស្សត្រង់សុចរិតទីងនាយទៅហ្វាយ កំឲ្យមានចិត្តគិតសង្វេគ ទើបឲ្យនាំយកសពខៀវយ៉ែម ទៅបញ្ចុះទុកនៅទីដើមស្ពានតឹមឆ៉ីមកៀវ ព៉ា ហើយនាំឲ្យចារិកអក្សរដាក់នៅថ្មឆ្លាក់ទុកថា «ខៀវយ៉ែមជាមនុស្សត្រង់» ប្រាថ្នាទីងឲ្យមនុស្សទាំងពួងយកគួយ៉ាងតទៅមុខ ៗ

លុះព្រឹកឡើង ឡៅពីក៏ ឆាន់ខឹងងីអ៊ី នៅបណ្ដានាយទាហានកូនទាហានក្នុងស្រុកសែឈួន ដែលចូលមកនៅនឹងឡៅពីនោះ លើកទាហានជាកងមុខ ចូលទៅក្នុងស្រុកឡុកសៀ លុះទាហានលើកទៅដល់ដើងកំផែងហើយ ក៏ស្រែកហៅឡៅឈុមទីងឡៅកុយថា ការប្រទាល់គួដល់ប៉ុណ្ណោះហើយ កុំបរិងទទឹងតទៅទៀតឡើយ ចូរប្រញាប់បើកទ្វារចេញមកគំនាប់ឡៅពីដោយល្អទៅចុះ ទោះទីងខំមានះនៅក៏ឃើញថាទីងរក្សាការពារស្រុកនេះពុំបានទេ កុំឲ្យបានសេចក្ដីក្ដៅក្រហាយដល់អាណាប្រជានុរាស្ត្រទាំងពួងឡើយ ៗ

ឡៅកុយឈរនៅលើកំពែង បានឮសម្លេងស្រែកឡើងទៅដូច្នោះក៏ខឹងណាស់ ស្រែកតបមកវិញជាពាក្យទ្រគោះអសុរោះមិនមានគួរសមទីងចំណុះចុះចាញ់ ងៀមឆាំទឃើញឡៅកុយមានចិត្តព្រហើនកោងកាចដូច្នោះក៏ខឹងណាស់ ចាប់លំពែងទីងពួយឡើងទៅ ទទួលខៀវអេកកាត់ក្បាលឡៅកុយធ្លាក់ចុះមកឲ្យ ហើយក៏បើកទ្វារស្រុកចេញមក

ទទួលងៀមង៉ាន់ ៗ មានចិត្តត្រេកអរណាស់ ទើបនាំទាហានទាំងពួងចូលទៅក្នុងស្រុក ៗ

ឡៅឈុនឃើញទាហានឡៅពីចូលស្រទៅ ក៏ឲ្យបើកទ្វារទិសខាងកើតនាំទាហានស្រួតរត់ចេញទៅស្រុកសែឈួន លុះឡៅពីចូលទៅក្នុងស្រុកហើយក៏សួរថា នរណាមានសេចក្តីស្វាមីភក្តិនឹងយើង បានកាត់ក្បាលឡៅកុយទម្លាក់មកឲ្យនោះ ងៀមង៉ាន់ឆ្លើយថា ទៀវអេកនោះដែលមកគំនាប់លោក បានកាត់ក្បាលឡៅកុយទម្លាក់ប៉ោះមកឲ្យ ឡៅពីក៏ឲ្យបំណាច់រង្វាន់ដល់ទៀវអេកជាច្រើន ហើយក៏ចាត់តែងអ្នកស្រុកឲ្យនៅជាសុខមិនឲ្យទាហានណាទៅបៀតបៀនឲ្យកើតអន្តរាយ ៗ

ខុងបេងថា ឥឡូវស្រុកឡុកសៀបានមកយើងហើយ ឯស្រុកសែឈួនក៏ដូចជានៅក្នុងកណ្តាប់ដៃយើងដែរ បើយើងនឹងលើកទៅវាយយកវេលាណាក៏បាន តែអាណាខែត្រដែលត្រូវចំណុះស្រុកសែឈួននោះមិនទាន់ពបទាប សុំឲ្យលោកចាត់ទៀវអេកនឹងង៉ីអ៊ុំឲ្យនាំជួឡុងលើកទាហានទៅប្រាបប្រាមស្រុកតេងតាំង ឲ្យងៀមង៉ាន់នឹងគោអេងនាំទៀវហ៊ុយលើកទាហានទៅសង្កត់ស្រុកតេកយ៉ុង ដែលនៅរឹងទទឹងនោះឲ្យចុះចូលជាប្រក្រតី ចាត់តែងមុខមន្ត្រីឲ្យនៅរក្សាស្រុកតាមភូមិលំនៅស្រេចហើយ ទើបឲ្យលើកកងទ័ពទៅវាយយកស្រុកសែឈួនឲ្យព្រមគ្នា នាយទ័ពនាយកងទាំងពួង លុះបានទទួលការដែលខុងបេងចាត់តែងដូច្នេះហើយ ទាំង

អស់គ្នាក៏លើកទាហានចេញទៅ ។

ខុនបេងក៏សួរអ្នកស្រុកសៃឈួនថា យើងនឹងលើកទ័ពទៅវាយយកស្រុកសៃឈួនក្នុងគ្រានេះ តើតាមផ្លូវដែលនឹងលើកទៅនោះ មានគយបន្ទាយជាទីកំពង់ផ្លូវនៅប៉ុន្មានអន្លើ ពួកអ្នកស្រុកឆ្លើយដំកបថា មានគយកឹមកុកជាបន្ទាយធំមាំមួនណាស់នៅដំបន់នោះ មួយទៀត គយកឹមកុកនោះទាហានក៏ស្រុះស្រួល ទាំងខ្លាំងពូកែមានថ្វីដៃណាស់ បើវាយបានបន្ទាយនោះហើយ ក៏មិនមានទីដទៃទីងទទឹងទៀតបាន នឹងលើកទៅវាយយកស្រុកសៃឈួនបានដោយងាយណាស់ ។

ខុនបេងដឹងដូច្នោះ ក៏ឲ្យប្រុងប្រៀបរៀបទាហាន នឹងលើកទៅ ហួតេងថា ដែលលោកនឹងលើកទៅវាយយកស្រុកសៃឈួននោះ ខ្ញុំបាទយល់ឃើញថា អាណាប្រជាទុក្ខស្ត្រនឹងបានសេចក្ដីក្ដៅក្រហាយណាស់ សុំឲ្យលោកបង្អង់កងទ័ពទុកសិន ព្រោះស្រុកឡុកសៀក៏បានជារបស់លោកហើយ ស្រុកសៃឈួនដូចនៅក្នុងកណ្ដាប់ដៃលោកដែរ ខ្ញុំបាទនឹងមានសំបុត្រទៅដល់ឡៅជៀងមួយច្បាប់ឲ្យចេញមកចំណុះចុះចូលលោកតាមប្រពៃណី ឡៅជៀងដឹងថាស្រុកឡុកសៀនេះបានមកលោកហើយ គឺនឹងព្រមចំណុះមិនខាន បើជារឹងទទឹងប្រការម្ដេច សឹមយើងលើកទ័ពទៅវាយជាក្រោយ ខុនបេងយល់ត្រូវផង ទើបឲ្យបង្អង់កងទ័ពឈប់ ហើយឲ្យហួតេងមានសំបុត្រទៅដល់ឡៅជៀង ។

ឯឡៅឈុន លុះតែទៅដល់ស្រុកសែឈូនហើយ ក៏ពណ៌នាប្រាប់ហេតុដំណើរឲ្យបិតាស្តាប់គ្រប់ប្រការ ឡៅជៀងក៏ឲ្យប្រមូលមន្ត្រីខុំពងការចូលមកប្រឹក្សាថា ឥឡូវស្រុកឡុកសៀវខូចហើយ មុខជាឡៅពីនឹងលើកទ័ពចូលមកក្តាប់ដល់ស្រុកយើងឯណោះទៀតជាប្រាកដណាស់ យើងនឹងគិតការពារយ៉ាងណាឲ្យបានគង់ល្អតទៅ ។

តែគ ទីប្រឹក្សាឆ្លើយថា ឡៅពីបានស្រុកឡុកសៀវក៏មែន តែពួកទាហានសុទ្ធតែជាមនុស្សផ្តេសផ្តាស ព្រោះច្រើនតែពួកល្មើយ មិនបានជាចិត្តមួយនឹងជួយធ្វើការឲ្យអស់ពីចិត្តទេ នឹងធ្វើការក៏ពុំសូវព្រមព្រៀងគ្នា ហើយគិតតូចផង មិនធ្លូននឹងធ្វើសង្គ្រាមនឹងយើងបាន សុំឲ្យលោកជាត់មនុស្សចេញទៅបណ្តេញកៀរយកគាណាប្រជានុរាស្ត្រ ក្នុងស្រុកប៉ាសេ ទិសខាងឯលិច ឲ្យធ្ងន់ស៊ឹងប៉ោស៊ុយចូលមក នៅខាងក្រោយស្រុកយើងឲ្យអស់ ហើយឲ្យដុតបំផ្លាញស្បៀងអាហារដែលនាំយកមិនបាននៅសល់ប៉ុន្មាននោះឲ្យអស់កុំឲ្យទុក បើឡៅពីនឹងលើកទ័ពមកព័ទ្ធស្រុកយើង ស្បៀងអាហារក្នុងស្រុកយើងក៏មានច្រើនបរិបូណ៌ ត្រូវតែខំរក្សាស្រុកទុកឲ្យមាំ កុំឲ្យធ្វើវិនាសបាន ឯឡៅពីមកពីស្រុកឆ្ងាយ គង់នឹងអស់ស្បៀងអាហារ បើច្រាំនៅយូរតទៅយកស្រុកយើងមិនបាន អស់ផុតស្បៀងអាហារវេលាណា សេនាទាហានមានតែថយកម្លាំងចុះ ទោះនឹងធ្វើការក៏មិនពេញដៃ មុខជានឹងលើកទ័ពត្រឡប់ទៅឯង ទាហាន

យើងមានកម្លាំងស្រុះស្រួលគ្នា  ក៏នឹងលើកទ័ពយកស្រុកវិញខាងចុងដៃ  មុខជានឹងចាប់ឡាវពីបានដោយងាយ ៗ

ឡាវដៀងថា  ធម្មតាសត្រូវមកធ្វើអន្តរាយ  គួរនឹងរកឧបាយការពាររក្សាស្រុក ទុកកុំឲ្យអាណាប្រជានុរាស្ត្របានសេចក្តីក្តៅក្រហាយ នេះសត្រូវលើកមកមិនទាន់នឹងបានច្បាំងតកម្លាំងគ្នាឲ្យឃើញយ៉ាងណា ស្រាប់តែទៅកៀរយកគ្រួសារអ្នកស្រុក ឲ្យកើតទុក្ខព្រាត់ទីលំនៅ បានសេចក្តីក្តៅក្រហាយទទេ ៗ យើងគួរមិនយល់ឃើញផងសោះ  កាលឡាវដៀងកុំពុងប្រឹក្សាការនោះ  ទទួលអ៊ុយគួនយកសំបុត្រហ្លួតបេងចូលទៅឲ្យឡាវដៀង ១ ហែកស្រោមមើលឃើញសេចក្តីថា  ខ្ញុំបាទហ្លួតបេង សូមគំនាប់មកដល់លោកជ្រាប  ព្រោះពីដើមលោកមានចិត្តស្រឡាញ់ឡាវពីដោយសុចរិតមិនមានគិតវៀសពីអ្វីសោះ  បានជាប្រើខ្ញុំបាទឲ្យនាំទាហានទៅទទួលឡាវពីមកដល់ស្រុកសែឈូន  ប្រាថ្នានឹងឲ្យជួយផ្ចុបផ្ចួនការពាររក្សាស្រុកឲ្យមានសេចក្តីសុខតទៅ  ឥឡូវលោកមកជឿកាន់យកពាក្យសំដីមនុស្សញុះញង់  លោកក៏មិនបានស្ទង់ពិគ្រោះឲ្យហ្មត់ចត់  ទើបបានសេចក្តីព្រាត់ឃ្លាតមេត្រីឡាវពីទៅវិញ  ត្រឡប់បានសេចក្តីទោមនស្ស ជាទុក្ខម្នេញទៅជាសត្រូវនឹងគ្នា  ឯឡាវពីក៏បានធ្វើការធំលើសលប់មិនឈប់បង្អង់មកដល់ប៉ុណ្ណោះហើយ  មួយទៀតអាណាខេត្តឯទៀតក៏បំណុះចុះចូលទៅខាងឡាវពីអស់ហើយ  នៅឡើយតែត្រឹមស្រុកសែឈូនប៉ុណ្ណោះ

សូមឲ្យលោកត្រិះរិះគិតប្រែប្រួលសម្រួលតាមកាលៈទេសៈគួរនឹងចំណុះចុះ ចូលឡៅពីតាមប្រពៃណីទៅវិញស្រួលជាជាង ព្រោះឡៅពីជាមនុស្ស ប្រកបដោយស័ក្យពិតត្រង់ល្អណាស់ ហើយមានចិត្តនោះស្មោះសស្រឡាញ់អ្នកទាំងពួង គ្មានអាឃាតព្យាបាទនរណា បើលោកពិគ្រោះពិចារណាឃើញគួរនឹងការហើយ ក៏ឲ្យចេញមកគំនាប់តាមស្រួលទៅចុះ ដើម្បីនឹងបានសេចក្ដីសុខតទៅ ឡៅពីមិនមានចង់សត្រូវនឹងលោកជាប្រាដក ។

ឡៅជៀងមើលចប់សេចក្ដីក៏ខឹងណាស់ ល្មីសំបុត្រនោះចោលមួយរំពេច ហើយដេរថាអាចោរលក់ម្ចាស់ វាពោលមកយ៉ាងនេះ ប្រាថ្នានឹងយកប្រយោជន៍ចំពោះខ្លួនវា បង់កំឡាំង ដែលបានទំនុកបំរុងឲ្យវាមានយសសក្តិរៀងមក វាមិនយកចិត្តស្រឡាញ់ឯងដោយស្មោះត្រង់បង់សេចក្តីកតញ្ញូសោះ ហើយក៏បណ្ដេញអ្នកកាន់សំបុត្រនោះឲ្យថយចេញមួយរំពេច ទើបប្រើអ៊ុយហ៊ួនជាប្អូនករិយានឹងលីយៀមឲ្យលើកទាហាន ៣ ម៉ឺនទៅរក្សាគយកឹមកុកខុកឲ្យមាំមួន តាំងហោ ទីប្រឹក្សាក៏ចូលទៅនិយាយនឹងឡៅជៀងថា សុំឲ្យលោកមានសំបុត្រទៅដល់ទៀវឡេចៅហ្វាយស្រុកហ័នតុង សូមឲ្យលើកកងទ័ពមកជួយចុះ មុខជាតស៊ូនឹងឡៅពីបាន ឡៅជៀងថា ដែលអ្នកនឹងឲ្យទៅសុំកងទ័ពស្រុកហ័នតុងមកជួយនោះ ទៀវឡេនឹងយើងក៏ជាសត្រូវនឹងគ្នា កាលណាគេនឹងមកជួយ ។

តាំងហោថា ទោះបីទៀវឡូទាស់អធ្យាស្រ័យនឹងយើងយ៉ាងណា តែវេលានេះ ទ្យាពីធ្វើការធំលើសលុបខ្លាំងណាស់ បើបានស្រុកសៃឈួនវេលាណា ក៏គង់នឹងខ្ទ្រួនទៅយកស្រុកហ៍នតុងទៀតជាប្រាកដ ព្រោះស្រុកសៃឈួនដូចនៅត្រង់រីមបបូរមាត់ ស្រុកហ៍នតុងឧបមាដូចធ្មេញ បើបបូរមាត់ភ្ញាក់ប្រហាទៅហើយ មិនលែងឡើយនឹងឃើញធ្មេញនោះ ព្រោះនៅជិតគ្នាណាស់ សូមឲ្យលោកមានសំបុត្រទៅនិយាយចុះថា ទ្យាពីវេលានេះធ្វើការមានកម្លាំងជិតពេញផែនដីទៅហើយ សុំឲ្យទៀវឡូរិះគិតជួយទៅវិញទៅមកកុំឲ្យអន្តរាយស្រុកទាំងសងខាង ទៀវឡូក៏គង់នឹងគិតខ្លាចមិនអាចបង្អង់ឈប់ទេ យូរធាប់ក៏គង់នឹងលើកពលរេហ៍មកជួយលោកទេ ទ្យាជៀងយល់ឃើញត្រូវផង ក៏តែងសំបុត្របាត់បំរើឲ្យកាន់ទៅដល់ទៀវឡូ ។

---

## សាមគុកខ្សែ ៥៤

តាំងពីម៉ាឈៀវបែកទ័ពរត់ពីចូចូទៅ ។ នៅស្រុកធៀងក្រៅស្រុកចិន ហើយវិលមកវាយស្រុកតីដីវ រហូតដល់គួនអ៊ូ បានបំរើទៅសុំឡៅពីតស៊ូនឹងម៉ាឈៀវ ខុងបេងមានសំបុត្រទៅឃាត់គួនអ៊ូ ។ ក៏ឈប់ខានមិនបានចូលទៅដល់ឡៅពី ។

ឯម៉ាឈៀវកាលបែកទ័ពតែពីចូចូ ទៅពីខ្មែរអ៊ុយហោ គ្រានោះ ក៏ទៅនៅស្រុកធៀវក្រៅដែនស្រុកចិនបានប្រហែល ៣ ខែ ក៏បញ្ចុះបញ្ចូលទាហានបានជាច្រើន ក៏ទៅវាយយកអាណាខែត្រដំបន់ដែលចំណុះចូចូបានជាច្រើនអន្លើ ហើយក៏លើកទៅវាយយកស្រុកគីជីវ អ៊ុយខង់ហៅហ្វាយស្រុកគីជីវឲ្យសំបុត្រទៅដល់ហែហ្ញ៉ូអៀនឲ្យលើកទៅជួយ ហែហ្ញ៉ូអៀនក៏ព្រងើយកន្តើយមិនសូវយកចិត្តទុកដាក់ មិនបានឲ្យដំណឹងទៅដល់ចូចូ ៗ មិនបានលើកទ័ពទៅជួយអ៊ុយខង់សោះ អ៊ុយខង់ចេះតែរង់ចាំកងទ័ពហែហ្ញ៉ូអៀនជាយូរថ្ងៃណាស់ មិនឃើញលើកទៅសោះ កងទ័ពម៉ាឈៀវក៏លើកព័ទ្ធស្រុក អ៊ុយខង់គិតនឹងលើកទ័ពចេញទៅចំណុះចុះចូលម៉ាឈៀវ ។

ពេលនោះអៀវហ្ញ៉ូនាយទាហានក៏ចូលទៅស្រែកឃាត់ ហាមថាដែលនឹងលើកចេញទៅចំណុះចុះចូលម៉ាឈៀវតែម្តងនោះ ខ្ញុំមិនពេញចិត្តសោះ ព្រោះម៉ាឈៀវនោះជាមនុស្សអកតញ្ញូ នឹងចៅហ្វាយនាយមិនមានសុចរិតពិតត្រង់សោះ ត្រូវការអ៊ុំនឹងចេញទៅចំណុះ បើខុសក៏ស៊ូតែស្លាប់ក្នុងស្រុកតែម្តងទៅជាជាង អ៊ុយខង់ថា ឥឡូវបើការបុប្ផ-ជួនពាល់ត្លួមកដល់ប៉ុណ្ណេះហើយ អ្នកឯងនឹងមកឃាត់ហាមយើងមិនឲ្យចេញទៅចំណុះចុះចូលគេធ្វើម្តេចបាន អ៊ុយខង់មិនស្តាប់ក៏បើកទ្វារស្រុកចេញទៅទទួលម៉ាឈៀវ ឲ្យចូលទៅក្នុងស្រុកហើយគំនាប់តាម

ប្រពៃណី ម៉ាឈៀវទៅដល់ស្រុកគីជីវហើយថា អ្នកឯងបើកទ្វារទទួល គំនាប់យើងគ្រានេះ នឹងបានចំណុះចុះចូល ក មសុភាពសុចរិតពិតត្រង់ក៏ទេ ហេតុពីព្រោះអាល់ប្រកនឹងរកទីពៀសវាងពុំបាន ហើយបានជាធ្វើដូច្នេះ បើអ្នកឯងស្មោះស្ម័គ្រភក្តីនឹងយើងក៏គួរធ្វើតាមដើមដំបូង តាមស្រួលទៅចុះ នេះពុំមែនធ្វើតាមអំពើសុចរិតពិតត្រង់ យូរទៅក៏គង់នឹងគិតប្រទូសរ៉ាយយើងវិញ យើងនឹងជឿទុកចិត្តក៏មិនបាន ថាហើយក៏បង្គាប់អាហារ ឲ្យនាំយកខ្លួនអ៊ុយខងនឹងគ្រប់គ្រួទៅប្រហារជីវិតទាំងអស់ អា-ហារទាំងពួងក៏ជំរាបថា អៀវហ៊្វូនេះក៏ជាអាហារអ៊ុយខង កាលដើម អ៊ុយខង នឹងចង់ចេញមកគំនាប់លោកនោះ អៀវហ៊្វូឃាត់ហាមទទឹងនឹងចិត្តលោក គឺគ្មានចិត្តភក្តីនឹងលោកសោះ សុំឲ្យលោកយកអៀវហ៊្វូទៅសម្លាប់ចេញ ម៉ាឈៀវថា អៀវហ៊្វូទទឹងតាស់ដូច្នោះជាប្រពៃណី ព្រោះជាមនុស្សទៀងត្រង់នឹងសម្លាប់ចេញពុំគួរ គួរតាំងអៀវហ៊្វូឲ្យជានាហ្មឺនធំនៅរក្សាស្រុកគីជីវ អៀវហ៊្វូគំនាប់ហើយថា ឥឡូវករិយាខ្ញុំបាទស្លាប់ឯស្រុកលិមអៀ នឹងសុំលាលោកទៅតែងការសពមួយខែពីរខែសិន បើស្រេចការហើយ ខ្ញុំបាទនឹងត្រឡប់វិលមករកលោកវិញ ម៉ាឈៀវក៏ព្រមអនុញ្ញាតឲ្យអៀវហ៊្វូទៅ អៀវហ៊្វូលាម៉ាឈៀវទៅដល់ស្រុកឡិកសេវែផលកៀវយឺមជាកូនរបស់មារក្សាខែត្រនៅនោះ ក៏ត្រង់ចូលទៅគេមាគាកៀវយឺម គំនាប់ហើយក៏យំសោកថា ខ្លួនខ្ញុំបាទទៅនៅធ្វើកជការជា

មួយនឹងអ៊ុយខងឯស្រុកតីជីវ មិនបានការពារក្សានាយចៅហ្វាយរបស់ខ្លួនឲ្យផុតសេចក្តីអន្តរាយ ទទួលម៉ាឈៀវកាសត្រូវផែនដីមកសម្លាប់អ៊ុយខងទៅ ខ្ញុំបាទមិនដឹងបើនឹងគិតម្តេច ព្រោះខ្មាសមុខមិនដឹងនឹងយកទៅទុកឯណាបានឡើយ បានសេចក្តីអប្បយសដល់បណ្តាជនអ្នកស្រុកទាំងពួងខ្លាំងណាស់ ព្រោះធ្វើមនុស្សក្សានាយចៅហ្វាយមិនបាន ឥឡូវអាណាប្រជារាស្ត្រនិស្រុកតីជីវក៏ក្តៅក្រហាយឈឺចិត្តតែគ្រប់គ្នា គិតនឹងប្រទូសរ៉ាយម៉ាឈៀវវិញឲ្យបាន ហេតុអ្វីបងខ្ញុំបានធ្វើដល់ចៅហ្វាយស្រុកខ្សុកសេ មិនបានចាត់ចែងទាហានលើកទៅជួយកំចាត់ សត្រូវចេញចំនៅសៀមទៅបាន មិនមានឈឺចិត្តសោះឡើយ ។

មានតាគៀវឃឹមជាចាស់មានអាយុ ៨២ ឆ្នាំដូច្នេះក៏ឲ្យហៅខ្លួន គៀវឃឹមមកប្រាប់ថា ឥឡូវស្រុកតីជីវ មានទ័ពម៉ាឈៀវលើកទៅប្រទូសរ៉ាយអ៊ុយខងក្ស័យជីវិតទៅហើយ ចៅក៏នៅព្រងើយមិនលើកទាហានទៅជួយទាល់តែអន្តរាយស្រុកបានទៅគេអស់ ទោសកំហុសក៏នឹងមានមកចំពោះខ្លួនចៅជាមិនខាន បើដឹងការនេះទៅដល់ចូវវេលាណា ក៏នឹងយកទោសវេលានោះ ហើយនិយាយនឹងអៀវហ៊ួថា ខ្លួនចៅខាងនេះបានទទួលគំនាប់ជាប់ប្តេជ្ញានឹងម៉ាឈៀវ ៗ ក៏ជឿចិត្តឥតពិគល់លើកដំកើងខ្លួនឲ្យធ្វើនាម៉ឺនបានស៊ីបៀវត្សរ៍គេហើយ ហេតុម្តេចក៏គេចមកគិតមិត្រទ្រុស្តនឹងគេវិញ ទៅជាមនុស្សអកតញ្ញូនិគុណគេទៅទៀត ។

អៀវហ៊ួឆ្លើយថា ដែលខ្ញុំបាទបំណុះចុះចូលម៉ាឈៀវនោះមិនមែន

ជាការសុចរិតប្រាកដទេ ប្រាថ្នាគ្រាន់តែដោះជីវិតខ្លួនប៉ុណ្ណោះ ដើម្បីទិន អនុគ្រោះដល់អ្នកស្រុក បានជាប្រែមុខមកដល់នេះ ព្រោះនឹងគិតធ្វើការសងសឹកវិញឲ្យបាន កៀវឃឹមថា ម៉ាឈៀវនោះមានថ្វីដៃខ្លាំងពូកែណាស់ ដែលនឹងគិតកំចាត់បេញក៏កម្រ អៀវហ៊្វីថា ទោះបីថ្វីដៃវាខ្លាំងពូកែក៏មែន តែមិនបានជាមនុស្សមានសតិបញ្ញាដែលនឹងយល់ការពក់ជ្រៅក្នុងផ្លូវសង្គ្រាមប៉ុន្មានទេ ប្រសិនបើលោកនឹងគិតកំចាត់បេញក៏គង់បាន កាលខ្ញុំបាននឹងមកនោះ ក៏បានណាត់ការទុកនឹងឡេងខ្វាន់ ទៀវហេង បើបងនឹងលើកទាហានទៅកំចាត់ម៉ាឈៀវវេលាណា អ្នកទាំងពីរក៏នឹងទទួលជាកលសឹក ចាត់ការក្នុងស្រុកស្រាប់ហើយ ។

មាតាកៀវឃឹមថា បើដូច្នោះចូរទៅគិតកំចាត់បេញឲ្យឆាប់ចុះ បើលុះទុកឲ្យយូរទៅ គេក៏មានគំនិតគិតឃើញការម្យ៉ាង ៗ ឃើងក៏ធ្វើគេពុំបាន មានសេចក្ដីលំបាក ធម្មតាកើតមកជាមនុស្សពលគ្នា នរណា ៗ ក៏ត្រូវតែស្លាប់ម្ដងម្នាក់ដូចគ្នា បើទៅនឹងធ្វើសង្គ្រាមហើយ មិនត្រូវគិតខ្លាចសេចក្ដីស្លាប់នោះឡើយ ។ មួយទៀតក៏មិនត្រូវគិតអាល័យភមុខកក្រោយដល់ម្ដាយនេះឡើយ បើថាព្រួយវិតក្កដល់ម៉ែហើយ ម៉ែក៏នឹងស្លាប់ឲ្យហើយរួចសឹមទៅចុះ ម្ដាយគិតនេះគឺកុំឲ្យព្រួយរវល់ដល់ទៅ កៀវឃឹម ៗ ឮមាតាថា ក៏ចាត់ឲ្យទៀវតាំងចាត់ចែងទាហានត្រៀមទុកព្រម រួចលើកទៅជាមួយនឹងអៀវហ៊្វី ។

ម៉ាឈៀវលុះដឹងថា អៀវហួទៅប្រាប់កៀវឃឹមឲ្យលើកទ័ពមកទីង ធ្វើអន្តរាយដល់ខ្លួនដូច្នោះក៏ខឹងខ្លាំងណាស់ តាំងតែលើកទាហានចេញពីស្រុកតីដីវទៅជាមួយបាំងតេកទីងម៉ាតាយ ប្រាថ្នាទីងចាំរង់ទ័ពកៀវឃឹម លុះកៀវឃឹមលើកទាហានទៅដល់កណ្តាលផ្លូវ ក៏ប្រទះគ្នានឹងទ័ពម៉ាឈៀវ ទើបបរសេះចេញទៅបញ្ឈរនៅមុខទាហានតាំងពួងហើយស្រែកថា អាសត្រូវផែនដី ឯងបើចង់តស៊ូនឹងអញក៏ចូលមកចុះ ម៉ាឈៀវខឹងលើសកម្លាំង តាំងតែបពោលចូលវាយប្រកាប់ជាប់ដៃគ្នា សម្លាប់ទាហានកៀវឃឹមស្លាប់ច្រើនណាស់ កៀវឃឹម អៀវហ្ពួតស៊ូមិនបាន ក៏បំបាយសេះរត់ ម៉ាឈៀវបានទំនងក៏ចេញតាមទៅ ទៀវតាំងទាហានកៀវឃឹមឃើញដូច្នោះ ក៏លើកទាហានស្ទាក់ព័ទ្ធពីក្រោយ កៀវឃឹមក្រឡេកមកឃើញក៏ត្រឡប់មុខមកតវិញ ម៉ាឈៀវក៏នៅកណ្តាលចំណោមទ័ព ចេះតែកប់រងការពារខ្លួនទៅវិញទៅមក ។

ខទួលហៃហ៊ួអៀន លើកកងទ័ពស្រួចចូលមកប្រសព្វគ្នា ក៏ដេញទាហានឲ្យចូលប្រកាប់ប្រហាក់ជួយកៀវឃឹម ទាហានតាំង ៣ កងក៏ចូលប្រយុទ្ធព័ទ្ធជុំវិញខ្លួនម៉ាឈៀវ ៗ លើសកំឡាំងនឹងតស៊ូពុំឈ្នះ ក៏ស្ទុះបំពារទំលាយរត់ទៅ ដល់ក្លោស្រោង លុមដល់ទៅស្រុកតីដីវក៏ហៅឲ្យបើកទ្វារទទួល ទៀវហោង ឡេងខ្វាន់ ដែលនៅក្នុងស្រុកនោះ មិនឲ្យបើកទ្វារទទួល តាំងតែឡើងលើកំផែង ហើយឲ្យទាហានបាញ់ធ្នូចម្រុះចុះមក

ហើយស្រែកជេរម៉ាឈៀវមិនដាច់ពាក្យសោះ រួចក៏យកបុត្រភរិយាទាំង ស៊័គ្រប់ក្រួកកាត់ក្បាលទម្លាក់ចុះមក ចំពោះមុខម៉ាឈៀវៗ ឃើញដូច្នោះក៏ឈឺចួលឆេះក្នុងចិត្ត ហាក់បីដូចភ្លើងគរលើដើមទ្រូង ធ្លាក់ពុះពីលើសេះដល់ ៣ ដង ៤ ដង មិនដឹងដែលទឹងធ្វើប្រការម្ដេច ។

ខណៈនោះហៃហ៊្លួអៀន យុំទាហានលើកទ័ពតាមមកទាន់ម៉ាឈៀវៗ ទាហានតិចណាស់ ក៏វាយទម្លាយស្លុះរត់ទៅ ទទួលប្រទះនឹងកងទ័ពកៀវឃីមនឹងអៀវហ៊្លួស្នាក់នៅពីមុខ ម៉ាឈៀវបរសេះពុះពារទំលាយទាហានទាំងឡាយចេញទៅផុតអស់ ទៀវតាំងក៏លើកជូនថែមទៅជាក្រោយ ក៏ហោមព័ទ្ធម៉ាឈៀវជុំវិញ កាប់សម្លាប់ទាហានស្លាប់ជេរជាស ម៉ាឈៀវម៉ាកាយ ទាំង បាំងគេក ឃើញទាហានសល់នៅប្រហែល ៥០ នាក់ ក៏បរសេះគេចនាំទាហានទាំងនោះស្លុះរត់ចេញរួចទៅ តាំងពីថ្ងៃលុះយប់ទៅដល់ស្រុកឡូកសេ ដើរទៅដល់ក្បែរកំផែង ទាហានក្នុងស្រុកឡូកសេមិនបានសង្កេតព្រោះយប់ងងឹតណាស់ សំគាល់ថា កៀវឃីមទៅហាយស្រុក លើកត្រឡប់ទៅវិញក៏បើកទ្វារទទួល ម៉ាឈៀវក៏នាំទាហានកន្ទ្រង់ចូលទៅក្នុងស្រុកបាន ហើយដេញកាប់សម្លាប់អ្នកស្រុកស្លាប់ជាច្រើនណាស់ រួចចូលទៅចាប់យកម្ដាយកៀវឃីមមកក្រៅផ្ទះ មាតាកៀវឃីមមិនខ្លាចសេចក្ដីស្លាប់ ចង្អុលមុខជេរម៉ាឈៀវថា អាសត្រូវផែនដី អាឯងសម្លាប់អញជាស្រីក៏តាមចិត្តចុះ ម៉ាឈៀវខឹងណាស់ ក៏យកគ្រប៊ី

កាប់មាត់កៀវឃឹមស្លាប់ លុះព្រឹកឡើងហៃហ៊្វអៀនដឹងដំណឹងក៏លើកទាហានដិតតាមមកទៀត ម៉ាឈៀវរត់ចេញពីស្រុកឡុកសេទៅ ក៏ជួបប្រទះនឹងអៀវហ៊្វលើកទាហានតាមមកក្រោយទៀត ម៉ាឈៀវក៏បរសេះចូលប្រយុទ្ធនឹងអៀវហ៊្វ កាប់សម្លាប់ទាហានអៀវហ៊្វស្លាប់ច្រើនណាស់ អៀវហ៊្វត្រូវលំពែងពិការធ្ងន់ពន់ប្រមាណក៏មិនបានរត់ចូលតស៊ូនឹងម៉ាឈៀវជាសាហ័ស ទទួលហៃហ៊្វអៀនលើកត្រឡប់តាមមកពីក្រោយជួយអៀវហ៊្វ ម៉ាឈៀវក្រឡេកឃើញទាហានខ្លួនសល់តែ ៧ នាក់ ក៏នាំបាំងតេក ម៉ាតាយនូវទាហានទាំងនោះគេចទៅ ។

ហៃហ៊្វអៀន បានកំចាត់ម៉ាឈៀវ បែករត់ទៅហើយ ក៏លើកទាហានទៅច្រាបច្រាមអាណាខេត្ត ឡុកសេបានរាបទាបជាប្រក្រតីគ្រប់ដំបន់ តាំងឲ្យកៀវឃឹម នៅរក្សាស្រុកនោះដូចដើម ទើបនាំយកអៀវហ៊្វដែលត្រូវរបួស ឡើងរទេះត្រឡប់ទៅក្រុងហ៊ូតោ ប្តឹងការឲ្យចូចូជ្រាបគ្រប់ប្រការ ។ ចូចូក៏មានសេចក្តីត្រេកអរណាស់ ទើបតាំងឲ្យអៀវហ៊្វជានាហ្មឺនធំ ។

ខណៈកាលម៉ាឈៀវបែកទៅនោះ ក៏ប្រឹក្សាគ្នានឹងបាំងតេក ម៉ាតាយថា ឥឡូវនេះ យើងនឹងរកទីអាស្រ័យមិនបានឡើយ នឹងទៅពឹងពាក់លើស្រុកទិសឯកើតនឹងឯលិច គឺស៊ីងជាដែនដំបន់របស់ចូចូទាំងអស់ យើងនឹងនាំគ្នាទៅប្រស្រ័យនៅនឹងទៀវឡូឯស្រុកហ័នតុងចុះ លុះប្រឹក្សាគ្នា

ហើយ ម៉ាឈៀវប៉ាំងគេក និង ម៉ាកាយ ក៏នាំទាហាន ៤ នាក់ចូលទៅនៅក្នុងស្រុកហ៊ានតុងជាមួយនឹងខៀវឡុ ៗ ក៏ទទួលរាប់អានស្រឡាញ់ពេញចិត្តណាស់ ទើបនិយាយនឹងទីប្រឹក្សាទាំងពួងថា ឥឡូវ ម៉ាឈៀវមកនៅនឹងយើងហើយ ដែលយើងនឹងគិតធ្វើការទៅខាងមុខនោះឃើញថាស្រួលណាស់ ខាងទិសឯកើតក៏នឹងបានតស៊ូបច្ច ខាងទិសឯលិចក៏នឹងគិតយកស្រុកសែឈួន គ្រានោះសត្រូវដែលមានខ្លួនក៏នឹងកោតក្រែងវែងខ្លាច ព្រោះម៉ាឈៀវមានអំណាចខ្លាំងពូកែមកជាកម្លាំងយើងហើយគួរតែយើងនឹងលើកកូនក្រមុំយើងឲ្យយកគ្នាជាស្វាមីភរិយា នៅនឹងគ្នាតាមប្រវេណី ។

អៀវប៉េកហាមឃាត់ថា ដែលលោកនឹងលើកបុត្រីឲ្យជាភរិយាម៉ាឈៀវនោះ ខ្ញុំបាទមិនពេញចិត្តសោះ ព្រោះម៉ាឈៀវនោះអកត្តញ្ញូនឹងរក្សាតែបុត្រភរិយារបស់ខ្លួន ក៏មិនគង់មួងទៅហើយ វេលានេះ បើលោកលើកបុត្រីឲ្យទៀត តទៅមុខក៏គង់នឹងរក្សាបុត្រលោកពុំបានដូចគ្នា គង់នឹងលះបង់ឲ្យអន្តរាយជាប្រាកដពុំខាន សូមឲ្យលោករិះគិតអានសិន ៗ ខៀវឡុយល់ឃើញត្រូវ ក៏មិនបានលើកកូនក្រមុំឲ្យម៉ាឈៀវវិញ ម៉ា-ឈៀវដឹងថា អៀវប៉េកឃាត់ខាំងរាំងរាដូច្នោះក៏តាស់តូចចិត្តខ្លាំងណាស់គិតខឹងនឹងអៀវប៉េកមិនរសាយ គិតនឹងប្រទូសរាយឲ្យបានវិញ ៗ អៀវប៉េកដឹងខ្លួន ក៏ប្រឹក្សានឹងអៀវសុងជាបងថានឹងជួយកំចាត់ម៉ាឈៀវចេញ ។

ឯអ៊ុយគួនដែលកាន់សំបុត្រមកពីស្រុកសែឈួននោះ លុះទៅដល់ហើយក៏យកសំបុត្រនោះទៅជូនទៀវឡូ ៗ បានទទួលមើលឃើញសេចក្ដី-ថា ឡៅជៀនដំកបមកទៀវឡូបានជ្រាប ដ្បិតឥឡូវនេះឡៅពីលើកទព័មកធ្វើអន្តរាយដល់ស្រុកសែឈួនហើយ គិតប្រឹងនឹងធ្វើការឲ្យទូលំទូលាយតទៅទៀត ឯស្រុកសែឈួននឹងស្រុកហ័នតុងនោះ ក៏ទបមាបីដូចបបូរមាត់នឹងធ្មេញគ្នាជិតណាស់ បើឡៅពីវាយបានស្រុកសែឈួនហើយក៏គង់នឹងកលដាលមកវាយយកស្រុកហ័នតុងមិនបង្អង់ខានទេ អាណាប្រឌុកស្ត្រទាំងពួងក៏នឹងបានសេចក្ដីក្ដៅក្រហាយ ការនេះសូមឲ្យអ្នកជួយលើកទាហានទាំងឡាយទៅជួយកំចាត់ឡៅពីចេញ បើសម្រេចបានការហើយ ខ្ញុំនឹងលើកអាណាខេត្តឲ្យអ្នក ២០ ដំបន់ ៗ ទៀវឡូឃើញសំបុត្រដូច្នោះក៏មានអំណរណាស់ ព្រោះចង់បានអាណាខេត្តសែឈួនក៏ទទួលពាក្យនឹងអ៊ុយគួនថានឹងលើកកងទ័ពទៅជួយ ៗ

# រឿងល្បើកឡាហ្វុងតែន

លោក ដេង-ជ្រីវ ប្រែរៀបរៀង

(តមក)

## ៣៦ កិច្ចប្រឹក្សានៃសត្វកណ្ដុរ

មានឆ្មាមួយឈ្មោះ «រូឌីឡារឌុះ» តែងតែចាប់កណ្ដុរទាំងឡាយ ជាចំណីស្ទើរនឹងពាយអស់ ៗ កណ្ដុរខ្លះដែលនៅសល់ ខ្លាចមិនហ៊ានចេញពីរន្ធ ម្ល៉ោះហើយរកចំណីចំអែតកាយ បានតិចតួចពន់ពេក ហើយ «រូឌីឡារ» កាលណាទៅរកកណ្ដុរមិនមែនដូចឆ្មាទេ ហាក់ដូចជាព្រាយបិសាចតែម្ដង ៗ

ថ្ងៃមួយ អាដើងខិលទៅរកញីឯលើដំបូលផ្ទះ ហើយក្នុងពេលដែលវាកំពុងប្រតិបត្តិជាមួយញីវាប្រកបដោយសម្រែកដ៏ខ្លាំង ពួកកណ្ដុរដែលនៅសល់ នាំគ្នាធ្វើសន្និបាតត្រង់កៀនមួយ ស្ដីពីការចាំបាច់បច្ចុប្បន្នៗ

ជំបូងព្រឹទ្ធបុរស (កណ្ដុរចាស់) ជាអ្នកមានការប្រុងប្រយ័ត្នជាងគេ បញ្ចេញយោបល់ថា ត្រូវតែយកចង្រ្កង់ទៅចងករូឌីឡាកុំបង្អង់យូរ ធ្វើដូច្នេះ កាលណាឆ្មារូឌីឡារមករកស៊ីកណ្ដុរ ៗ អាចរត់ពួនទៅក្នុងអ្វី ៗ ទាន់ ព្រោះវាដើរមកឮសូរចង្រ្កង់ជាដំណឹង គឺមានតែមធ្យោបាយមួយនេះឯង ៗ

កណ្ដុរទាំងអស់ក៏យល់ស្របតាមលោកព្រឹទ្ធបុរសកណ្ដុរ គឺថាគ្មាន

មធ្យោបាយអ្វីដទៃដែលស្រោចស្រង់កណ្ដុរឲ្យប្រសើរជាងនេះទេ ។ ការលំបាកនៅត្រង់យកចង្រ្កឹងទៅចងកឆ្មា ។ អាមួយនិយាយថា ខ្ញុំមិនហ៊ានទៅសោះទេ ខ្ញុំមិនឆ្កួតទេ អាមួយទៀតពោលថា ខ្ញុំមិនមានសមត្ថភាពសោះ ។ អាមួយថាដូច្នេះ អាមួយថាដូច្នោះ រកធ្វើអ្វីមិនកើត ទាល់តែនាំគ្នាបំបែកផ្លូវទៅ ។

គេគិតតែពាក្យ មហាសន្និបាតមានទីប្រឹក្សាច្រើនលើសលុប តែលុះត្រាការអនុវត្ត គ្មានអ្នកណាម្នាក់ចេញមុខ ។

## ៧៧– សត្វប្រចៀវនិងកង្ហែនពីរ

ប្រចៀវមួយហើរទៅជ្រកនឹងសំបុកសត្វកង្ហែន លុះអាស្រ័យនៅយ៉ាងនេះហើយ កង្ហែនដែលជាសត្រូវនឹងកណ្ដុរមកយូរនោះ កាលបើឃើញដូច្នោះ ក៏ស្ទុះមកប្រុងនឹងសម្លាប់ ។

កង្ហែនពោលថា ម្ដេចក៏អ្នកឯងហ៊ានមកនៅនឹងមុខខ្ញុំ ព្រោះពួកអ្នកឯងនេះ បានរកឱកាសតែនឹងបំផ្លាញខ្ញុំទេតើ ! ក្រែងអ្នកឯងជាកណ្ដុរឬ ? ចូរប្រាប់មកឲ្យត្រង់ កុំកុហក ។ ប្រាកដមែន អ្នកឯងជាកណ្ដុរពិតឬមួយខ្ញុំមិនមែនជាកង្ហែន ! ។

ប្រចៀវអង្វរថា : សូមអ្នកអភ័យទោសដល់ខ្ញុំផង សំដីនេះ ខ្ញុំពុំព្រមទទួលតាមទេ ខ្ញុំពុំមែនជាកណ្ដុរសោះ ! មនុស្សចិត្តអាក្រក់ចេះតែយកដំណឹងខុសនេះមកប្រាប់អ្នក ដោយសារអ្នកនិពន្ធកងលោក ។

ខ្ញុំជាបក្សីទេតើ អ្នកមិនមើលស្គាល់ខ្ញុំ! ជយោពួកសត្វហើរ !

យោបល់ប្រចៀវគួរជាទីគាប់ចិត្ត ហើយហាក់ដូចជាត្រូវផង ។ ប្រចៀវចេះតែសំងួន ទាល់តែកន្ធែនបើកឲ្យមានសេរីភាពអាចដកខ្លួនចេញបាន ។

ពីរថ្ងៃក្រោយមក សត្វប្រចៀវល្ងីល្ងើនេះ ដោយស្រវាំងភ្នែក ក៏ហើរទៅជ្រកនឹងសំបុកសត្វកន្ធែនមួយដទៃទៀត ដែលជាសត្រូវនឹងសត្វបក្សី វាត្រូវទទួលគ្រោះភ័យដល់អស់ជីវិត ជាថ្មីម្ដងទៀត ។

សត្វកន្ធែនម្ចាស់សំបុក ក្ដោងប្រមុះវែង ស្ទុះទៅបំរុងនឹងខាំប្រចៀវ ក្នុងឋានៈជាសត្វស្លាប ពេលនោះប្រចៀវក៏ថា កន្ធែនប្រមាថមើលងាយណ៎ះ អីខ្ញុំជាសត្វស្លាប ! ចូរអ្នកសំឡឹងមើលខ្ញុំឲ្យច្បាស់ តើខ្ញុំពិតជាសត្វស្លាបមែនឬ? សត្វបក្សីគេសំគាល់ត្រង់ស្លាប ខ្ញុំជាកណ្ដុរទេតើ ! ជយោ កណ្ដុរទាំងឡាយ ! ឃើញឬទេ ព្រះបង្កើតសត្វឆ្នាឲ្យប្រឡំគ្នាដែរ ។

ប្រចៀវរួចរស់ជីវិតពីរលើក ព្រោះតែការឆ្លើយដោះដងវាងវៃនេះ ។

## ៣៨- កង្កែបសុំស្ដេចមួយព្រះអង្គ

ដោយនឿយហត់នឹងសភាពប្រជាធិបតេយ្យ កង្កែបទាំងឡាយស្រែកសុំចំពោះព្រះ ឲ្យព្រះអង្គផ្ញើខ្លួន ឲ្យតាំងនៅក្រោមអំណាចរាជាធិបតេយ្យវិញ ។ ព្រះក៏ទម្លាក់ស្ដេចមួយព្រះអង្គ យ៉ាងស្លូតបូតពីលើមេឃ

ប្រមាទដល់កន្ទែប ៖ តែស្តេចព្រះអង្គនេះ ក្នុងពេលដែលធ្លាក់មក លាន់ឮសូរអស្ចារ្យ ទាល់តែពួកកន្ទែបជាសត្វល្ងីល្ងើហើយខ្លាចច្រើន ខ្លះមុជចូលក្នុងទឹក ខ្លះពួនក្នុងគុម្ពកក់ ខ្លះក្នុងប្របុស ខ្លះក្នុងនេត្រពាំង មិនហ៊ានអើតចេញ មើលចំ ជាយូរពេល នូវព្រះកក្រស្តេចដែលភ័ស្មានថាជាយក្សថ្មី ។

គឺជាស្តេចយ៉ាងស្អុតដូចជាឈើមួយដុំ តែអាការៈធ្វើឲ្យកន្ទែបកើតភ័យតក់ស្លុត ។ លុះឃើញស្តេចយានទៅមកបង្ហាញព្រះអង្គ កន្ទែបអស់ភ័យ ក៏ហ៊ានចេញពីរូងរៀងខ្លួន ។ កន្ទែបខ្លះហ៊ានចូលជិត តែទៅបុកពោះ ។ អាមួយឃើញក៏ធ្វើតាម អាមួយទៀតចូលមកដែរ មិនយូរប៉ុន្មាន រាមកអ៊ូដូចស្រមោច នៅទីបំផុត កន្ទែបទៅជាស្និទ្ធស្នាលនឹងស្តេច រហូតដល់ទៅហ៊ានលោតចំលើព្រះអង្គ ។ ស្តេចស្អុតនេះ មិនប្រកាន់ទោស ហើយគង់នៅតែស្ងៀម ។

មិនយូរប៉ុន្មាន ព្រោះអផ្សុកនឹងកន្ទែបដែលស្រែកសុំឲ្យប្រទានស្តេចណាដែលចេះកំរើកទៅវិញ (មិនយកទេស្តេចធ្មឹងដូច្នេះ) ។ ស្តេចទេព្តាក៏បញ្ជូនក្រដក់មកឲ្យ ក្រដក់ចឹកបួបចុះបួបឡើង លេបកន្ទែបទាំងមូលដោយសេចក្តីរីករាយនៃអាត្មា ។

ចំណែកកន្ទែបដូរគ្រប់គ្នា ហើយព្រះមានបន្ទូលទៅនឹងកន្ទែបទាំងនោះថា ៖ ចុះរាអ៊ូទៀតហើយ ! បំណងអ្នកពល់គ្នាទេតើដែលបន្ទុំយើងឲ្យ

គេស្ដេចដែលប្រកាន់បែបនេះ ។

ដំបូន្ម អ្នកត្រូវតែរក្សាទុកឲ្យគត់មត់នូវរដ្ឋាភិបាលរបស់អ្នក តែបើមិនបានធ្វើយ៉ាងនេះ គប្បីធ្វើយ៉ាងណា សុំឲ្យស្ដេចទមួយរបស់អ្នក មានចិត្តល្អជាទីបំផុត ហើយស្លូតបូតផង ហើយអ្នកត្រូវតែត្រេកអរនឹងស្ដេចបែបនេះទៅ ខ្លាចក្រែងលោជាជួបណាមួយវិញ ដែលគាក្រក់លើសលុបនោះ ។

## ៧៩– អ្នកប្រមឹកនិងប្រពន្ធ

មនុស្សម្នាក់ៗរមែងមានគុណវិបត្តិរបស់ខ្លួន ហើយតែងវិលមករកគុណវិបត្តិនេះជាធម្មតា : ការអៀនខ្មាស ការខ្លាច មិនអាចធ្វើជាថ្នាំពូកែបានឡើយ ។

ចំពោះការណ៍នេះ ខ្ញុំនឹកឃើញរឿងមួយ ព្រោះខ្ញុំមិនដែលនិយាយអ្វីដែលគ្មានយកឧទាហរណ៍មកជាទីអាងឡើយ ។

អ្នកប្រមឹកតែងធ្វើឲ្យខូចនូវសុខភាព ខូចគំនិតនឹងប្រាក់កាសរបស់ខ្លួន ។

មនុស្សបែបនេះ ចូលក្នុងឆាកជីវិតមិនទាន់បានពាក់កណ្ដាលផង ក៏ស្រាប់តែអស់ប្រាក់លើង ។

ថ្ងៃមួយ អ្នកប្រមឹកនេះ ស្រវឹងជោក សន្លប់បាត់ស្មារតី ឃើញដូច្នោះ ប្រពន្ធលើកដាក់ក្នុងមឈូស ។ ដោយអំណាចស្រា គាត់នៅ

លក់ក៏កូនទាំនោះ ។ កាលបើបានដឹងស្មារតី គាត់ឃើញអណ្ដាប់ខ្មោច នៅជុំវិញខ្លួន គឺទៀនគោល ទឹងសំពត់សរុំសព ។

គាត់ពោលថា : យី ! ចុះអ្វីហ្នឹង ? ប្រពន្ធអញមេម៉ាយទេតើ ! ។

ទុកាសនោះ ដោយយកសំពត់កាន់ទុក្ខមកទទូរ ហើយធ្វើសម្ដែងឲ្យប្លែក នាងប្រពន្ធ មកកេះខ្មោចនោះ ចូលទៅជិតមឈូស ដាក់ជូនដល់គាត់ នូវបាយសម្ងរជាសំណែនសម្រាប់ខ្មោច ។

ខណៈនោះ ប្ដីដៀជាក់ថា អាត្មាជាពលរដ្ឋនៃប្រទេសនរកពិតប្រាកដ គាត់សួរចំពោះប្រពន្ធដែលទទូរសំពត់ថា ឯងជាអ្វី ? ។

នាងប្រពន្ធឆ្លើយប្រាប់ថា ខ្ញុំជាយាយជីខាងស្បៀងអាហារនៅឋានព្រះយមរាជ ហើយខ្ញុំយកអាហារមកឲ្យអ្នក ដែលជាចំពោះសត្វនរកដ៏ងងឹតនេះបរិភោគ ។

ប្ដីឆ្លើយទាំងឥតគិតថា នាងឯងមានបានយកស្រាមកឲ្យពឹកផងទេ ? ។

# រឿងព្រេងបិនទី ៩

## *អ្នកលក់ត្រីនឹងយក្សខ្វាក់*

Le vendeur de poisson et Yack borgne (conte tibétain)

*ប្រែពីភាសាបារាំង ដោយលោក ក៉យ - ប៊ុក*

---

តាំងពីអតីតកាល នៅក្នុទីបេ មានព្រះមហាក្សត្រិយ៍មួយអង្គ ទ្រង់មិនដែលសោយព្រះក្រយាគ្មានត្រីទេ ។ តែក្នុងពេលមួយ ប្រទេសរបស់ព្រះអង្គមានវិបត្តិដោយគ្មានភ្លៀង ដីប្រេះក្រហែងរកទឹកគ្មាន ។ នៅ-បាតស្ទឹង មានទឹកបន្តិចបន្តួច ត្រីក៏មានចំនួនថយចុះតាមលំដាប់ ។

ព្រះមហាក្សត្រិយ៍ទ្រង់មិនអាចសោយព្រះស្ងោយបានដោយគ្មានត្រី ទ្រង់មានព្រះរាជហឫទ័យព្រួយបារម្ភជាខ្លាំង ក៏មានព្រះរាជបញ្ជាឲ្យបិទព្រះរាជប្រកាសគ្រប់កន្លែងថា : « បើអ្នកណាមានត្រីស្រស់ ឬ ត្រីងៀតយកមកថ្វាយទ្រង់ ។ នឹងជូនរង្វាន់ដល់អ្នកនោះតាមសេចក្ដីសុំ » ។ ដំណឹងនេះក៏ឮសព្ទសូរខ្ទរពាសពេញប្រទេស ។ មានមួយថ្ងៃ មានបុរសម្នាក់មកដល់មុខព្រះបរមរាជវាំង បានយកពីបរទេស នូវត្រីមួយហើយមានបំ-ណងចង់យកត្រីនោះទៅថ្វាយព្រះមហារាជ ។ នាយឆ្មាំព្រះបរមរាជវាំង-ឃាត់ហើយសួរថា :

« នែ បុរស ! អ្នកឯងទៅណាមកណា ?

បុរសនោះតបទៅនាយឆ្មាំថា : « ខ្ញុំចង់សូមគាល់ព្រះរាជា តើបាន-

ឬទេ? » ។

នាយឆ្មាំតបថា : « តើអ្នកមានការណ៍អ្វី? » ។

បុរសឆ្លើយថា : « ខ្ញុំមានត្រីមួយដែលខ្ញុំយកមកពិសេស សូមថ្វាយចំពោះព្រះរាជា » ។

នាយឆ្មាំគិតក្នុងចិត្តថា : « ត្រីមួយ ! អ្នកណាយកទៅថ្វាយព្រះបរមរាជ អ្នកនោះមុខជាបានគេគាប់ប្រសើរ ! ព្រោះហេតុដូច្នេះ បានជានាយឆ្មាំពោលទៅកាន់បុរសថា : មិនអីទេ អ្នកទុកត្រីនៅទីនេះហើយខ្ញុំនឹងយកទៅថ្វាយព្រះអង្គជូនអ្នក » ។

បុរសតបថា : « ទេលោក ខ្ញុំសូមយកត្រីនេះទៅថ្វាយព្រះរាជាខ្លួនខ្ញុំ » ។

នាយឆ្មាំឆ្លើយថា : « ចូរអ្នកលក់ត្រីនោះមកឲ្យខ្ញុំ ៗ នឹងឲ្យតម្លៃអ្នកតាមត្រូវការ » ។

ដោយបុរសនោះមិនព្រមលក់ត្រីឲ្យសោះ នាយឆ្មាំក៏សន្ទនាព្រមព្រៀងនឹងបុរសថា : ។

« ខ្ញុំអនុញ្ញាតឲ្យអ្នកចូលគាល់ព្រះរាជាបាន តែបើអ្នកបានរង្វាន់ត្រូវយករង្វាន់នោះមកចែកខ្ញុំផង » ។

បុរសឆ្លើយថា :

« បើព្រមព្រៀងបែបនេះ ខ្ញុំក៏ពេញចិត្តណាស់ លោកនឹងបាន

រង្វាន់ពាក់កណ្ដាល ។

នាយឆ្មាំតបថា: « តើអ្នកឯងនិយាយដោយសច្ចៈពិតឬ! អ្នកឯងត្រូវស្បថឲ្យខ្ញុំជឿផង! » ។

ក្នុងពេលនោះ នាយឆ្មាំក៏អនុញ្ញាតឲ្យបុរសនោះ ចូលទៅក្នុងព្រះបរមរាជវាំង ។ លុះបុរសដើរតែរដំហានចូលទៅ បុរសនោះក៏ងាកក្បាលមករកនាយឆ្មាំហើយសួរថា: » ខ្ញុំមិនស្គាល់ឈ្មោះលោក បន្តិចទៀត ខ្ញុំនឹងមករកលោក ដើម្បីនឹងចែករង្វាន់ពាក់កណ្ដាលនោះ » ។

នាយឆ្មាំឆ្លើយថា: « ខ្ញុំឈ្មោះយក្ខខ្វាក់ អ្នកណាក៏ស្គាល់ខ្ញុំដែរ » ។

បុរសក៏ចូលទៅក្នុងព្រះបរមរាជវាំង ថ្វាយបង្គំគាល់ព្រះរាជា រួចហើយថ្វាយត្រីនោះទៅព្រះអង្គ ។ ក៏មានព្រះរាជហឫទ័យសោមនស្សរីករាយមាមានបន្ទូលសួរបុរសថា: « តើអ្នកប្រាថ្នាចង់បានអ្វី ? » ។

បុរសនោះក្រាបបង្គំទូលថា:

« ទូលព្រះបង្គំជាខ្ញុំមិនចង់បានរង្វាន់អ្វីទេ សូមតែព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យអាមាត្យវាយមួយពាន់បន្ទះក្ដារ » ។

ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ព្រះសណ្ដាប់នូវសេចក្ដីក្រាបបង្គំទូលតបនៃបុរសនោះ ទ្រង់ព្រះសម្រួលជាយ៉ាងខ្លាំងហើយទ្រង់មានព្រះរាជឱង្ការថា: » បុរសនេះជាមនុស្សល្ងីលាទេដឹង! បានជាមិនចង់បានរង្វាន់ ចង់ឲ្យគេវាយគាត់ទៅវិញ » ។

ព្រះកជាទ្រង់មានព្រះកជបន្ទូលសួរហើយសួរទៀត បុរសនោះនៅតែឆ្លើយតបនូវពាក្យដដែល ។ ។ ព្រោះហេតុដូច្នេះ ព្រះអង្គទ្រង់មិនដឹងជាទ្រង់ព្រះតម្រិះយ៉ាងណា ក៏ទ្រង់ត្រាស់បង្គាប់ឲ្យគេវាយ ១០០០ បន្ទះក្តារ តែទ្រង់ឲ្យវាយតិច ។ ។

អាមាត្យក៏ចាប់ផ្តួលបុរសនោះលើផែនប្រថពី ហើយក៏វាយតិច ។ ។ លុះវាយដល់គ្រប់ប្រាំរយដង បុរសនោះក៏ក្រោកឈរឡើងហើយពោលថា:

« ប៉ុណ្ណឹងហើយ ខ្ញុំបានទទួលចំណែកខ្ញុំហើយ ឈប់ ។ » ។

អាមាត្យនឹកក្នុងចិត្តថា · ចំណែកមួយទៀតគឺអ្វីទៅ ! អ្នកណានឹងត្រូវឲ្យគេវាយប្រាំរយ ! » ។

ក្នុងពេលនោះ បុរសក៏ក្រាបបង្គំទូលព្រះកជានូវពត៌មានសព្វគ្រប់ប្រការហើយបន្ថែមថា:

« ទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គហៅអ្នកយាមម្នាក់នោះមកហើយទ្រង់ត្រាស់បង្គាប់ឲ្យទទួលរង្វាន់ពាក់កណ្តាលទៀត » ។

ព្រះកជាទ្រង់ព្រះក្រោធយ៉ាងខ្លាំង ហើយទ្រង់ត្រាស់បង្គាប់ឲ្យហៅ « យក្ខខ្វាក់ » នោះមកប្រញាប់ ។

« យក្ខខ្វាក់ » កំពុងតែគិតក្នុងចិត្តថា បើបានរង្វាន់ពាក់កណ្តាលនោះមក តើអញនឹងគិតធ្វើអ្វី ? ។ កំពុងតែគិតសប្បាយក្នុងចិត្ត ស្រាប់តែនាយសន្តិបាលទៅដល់ ។ « យក្ខខ្វាក់ » ក៏លោតត្រេកត្រអាល

សប្បាយជាខ្លាំង ៗ លុះទៅដល់មុខព្រះភក្ត្រព្រះអង្គ យល់ទ្រង់ក្រោធដូច្នោះ «យក្ខខ្វាក់» មានចិត្តព្រួយបារម្ភជាខ្លាំង ៗ ព្រះរាជាទ្រង់បានទតឃើញ «យក្ខខ្វាក់» ទ្រង់មានព្រះរាជបញ្ជាឲ្យចាប់នាយឆ្មាំនោះមកឲ្យដេកលើផែនប្រថពី ហើយក៏តាំងវាយប្រាំរយដំបងឫស្សីយ៉ាងខ្លាំង រួចនាយសន្តិបាលប្រាប់ «យក្ខខ្វាក់» ថា:

«នេះគឺរង្វាន់ពាក់កណ្ដាលចំពោះរឿងអមង្គលមិញនេះ ដែលបុរសបានថ្វាយចំពោះព្រះរាជា ៗ «យក្ខខ្វាក់» ឈឺកំពឹងគូថជាខ្លាំង តែបានហាមាត់ញញឹមទៅបុរសនោះថា:

«នេះចំជារង្វាន់ប្រសើរថ្លៃថ្លា មែនទេមិត្ត!» ៗ

«លោភណាស់លោភខូច លោភនេះជាពូជ ហាយនភាព ចង់បានខុសបទ ប្រាំរយរោប កូនចៅគួរប្រាប «យក្ខខ្វាក់ជានិយ ៗ

ចប់រឿងអ្នកលក់ត្រីនឹង «យក្ខខ្វាក់» នៅមានរឿងបក្សាតាតាខូខូនឹងហង្សមាសតទៅទៀត ៗ

# សំបុត្រទី ៦

របស់ លោក នេរូ ផ្ញើទៅបុត្រីលោក

ឈ្មោះ នាង លក្ស្មី

លោក ឈ ង-អៀម ប្រែពីភាសាអង់គ្លេស

## កំណើតនៃមនុស្ស

យើងបានឃើញនៅក្នុងសំបុត្រយើងមុនថា យ៉ាងដូចម្ដេចជីវិតបានកើតឡើងនៅលើផែនដីក្នុងទ្រង់ទ្រាយយ៉ាងសាមញ្ញបំផុត ហើយវិវឌ្ឍនាបន្តិចម្តងៗ កប់លានឆ្នាំ ទើបបានមកជាសណ្ឋានទ្រង់ទ្រាយសត្វថ្ងៃនេះៗ ក្នុងដំណើរវិវឌ្ឍនានៃជីវិតនេះ យើងក៏បានកត់សំគាល់នូវក្បួនមួយដ៏មានសារៈសំខាន់យ៉ាងជាប់ចិត្ត គឺថា សត្វទាំងឡាយតែងខិតខំអនុលោមធ្វើខ្លួនវាឲ្យស្របទៅនឹងសភាពទាំងឡាយ ដែលនៅជុំវិញខ្លួនវាជាដរាបៗ ក្នុងការខិតខំធ្វើនេះ វាបានបង្កើនពង្រីកនូវគុណសម្បត្តិថ្មីៗ ទៀតជាច្រើន ហើយបានប្រែទៅជាសត្វមានគុណសម្បត្តិខ្ពង់ខ្ពស់ទឹងមានរាងកាយកាន់តែសាំញាំឡើងៗ យើងអាចឃើញនូវការផ្លាស់ប្ដូរនេះ ឬក៏វិវឌ្ឍនភាពនេះ ដោយមធ្យោបាយជាច្រើនៗ គួរយ៉ាងដំបូងបង្អស់ មានសត្វគ្មានឆ្អឹងកើតឡើង ប៉ុន្តែដោយសត្វបែបនេះពុំអាចរស់នៅបានយូរ វាក៏បានបង្កើនឲ្យមានឆ្អឹងឡើងៗ ឆ្អឹងដំបូងដែលវាបានបង្កើនឡើង គឺឆ្អឹងខ្នងៗ ដូច្នេះ យើងអាចបែងចែកសត្វជាពួកៈ គឺ និបជ្ជាដ្ឋិកសត្វ

(សត្វគ្មានធ្មេញខ្នង) និងបិដ្ឋង្គិកសត្វ (សត្វមានធ្មេញខ្នង) ។ មនុស្ស និងសត្វដែលកូនឃើញនៅជុំវិញកូន សុទ្ធតែមានធ្មេញ ។

តមកទៀត កូនប្រទះឃើញសត្វសាមញ្ញតាំងឡាយដូចជាពួកត្រីដែលពងហើយបោះបង់ពងនោះចោល ។ វាពងម្តង ៗ រាប់ពាន់ ប៉ុន្តែវាមិនថែទាំពងតាំងនោះទេ ។ មេមិនបេះរក្សាការពារកូនតូច ៗ ទេ វាគ្រាន់តែពងហើយចាកចេញទៅ ពុំវិលត្រឡប់មករកពងវាវិញឡើយ ។ ដោយហេតុតែគ្មានអ្នកថែទាំ ភាគច្រើននៃពងតាំងនោះត្រូវស្លាប់ ហើយភាគតិចក៏បានញាស់ទៅជាពួកត្រី ។ នេះមិនគឺជាការខ្ជះខ្ជាយមួយយ៉ាងសំបើមទេឬ ? បើយើងថយមកពិនិត្យសត្វដែលមានគុណសម្បត្តិខ្ពង់ខ្ពស់វិញ យើងឃើញថាពងឬកូនតូច ៗ នៃសត្វប្រភេទនេះ មានចំនួនតិចទេ ប៉ុន្តែវាបេះថែរក្សាពងឬកូនតូច ៗ យ៉ាងមត់ចត់ ។

មេមាន់ក៏ពងដែរ ប៉ុន្តែវាបេះក្រាបហើយភ្ញាស់ពងរបស់វា ហើយលុះដល់កូនមាន់តូច ៗ ញាស់ហើយ វាចិញ្ចឹមកូនតាំងនោះអស់ពេលបន្តិចទៀតផង ។ តែដល់កូនមាន់ធំឡើង មេមាន់មិនសូវរវល់ថែទាំប៉ុន្មានឡើយ ។

តមក មានការប្រែប្រួលយ៉ាងធំ ក្នុងចំណោមសត្វខ្ពង់ខ្ពស់តាំងឡាយ គឺថនិកសត្វ ដែលឪពុកបាននិយាយខ្លះហើយក្នុងសំបុត្រមុន ។ សត្វពួកនេះពុំពងទេ តែរក្សាពងទុកនៅក្នុងពោះ ហើយបង្កើតជាកូនពេញ

លក្ខណៈតែម្តង ដូចជាឆ្កែ ឆ្មា ទន្សាយ ។ ហើយបន្ទាប់មក មេបំបៅកូន ។ ដូច្នេះ មេរក្សាការពារកូនរបស់វាយ៉ាងម៉ត់ចត់ ។ ពោះជាដូច្នោះក៏ដោយ យើងឃើញថាមានការខ្ជះខ្ជាយយ៉ាងខ្លាំងណាស់ដែរ។ ទន្សាយបង្កើតកូនមានចំនួនច្រើន ពីរបីខែម្តង ហើយកូនភាគច្រើនត្រូវស្លាប់ទៅវិញ ។ ប៉ុន្តែសត្វខ្ពង់ខ្ពស់ដូចជាដំរី បង្កើតកូនម្តងតែមួយប៉ុណ្ណោះ តែចេះថែកូនយ៉ាងប្រពៃ ។

ដូច្នេះ កូនត្រូវយល់ថា នៅពេលដែលសត្វចំរើនធំឡើង រកពុំពងទេ គឺពារពោះកូនតូចដែលធំណាត់ឡើង ដូចជាមេកសុខសាគងចឹង គ្រាន់តែតូចជាងប៉ុណ្ណោះ ហើយតាមធម្មតា សត្វខ្ពង់ខ្ពស់បង្កើតកូនម្តងតែមួយ ។ កូនគួរកត់សំគាល់ទៀត សត្វខ្ពង់ខ្ពស់រមែងមានសេចក្តីស្រឡាញ់ខ្លះ ។ ចំពោះកូនរបស់វា ។ មនុស្សគឺជាសត្វខ្ពង់ខ្ពស់បំផុត ហេតុដូច្នោះហើយ កូនរមែងឃើញម្តាយឪពុកតែងស្នេហាអាសូរនឹងថែទាំកូនយ៉ាងដិតដល់ ។

តាមគន្លងនេះ មនុស្សប្រាកដជាបានចំរើនឡើងជាជំហ្វង់អំពីសត្វទាបមក ។ តាមស្មាន បឋមមនុស្សមានភាពប្រហាក់ប្រហែលនឹងមនុស្សដែលយើងឃើញសព្វថ្ងៃនេះដែរ ។ មនុស្សនោះ ពាក់កណ្តាលជាស្វាព្រៃ ពាក់កណ្តាលជាមនុស្សរស់នៅ ហាក់ដូចជាមនុស្សសុទ្ធសាធ ។ តើកូននៅចាំបានទេ កាលយើងទៅជួបលោកសាស្ត្រាចារ្យម្នាក់នៅក្រុងហៃដែលប៊ែគ្ស៍ (Heidelberg) ក្នុងប្រទេសអាល្លឺម៉ង់ ? លោក

បានបង្ហាញយើងនូវសារមន្ទីរតូចមួយដែលពោរពេញដោយបាសាណភូត ហើយជាពិសេស នូវឆ្អឹងលលាក្បាលចាស់មួយ ដែលលោកបានរក្សាទាក់សោទុកយ៉ាងម៉ត់ចត់ ។ គេសន្និដ្ឋានថាឆ្អឹងលលាក្បាលនោះ ជារបស់មនុស្សជាន់ដើមណាមួយ ។ ឥឡូវនេះ យើងហៅមនុស្សជាន់ដើមនោះ ថាមនុស្សហៃដែលបិក័្យ (The Heidelberg man) ដោយហេតុថាឆ្អឹងលលាក្បាលរកឃើញកប់នៅជិតក្រុងហៃដែលបិក័្យ ។ មែនហើយ កាលពីសម័យព្រេងនាយនោះ ពុំមានក្រុងហៃដែលបិក័្យ ឬឋានទីណាមួយដទៃឡើយ ។

ក្នុងសម័យជាន់ដើមនោះ កាលដែលបឋមមនុស្សនៅត្រាច់រង្គត់វិលវល់ចុះឡើង: អាកាសធាតុត្រជាក់ពេកណាស់ ។ សម័យនោះ គេហៅថា យុគទឹកកក ពីព្រោះមានទឹកកកច្រើនណាស់ ។ គំនរទឹកកកទាំងឡាយ ដូចជាគំនរទឹកកកដែលឋិតនៅជិតអក្សាសានខាងជើង (The Nord Pole) សព្វថ្ងៃនេះ បានរអិលចុះមកកាន់ប្រទេសអង់គ្លេសនិងប្រទេសអល្លឺម៉ង់ ។ មនុស្សបានប្រទះនឹងការពិបាកក្នុងការរស់នៅណាស់ ហើយមានពេលគន្លល់យ៉ាងច្រើន ។ គេប្រាថ្នារស់នៅតែទីណាដែលគ្មានគំនរទឹកកកប៉ុណ្ណោះ ។ អ្នកវិទ្យាសាស្ត្របានប្រាប់យើងថា នៅសម័យនោះ សមុទ្រមេឌីទែរ៉ាណេមិនមែនជាសមុទ្រទេ គឺគ្រាន់តែជាបឹងមួយឬពីរប៉ុណ្ណោះ ។ ឯសមុទ្រក្រហមក៏ពុំមានដែរ ។ គឺជាដីគោកទាំងអស់ ។ តាមស្មាន ភាគធំនៃប្រទេសឥណ្ឌា] គឺជាកោះមួយ ហើយ

មានសមុទ្រនៅត្រង់ពុនចាប (PunJab) និងត្រង់ផ្នែកនៃខេត្តទាំងឡាយរបស់យើង ៗ ចូរកូនស្មានទុកភូមិភាគឥណ្ឌៀ ភាគខាងត្បូង និងឥណ្ឌៀ ភាគកណ្ដាលទុកដូចជាកោះមួយយ៉ាងធំ ដែលដាច់ផុតពីជួរភ្នំហិមល័យ ដោយសមុទ្រល្បងមើល! កូនមុខជាត្រូវទៅកាន់ស្រុកមូស្សូរី Mussoorie ដោយកប៉ាល់មួយដំណាក់មិនខាន ៗ

នៅពេលដែលមនុស្សកើតឡើងជាដំបូង គឺត្រូវសត្វធំ ៗ ជាច្រើនចោមរោមជុំវិញ ហើយត្រូវរស់នៅក្នុងសេចក្ដីភ័យខ្លាចនៃសត្វទាំងនោះ ៗ សព្វថ្ងៃនេះ មនុស្សជាម្ចាស់នៃពិភពលោកហើយ គេប្រើសត្វទាំងឡាយឲ្យធ្វើអ្វី ៗ តាមគេប្រាថ្នា ៗ គេបានផ្សាំងសត្វខ្លះដូចជាសេះ មេគោ ដំរី ឆ្កែ ឆ្មា និងសត្វដទៃទៀតជាច្រើន ៗ គេបរិភោគសត្វខ្លះ ហើយសត្វខ្លះដូចជា សិង្ហ និងខ្លា គេបាញ់សម្រាប់សេចក្ដីសប្បាយ ៗ ប៉ុន្តែក្នុងសម័យនោះ មនុស្សមិនបានជាម្ចាស់ទេ គឺគ្រាន់តែជាសត្វលោករងវេទនាដែលត្រូវគេបណ្ដេញដែរ ឯតខំគេចវេះប្រាសអំពីពាឡម្រឹគធំ ៗ ៗ តែបន្តិចម្ដង ៗ មនុស្សបានលើកស្ទួយខ្លួនឯងហើយបានទៅជាមានឥទ្ធិឫទ្ធខ្លាំងឡើង ៗ ទាល់តែក្លាយទៅជាមានកម្លាំងជាងសត្វទាំងអស់ ៗ តើមនុស្សខ្លាំងពូកែយ៉ាងដូចម្ដេច? មិនមែនដោយអាសារអត្តពលទេ ព្រោះថាដំរីខ្លាំងលើសជាងមនុស្សទៅទៀត ៗ គឺដោយសារតែប្រាជ្ញានិងកំឡាំងនៃខួរក្បាល ៗ

យើងអាចពិចារណាមើលដើមកំណើត នៃការដុះដាលនៃប្រាជ្ញា

តាំងពីសម័យព្រេងនាយនៃមនុស្សរហូតដល់មកសម័យបច្ចុប្បន្ននេះ ។
ពិតមែនហើយ គឺប្រាជ្ញានេះឯង ដែលញែកមនុស្សចេញអំពីសត្វឯទៀតៗ
តាមធម្មតា គ្មានការប្លែកអ្វីទេ រវាងមនុស្សឥតប្រាជ្ញាហើយនឹងសត្វ ។

តាមស្មាន ការរកឃើញដ៏សំខាន់មុនគេ ដែលមនុស្សរកឃើញ
គឺការរកឃើញភ្លើង ។ យើងបង្កាត់ភ្លើងសព្វថ្ងៃដោយសារឈើគូស ។
តែតាមពិត ឈើគូសគឺជាវត្ថុកើតថ្មីៗនេះទេ ។ ក្នុងសម័យដាច់ដើម
គេបានភ្លើងដោយគូសថ្មពីរដុំទៅវិញទៅមកទាល់តែកផ្កាជាភ្លើង ហើយ
ផ្កាភ្លើងនេះប៉ះជាប់ទៅលើដុំចំបើងស្ងួតឬវត្ថុស្ងួតអ្វីមួយដទៃទៀត ។ ជួន
កាលភ្លើងបណ្ដាលមានឡើងដោយឯង ។ នៅក្នុងព្រៃ ប្រហែលជាដោយ
សារប៉ះទង្គិចគ្នាឬក៏វត្ថុអ្វីដទៃទៀត ។ សត្វពុំឆ្លាតវាងវៃដើម្បីល្មមយល់
បានអំពីការនេះឡើយ ។ ប៉ុន្តែមនុស្សឆ្លាតវាងវៃជាង ។ គេឃើញនូវ
សារៈប្រយោជន៍របស់ភ្លើងៗ ភ្លើងធ្វើឲ្យគេកក់ក្ដៅក្នុងហេមន្តរដូវនឹងបង្អើល
សត្រូវរបស់គេគឺសត្វធំៗ ឲ្យបៀសចេញទៅឆ្ងាយ ។ ដូច្នេះនៅពេលដែល
ភ្លើងចាប់មានឡើង មនុស្សប្រុសស្រីបានចិត្តរក្សាភ្លើងទុកដោយបោះ
ស្ទឹកឈើស្ងួតទៅក្នុងភ្លើង ។ គេពុំចង់ឲ្យរលត់ទៅវិញទេ ។ បន្តិចម្ដងៗ
គេបានយល់ឃើញថា គេអាចបង្កើតកំទេចផ្កាភ្លើងនឹងភ្លើងដោយខ្លួនគេ
បានដោយប្រគួតថ្មជាមួយគ្នា ។ នេះគឺជាការរកឃើញមួយយ៉ាងធំសម្រាប់
គេ ហើយការរកឃើញនេះប្រគល់ដល់គេនូវអំណាចខ្លះទៅលើសត្វដទៃ
ផង ។ តាំងអំពីនោះមក មនុស្សក៏បានចុះក្នុងគន្លងជាម្ចាស់នៃពិភពលោក។

## តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

> ទំនៀមទម្លាប់ នៃខេមរជាតិ
> ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
> ព្រោះខេមរជាតិ ជាជាតិសោភី
> ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
>
> ប. ព.

# របាំបុកអង្រែ

### ស្រង់ពីសៀវភៅ របាំប្រជាប្រិយខ្មែរ

របាំបុកអង្រែ ជារបាំមួយផ្សេងពីរបាំគោះអង្រែ ។ សព្វថ្ងៃ របាំនេះឃើញមាននៅស្រុកភូមិឆ្ងាយពីរាជធានី ព្រោះធ្លាក់ទៅជារបាំប្រជាប្រិយ ដែលអ្នកស្រុកនិយមលេងនៅពេលបុណ្យចូលឆ្នាំ ដើម្បីលើកដំកើងពិធីបុណ្យនេះឲ្យរឹងរឹតតែខ្លាំងឡើង ។ អាស្រ័យដោយការខ្សត់ខ្សោយពុំសូវមាននៅសល់ច្រើនកន្លែង របាំនេះក៏ស្ទើរតែគេលែងស្គាល់ឈ្មោះទៅហើយ ។ ប្រសិនជានៅចាំឈ្មោះខ្លះ ៗ ក៏គេពុំសូវដែលឃើញរូបភាពច្បាស់លាស់នៃរបាំបុកអង្រែនេះដែរ ។

យើងសង្កេតត្រង់ឈ្មោះថា « បុកអង្រែ ។ » អាចបញ្ចេញន័យមក

ភ្នាមវិញថា ចង្វាក់នៃរបាំនេះច្បាស់ជាអាស្រ័យជាមួយការបុកអង្រែទៅ ក្នុងត្បាល់ ឬបុកទៅលើឈើកណាត់ណាមួយ ដើម្បីបញ្ចេញសូរជាម៉ង ខាន ប៉ុន្តែតាមពិតពុំដូច្នោះទេ ។ អង្រែនេះជាដងចង្កោមចង្រ្កន់ដែល អ្នកកាន់នៅដៃដើម្បីបុកទៅនឹងដី បញ្ចេញសូរតាមចង្វាក់ក្បាច់របស់ ខ្លួន ។ តាមការពិនិត្យសង្កេតឲ្យច្បាស់លាស់ពីបច្ចេកទេសរបាំនេះ ឃើញមានរបៀបដូចតទៅ ៖

១ - អំពីប្រដាប់ប្រដា

ក គ្រឿងភ្លេង -

គ្រឿងក្នុងសំរាប់ប្រគុំរបាំនេះ គ្មានអ្វីច្រើនទេ មានតែអង្រែ ៤ គឺអង្រែដែលព្យួរចង្រ្កន់ ដងធ្វើពីឫស្សីឬធ្វើពីឈើ ។ បើធ្វើពីឫស្សី គេយកឫស្សីមានទំហំប៉ុនកំភួនដៃ មានប្រវែងប្រមាណជា ១ ម៉ែត្រកន្លះ ឬ ២ ម៉ែត្រ ហើយពុះខាងចុង ច្រៀកជាបន្ទះ ៗ បិតឲ្យស្តើងស្អាត រួចពត់បន្ទះទាំងនោះឲ្យកោងចុងកំផាងដូចជាមាត់ដុច ដោយយកបន្ទះឫស្សី ផ្សេងទៀត ដែលចិតស្តើង មកត្បាញក្រងជាចន្លល់ទប់ឲ្យនៅជាប់ មាន សណ្ឋានដូចមាត់ត្រែ ។ តាមបណ្តោយបន្ទះឫស្សីដែលត្បាញនោះ មានចងបន្តោងព្យួរកូនចង្រ្កន់ប៉ុន ៗ ម្រាមដៃដង្ហែគ្នាគ្រប់ ៗ ជម្រៀក ៗ នៅចុងបំផុតនៃជម្រៀកឫស្សីដែលព្យួរចង្រ្កន់ មានចងក្រណាត់ជាតីដែល ច្រៀកតូចៗ ធ្វើជារុងរំយោល ។ ឯខាងគល់ដងឫស្សីនេះ ពុំមានបេធា

ជាអ្វីទេ ព្រោះសំរាប់ចុកទៅនឹងដីឲ្យឮសូរតាមបទឬតាមចង្វាក់ៗ ជួនកាលគេធ្វើដងនេះពីឈើមានសណ្ឋានដូចអង្រែ(១) តែបើដងជាឈើ ក៏ត្រូវតែយកបន្ទះឫស្សីមកបន្តខាងចុង ធ្វើជារូបកងសំរាប់ព្យួរបង្ក្រងដូចពោលមកហើយនេះដែរ ៗ

អាស្រ័យដោយលំអខាងចុងដោយបង្ក្រាមបង្ក្រងយ៉ាងនេះហើយ បានជាកាលណាគេចុកទៅ អង្រែនោះក៏បញ្ចេញសូរច្រាវៗ យ៉ាងគឹកកង ៗ

## ១– ប្រដាប់តុបតែងកាយ–.

អ្នករាំទាំងនេះ មានប្រុសមានស្រី ហើយប្រុសស្រីទាំងនេះ មានសំលៀកបំពាក់ផ្សេងគ្នាដូចតទៅ ៖

ប្រុស ៗ ពាក់អាវវៀលកដៃខ្លី មានពណ៌តាមគេចូលចិត្ត ស្លៀកខោខ្លីពាក់កណ្ដាលភ្លៅ ចុងជើងចំក្រណាត់ជាតិក្រហម ហើយក្របួចតឹងជាប់នឹងសាច់ ៗ កបង់កខ្សែប្រចុច ទំលាក់ចុងសំតាកទៅក្រោយខ្នង ៗ សក់កាត់ជើងកញ្ញើ ៗ

ស្រី ៗ ពាក់អាវបំពង់វែងខិចលើជង្គង់បន្តិច ពណ៌លឿងក្រួយបេកបុចុងល័ក្ខ ដៃអាវស្ដួចរៀវតឹងចុងដៃ ៗ សំពត់ចងក្បិនក៏ពណ៌ដែរ តាមការចូលចិត្តពណ៌អ្វីក៏បាន ៗ ដៃពាក់កងប្រាក់ទាំងសងខាង ត្រចៀកពាក់ការទំពក់ បង់កកខ្សែងសូត្រសំយុងចុះមកមុខទាំងសងខាង ៗ សក់កាត់ផ្កាថ្កូវ ៗ

---

១ – តាមឯកសារនៅក្នុងក្រុមជំនុំ មានតែឯកសាររបស់លោកកែវ. កុល នៅភូមិជ្រៃរយោង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ដែលឲ្យពត៌មានហួរហែរពីរបាំនេះ ។

## ២ – អំពីរបៀបរាំ

របៀបលេងរបាំនេះ ត្រូវមានមនុស្ស ៤ នាក់ ប្រុស ២ នាក់ ស្រី ២ នាក់ស្មើគ្នា ។ ម្នាក់ៗ សុទ្ធតែកាន់ដងអង្រែមួយៗ រៀងខ្លួន ។ ដល់ពេលរាំ គេឈរសងខាងទល់មុខគ្នា គឺស្រីៗ ពីរនាក់ឈរម្ខាង ប្រុសពីរនាក់ឈរម្ខាង ហើយចាប់ផ្ដើមច្រៀងម្ដងម្នាក់ឆ្លងឆ្លើយគ្នាទំនងដូចជាច្រៀងប្រកែក តែមានរាំលាយជាមួយផង ។ បើនរណាមួយជាអ្នកច្រៀង អ្នកនោះឈានចេញមកមុខឃ្លាតពីជួរបន្តិច ហើយចាប់ច្រៀងយោលខ្លួនតាមក្បាច់រាំ ជើងគោះចង្វាក់ ដៃម្ខាងកាន់អង្រែបុកបញ្ចេញស្នូរ ដៃម្ខាងរាំយ៉ាងទន់ភ្លន់ ។ ម្នាក់ទៀតដែលត្រូវច្រៀងតទៅវិញ ក៏ធ្វើដូចគ្នានេះដែរ ។ រីឯអ្នកដែលមិនច្រៀងទាំងប៉ុន្មាន សុទ្ធតែជួយបុកអង្រែឲ្យចង្វាក់ស្មើៗ គ្នាព្រមទាំងយោលខ្លួនរាំរំពើតរំពើងជាមួយផង ។

ក្រៅពីអ្នករាំទាំង ៤ នាក់នេះ តែងមានអ្នកឈរមើលហើយជួយទះដៃឲ្យចង្វាក់រាំជាច្រើននាក់ទៀត ។

ដោយសាររបាំនេះ គេលេងតែនៅពេលចូលឆ្នាំ ស្របជាមួយរបាំឬចម្រៀង ច្រើនបែបច្រើនយ៉ាងទៀតនោះ អ្នកស្រុកក៏យករបាំរាំបុកអង្រែទៅបញ្ចូលជាមួយល្បែងចោលឈូងឬ ចម្រៀងប្រកែក ឆ្លើយឆ្លងគ្នារវាងស្រីប្រុសទៅក៏មាន ។ ហេតុនេះបានជាលោកកែវ-កុល នៅអង្គតាសោមបានឲ្យការណ៍ថា ៖ ពីដើមលោកប្រទះគេលេងរបាំនេះនៅ

ភូមិទ្រយឹង ឃុំជម្រះពេន ស្រុកសំរោង ខេត្តតាកែវ គេច្រៀងបទប្របកៃ ឬបទបោលឈូង ដោយច្រៀងឆ្លើយឆ្លងគ្នាអស់មួយវគ្គ បោះឈូងម្តង ៗ ហើយអ្នកស្រុកនោះក៏ហៅរបាំនេះថា « កំបុកអង្រែបោលឈូង ៗ » ភ្ជាប់គ្នាដូច្នេះ ។

ឯគោលបំណងនៃការកំបុកអង្រែនេះ ពុំមានត្រូវការសុំលុយកាក់អ្វីទេ គ្រាន់តែជាការសប្បាយក្នុងពេលបុណ្យទានសំខាន់ ៗ ប៉ុណ្ណោះ ។

### ៣ – អំពីទំនុកច្រៀង

ដោយអ្នកស្រុកនិយម យករបាំនេះទៅការឡាយបញ្ចូលជាមួយល្បែងបោលឈូង ឬបទប្របកៃ សឹងបាត់ជានដើម ដូចអធិប្បាយមកខាងលើ បានជាបទច្រៀងក្នុងពេលកំ សុទ្ធសឹងជាបទបោលឈូងឬប្របកៃទាំងអស់ទៅដែរ មានបទកែវកិសាន នឹង បទកំសត់ ជាដើម ៗ ដូច្នេះសេចក្តីជាទំនុកច្រៀងក៏រេទៅតាមទំនុក ដែលមានស្រាប់ក្នុងល្បែងបោលឈូងនឹងចំរៀងប្របកៃនោះដែរ មានតែសេចក្តីផ្តើមបទប៉ុណ្ណោះ ដែលរក្សាទុកនូវលក្ខណៈស្របជាមួយរបាំនេះដូចឃ្លាដើមមានសេចក្តីថា៖

ពួកយើងប្រុស ៗ ( ឬថា ពួកយើងស្រី ៗ )
កំបុកអង្រែ
ទាំងអស់គ្រប់គ្នា
មានប្រុសមានស្រី ៗ

រដូវខែបេត្រ

ខែចូលឆ្នាំថ្មី

លេងទាំងប្រុសស្រី

សប្បាយគ្រប់គ្នា(១) ។

អ្នកច្រៀងទាំងប្រុសទាំងស្រី តែងចាប់ផ្តើមឡើងសុទ្ធតែយកឃ្លាខាងលើនេះមកធ្វើជាលំនាំដើម រួចបន្តទៅមុខ ទើបបញ្ចេញបញ្ចូលថែមថយតាមសំនួនពាក្យ ដែលគេឡកឡឺយឲ្យបានសើចសប្បាយក្នុងសិល្បៈនេះឡើង ។

## ៤– អំពីទ្រនំបត្រ

តាមទំនៀមរៀងមក រៀងរាល់ឆ្នាំបុកអង្រែ មុននឹងលេង សមាជិកវង់ប៉ាំបាននាំគ្នារៀបទ្រនំបត្រជាមុនសិន ។ ទ្រនំបនោះមានរណ្ដាប់ដូចតទៅ :

– ស្លាធម៌ ១ គូ – អង្ករមួយគ្រឡោក

– ទៀន ៥ ធូប ៥ – សំពត់សមួយផត់

– ស្លាដម៤ – ប្រាក់មួយរៀលនឹងកាស ៤

ប្រជាប់ប្រជារៀបចំនៅផ្ទះអ្នកណាជាមេប៉ាំ គឺជាគ្រូកំនៃវង់ប៉ាំនេះ ហើយកូនកំទាំងអស់គ្នា ត្រូវទៅជួបជុំអុជធូបថ្វាយបង្គំគ្រូ ។ គ្នាមុននឹងចេញទៅលេង ។

១– យកតាមឯកសារនៅក្នុងក្រុមជំនុំរបស់លោក កែវ កុល នៅភូមិជ្រៃយោង ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

## ៥- អំពីដើមកំណើត

តាមឯកសារតែមួយដែលយើងមាន ពុំបានបញ្ជាក់ថារបាំបុកអង្រែមានដើមកំណើតមកពីប្រទេសណា ឬកើតមកពីពួកកុលសម្ព័ន្ធណាទេ ។ ប៉ុន្តែ បើយើងរកសេចក្តីសន្និដ្ឋានតាមការសង្កេតអំពីរបៀបរាំ ប្រដាប់គ្រឿងបន្ទរនិងសំលៀកបំពាក់ដូចមានរាយរ៉ាប់មកខាងលើ យើងយល់ថាជាសិល្បៈចាស់បុរាណឆ្ងាយតាំងពីអារ្យធម៌ដើមរបស់ខ្មែរ មុនគ្រិស្តសករាជទៅទៀត តួយ៉ាងដូចមានប្រដាប់បុកឲ្យឮស្នូរ ដូចជាបញ្ជូររបស់របាំត្រុដិដែរ ។ ប៉ុន្តែប្លែកត្រង់ខ្នែរចនាជាវង់តូចបែបនេះឡើង យើងយល់ថាទំនងជាទើបតែតាក់តែងឡើង នៅសម័យកណ្តាលរវាងសតវត្សទី ១២ ដល់ ១៦ ប៉ុណ្ណោះ ដោយយើងវិនិច្ឆ័យទៅតាមសំលៀកបំពាក់ ដូចជាប្រុសស្លៀកខោខ្លី ស្រីពាក់អាវបំពង់វែង ជាដើម ។

ប៉ុន្តែ ទោះបីជារចនាច្រើនជាន់ថ្នាក់ច្រើនលើក ច្រើនគ្រាយ៉ាងណាក៏ដោយ លក្ខណៈដើមគឺប្រដាប់បន្ទរ និងក្បាច់រាំ ក៏នៅតែរក្សាកេរ្តិ៍ដំណែលសិល្បៈបុរាណនៃជនជាតិដើមដែលជាមូលដ្ឋាននៃអារ្យធម៌ដើមរបស់យើង គឺជារបស់ពួករដ្ឋកសិ (Autochtones) ដែលរស់នៅភូមិភាគអាស៊ីខាងត្បូង ដែលអ្នកប្រាជ្ញសព្វថ្ងៃសន្មតឈ្មោះថា «អារ្យធម៌អូស្ត្រូ-អាស៊ី» (Austro-Asiatiques) មានអារ្យធម៌បុរាណរបស់ខ្មែរយើងជាអាទិ ។

# បាតុកម្មនៃពុទ្ធសាសនិកនៅមុខព្រះបរមរាជវាំងចតុម្មុខ

ពត៌មានយ៉ាងអាណោចអាធម៌ ស្តីពីការតស៊ូរបស់ពុទ្ធសាសនិកប្រឆាំងនឹងរដ្ឋការវៀតណាមខាងត្បូង រហូតដល់មានបាត់បង់ជីវិត សុំឲ្យរដ្ឋការ ង៉ោ-ឌិន-យៀម បើកឲ្យមានសិទ្ធិខាងសាសនា ធ្វើឲ្យពុទ្ធសាសនិកជនទាំងសាកលលោក មានប្រទេសសេរីលង្កា ភូមាជាដើម មានសេចក្តីរំភើបយ៉ាងខ្លាំង ហើយបានទាំងធ្វើបាតុកម្មយ៉ាងឧឡារិក នៅក្នុងប្រទេសរៀងៗខ្លួន ដើម្បីសុំឲ្យមតិអន្តរជាតិជួយព្រមានរដ្ឋាភិបាល ង៉ោ-ឌិន-យៀម ឲ្យបញ្ឈប់នូវអំពើដ៏ឃោរឃៅនេះយ៉ាងរួសរាន់ ហើយសូមកុំឲ្យរំលោភលើធម្មនុញ្ញនៃសហប្រជាជាតិ ស្តីអំពីសិទ្ធិសេរីភាពខាងជំនឿ ។

រដ្ឋការ ង៉ោ-ឌិន-យៀម បានរំលោភលើសិទ្ធិនៃពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ធ្វើឲ្យរំជួលដល់សាកលលោក សូម្បីតែអ្នកកាន់សាសនាដទៃទៀត គេបានចូលកាន់មរណសញ្ញាជាមួយនឹងពុទ្ធសាសនិកដែរ ។ សាកលលោកទាំងអស់ គេព្រួយណាស់តែសង្គ្រាមខាងសាសនា ដោយមានការរំលោភសិទ្ធិសេរីភាពខាងសាសនា នៅវៀតណាមខាងត្បូង ទើបសាកលលោកដែលកាន់សាសនាក្រៅពីពុទ្ធសាសនា



ព្រះភិក្ខុសង្ឃនៅវត្តឧណ្ណាលោម គង់សង្រួមចូលកាន់មរណទុក្ខ ព័ទ្ធជុំវិញក្ដារបញ្ឈសមាធ ប្រទង់សាសនាពីលើជានិមិត្តរូបនៃសពពុទ្ធសាសនិកជាតិយៀកណាមខាងត្បូងទាំងបព្វជិតទាំងគ្រហស្ថ ដែលទទួលអនិច្ចកម្មដោយអំពើព្រៃផ្សៃនៃរបបង៉ោ ឌិញ-ឌៀម កាលពីថ្ងៃទី ១១-៦-៦៣ ។

គេជួយព្រួយ ជួយកើតទុក្ខជួសជនពុទ្ធសាសនិក ដែលត្រូវរដ្ឋការវៀតណាមខាងត្បូងធ្វើទុក្ខបុកម្នេញនោះ ។

ចំណែកខេមរជនវិញ ៩៩% ជាអ្នកកាន់ព្រះពុទ្ធសាសនា មិនព្រមព្រងើយកន្តើយឡើយ ក្រោកឡើងប្រឆាំងជាដាច់ខាត មិនឲ្យនរណាមួយរំលោភសិទ្ធិខាងពុទ្ធសាសនាឡើយ ។ ក្រោយពីព្រះសង្ឃទាំងពីរគណៈ បានធ្វើបាតុកម្មយ៉ាងមហោឡារិកនៅក្នុងវត្តឧណ្ណាលោមនឹងបទុមវតីកដវកកមមក នៅវេលាព្រឹកថ្ងៃទី ១៨ មិថុនា ឆ្នាំ ១៩៦៣ ប្រជាពលរដ្ឋខ្មែរ បានរួមគ្នាមកមុខព្រះបរមរាជវាំង ចូលកាន់មរណទុក្ខជាមួយពុទ្ធសាសនិកនៅវៀតណាមខាងត្បូង ដែលបានស្លាប់បាត់បង់ជីវិត ក្នុងកិច្ចការពារព្រះពុទ្ធសាសនា តទល់នឹងរដ្ឋការង៉ោ-ឌិន-យៀម ។

បាតុករទាំងអស់ដែលទៅថ្វាយទុក្ខនៅមុខព្រះបរមរាជវាំង មិនមែនសុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ បើតាមយើងសង្កេតឃើញសូម្បីតែអ្នកកាន់សាសនាឥស្លាម ក៏គេទៅជួយរួមធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋការង៉ោ-ឌិន-យៀម ( កាតូលិក ) ដែលចំបិទសិទ្ធិសេរីភាពខាងព្រះពុទ្ធសាសនា រហូតដល់ទៅសម្លាប់ពុទ្ធសាសនិកទៀតផង ។ បាតុករប្រមាណ ២ ម៉ឺននាក់ កាន់បដាទៅឈរថ្វាយញត្តិ ថ្វាយសម្តេចព្រះបិតាសន្តិភាពជាតិ សូមអង្វរឲ្យព្រះអង្គទ្រង់ជួយធ្វើអន្តរាគមន៍ ចំពោះសាកលលោកក្នុងរឿងឃាតកម្មនៃពុទ្ធសាសនិក នៅវៀតណាមខាងត្បូង ។

បាតុករទាំងនោះ មានព្រះសង្ឃជាសមណនិស្សិតនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងមហាវិទ្យាល័យព្រះស៊ីហនុរាជ ព្រះសង្ឃយុវជនផ្នែកមហាយាន ឧបាសក-សិកា និងក្រុមឥស្លាម បានឈរយ៉ាងស្រងូតស្រងាត់ ៗ

នៅវេលាម៉ោង ៩ គត់ សម្ដេចព្រះប្រមុខរដ្ឋជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ដែលមានសម្ដេចក្រុមព្រះស៊ីសុវត្ថិមុនីរេត ប្រធានឧត្ដមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារផងទៀតជាច្រើន ហែហមព្រះអង្គផង ព្រះអង្គទ្រង់ស្ដេចយាងចេញពីព្រះរាជដំណាក់ មកទទួលក្រុមបាតុករ ក្រោមស្វេទៈដែលគ្រហស្ថយ៉ាងកន្ទេញ ៗ

ក្រោយដែលព្រះអង្គថ្វាយបង្គំព្រះសង្ឃ និងទទួលក្រាបថ្វាយបង្គំពីកូនចៅពុទ្ធសាសនិកហើយ សម្ដេចពុទ្ធសាសនូបត្ថម្ភ ព្រះអង្គទ្រង់ស្ដេចយាងទៅប្រថាប់ នៅលើព្រះទីនាំងចន្ទច្ឆាយា ទើបសហជីវិន ក៏យល្ក ជាដំណាងនៃពុទ្ធិកសមាគម បានថ្លែងថ្វាយនូវញត្តិ ហើយជាបន្ទាប់មកទើបពុទ្ធសាសនិកជនជាច្រើន បានអានញត្តិជាបន្តបន្ទាប់គ្នា ៗ គួរឲ្យតាប់អារម្មណ៍ចំពោះជនឥស្លាមដែលបានថ្វាយញត្តិ ប្រឆាំងមិនពេញចិត្តចំពោះយ៉មកដកាតូលិក ង៉ោ-ឌិន-យៀម ដែលរំលោភមកលើពុទ្ធសាសនិករហូតដល់ស្លាប់បាត់បង់ជីវិត ។ ជាទីបំផុត ក្រុមបាតុករ បានសុំឲ្យសម្ដេចព្រះប្រមុខរដ្ឋ ជួយធ្វើអន្តរាគមន៍ជាមួយនឹងសាកលលោក បំបាត់នូវអំពើព្រៃផ្សៃ កាប់សម្លាប់ពុទ្ធសាសនិក នៅវៀតណាមខាងត្បូង កុំឲ្យ-



លោកសង្ឃជាតិយៀកណាម ១ អង្គថ្លែងញត្តិថ្វាយចំពោះសម្តេចព្រះប្រមុខរដ្ឋកម្ពុជា ក្នុងឱកាសបាតុកម្មនៃពុទ្ធសាសនិកខ្មែរប្រឆាំងនឹងការជិះជាន់ព្រះពុទ្ធសាសនានៃរដ្ឋការ ង៉ូ ឌិញ យៀម នៅថ្ងៃទី ១៥ មិថុនា ១៩៦៣ នៅមុខព្រះបរមរាជវាំងចតុមុខ ភ្នំពេញ

មានទៀត ហើយសុំឲ្យព្រមានង៉ោ-ឌិន-យៀម ឲ្យបើកសិទ្ធិសេរីភាព ដល់ពុទ្ធសាសនិក ឲ្យបានទូលាយផង ។

លុះចប់ញត្តិនៃក្រុមបាតុករហើយ សម្តេចព្រះបិតាសន្តិភាពជាតិ ទ្រង់មានព្រះបន្ទូលទៅកាន់កូនចៅយ៉ាងកងរំពង ។

សម្តេចទ្រង់បញ្ជាក់ថា បន្ទាប់ពីព្រះអង្គបានទទួលញត្តិនៃព្រះសង្ឃ ទាំងពីរគណៈហើយ ព្រះអង្គទ្រង់ផ្ញើសារលិខិតទៅកាន់មហាអំណាច ជាច្រើន មានអាមេរិកាំង អង់គ្លេស បារាំងជាដើម ឲ្យគេជួយដាស់តឿន ប្រធានាធិបតីង៉ោ-ឌិន-យៀម ឲ្យលះបង់ចោលនូវអំពើព្រៃផ្សៃកាប់ សម្លាប់ពួកពុទ្ធសាសនិក ហើយព្រះអង្គនឹងចាំតទៅទៀតបំពេញតាម ព្រះសមត្ថភាពដើម្បីធ្វើអន្តរាគមន៍ក្នុងរឿងនេះ ។

នៅពេលចប់ព្រះសន្ទរកថា គួរជាទីទុកចិត្តនៃក្រុមបាតុករហើយ ព្រះសង្ឃជាសមណនិស្សិតបានស្វាធ្យាយធម៌បង្សុកូល ឧទ្ទិសកុសល ចំពោះវិញ្ញាណក្ខន្ធ នៃពុទ្ធសាសនិកជាតិវៀតណាមខាងត្បូង ដែលបាត់ ជីវិតក្នុងការតស៊ូ ដើម្បីការពារព្រះពុទ្ធសាសនា នៅវៀតណាមខាងត្បូង ។

ក្រោយការស្វាធ្យាយធម៌បង្សុកូល សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានថ្វាយបង្គំព្រះសង្ឃនឹងលាកូនចៅបាតុករទាំងអស់យាងនិវត្តន៍ចូល កាន់ព្រះបរមរាជវាំងវិញ ។

ចំណែកក្រុមបាតុករផ្នែកព្រះសង្ឃជាតិយួនមហាយាន នឹងពុទ្ធ-

សាសនិកខ្មែរ-យួន ឥស្លាមទាំងប្រុសស្រី បានកាន់បដាសរសេរពាក្យស្លោកប្រឆាំងនឹងការរំលោភសិទ្ធិសេរីភាព លើពុទ្ធសាសនិកនៃរដ្ឋាភិ-បាលព្រៃនគរ ដើរជាជួរយ៉ាងរៀបរយកាត់មុខវាំង ឆ្ពោះទៅតាមវិថីទុកញ៉ាឈុន មហាវិថីព្រះបាទនរោត្តម ហើយបត់ចូលទៅតាមទុកញ៉ាពេជ ។ បាតុករទាំងនោះយកបដាទៅគរគោលទុកនៅមុខស្ថានលោកដំណាងនៃសាធារណរដ្ឋវៀតណាមខាងត្បូង ហើយក្រុមបាតុករបន្ទឺសព្ទសញ្ញាថា « ជយោព្រះពុទ្ធសាសនា » កងរំពងរហូតដល់ម៉ោង ១២ បាតុករបែកខ្ញែកគ្នាទៅកាន់គេហដ្ឋានរៀងខ្លួន ប្រកបដោយវិន័យយ៉ាងស្ងៀមស្ងាត់ ។



សម្តេចព្រះប្រមុខរដ្ឋកម្ពុជា ព្រះនរោត្តមសីហនុ ទ្រង់ថ្លែងតបទៅនឹងបាតុករពុទ្ធសាសនិកខ្មែរនឹងបរទេស ដែលឈរកកកុញច្រើនណែនណាន់ នៅមុខ
ព្រះបរមរាជវាំង ភ្នំពេញ នៅថ្ងៃ ទី ១៨ មិថុនា ១៩៦៣ ដើម្បីប្រឆាំងនឹងអំពើជិះជាន់ពុទ្ធសាសនានៃរដ្ឋការ ង៉ូ ឌិន យៀម នៅវៀតណាមខាងត្បូង។

# សារាចរស្តីអំពីការគាំពារ ថែរក្សា បូរាណវត្ថុជាតិ

ភ្នំពេញ ថ្ងៃទី ៧ កញ្ញា ឆ្នាំ ១៩៦៣

## សារាចរ

---

រដ្ឋលេខាធិការដ្ឋានក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈ ជំរាបមក សហជីវិន ចៅហ្វាយខេត្តគ្រប់ខេត្ត ក្នុងព្រះរាជអាណាចក្រ ។

កម្មវត្ថុ– ការបំពារបំពានលើប្រាសាទនិងការបំផ្លិចបំផ្លាញវត្ថុបូរាណ របស់ជាតិ ។

ខ្ញុំតែងទទួលពត៌មានជាញឹកញាប់ ពីឆ្មាំប្រាសាទទាំងឡាយ នៅតាមខេត្តថា : ថ្វីបើមានសេចក្តីអំពាវនាវដែលក្រសួងខ្ញុំបានធ្វើ មកទល់នឹងសព្វថ្ងៃនេះយ៉ាងណា ក៏ដោយ តាមខិត្តប័ណ្ណក្តី តាមប្រកាសបិទផ្សាយក្តី តាមសម្លេងវិទ្យុជាតិក្តី ឃើញថា សេចក្តីអំពាវនាវទាំងនេះ ដូចជាពុំបានទទួលលទ្ធផលជាក់ស្តែងសោះនៅឡើយ ព្រោះថាការបំពារបំពាន និងការបំផ្លិចបំផ្លាញប្រាសាទនិងវត្ថុបូរាណជាតិ ដោយជនជាតិយើងគាត់ខ្លះ នៅតែមានប្រព្រឹត្តជារឿយៗ ដែលជាហេតុនាំឲ្យមានគ្រោះថ្នាក់មួយយ៉ាងធំដល់អនាគតនៃដំណែលសិល្បៈ របស់បុព្វបុរសជាតិយើង ។ គេតែងសង្កេតឃើញមានជនខ្លះ ជញ្ជូនយកដុំថ្មសិលាបុរាណទៅប្រើការតាមទំនើងចិត្តខ្លួន គឺយកទៅធ្វើជាថ្មសំលៀងកាំបិត ពូថៅ យកទៅពាយ

បំបែកធ្វើជាកំណល់ស្ពានដើរចូលទៅកាន់គេហដ្ឋាន នៅផ្លូវលិចទឹក ឬធ្វើជាកំណល់សសរផ្ទះក៏សឹងមាន លបលួចកាប់ព្រៃឈើដែលរាជការរក្សាទុកជាគ្រឿងលំអប្រាសាទបុរាណ ការសង់លំនៅស្ពាន ឬ ដាំដំណាំក្នុងបរិវេណប្រាសាទជាដើមៗលៗអំពើទាំងនេះ ជាហេតុបំផ្លាញគ្រឹះស្ថានបុរាណរបស់ជាតិបន្តិចម្តង លុះគ្រាវិនាសសូន្យ តែម្តង ទៅអនាគតដ៏ខ្លីនេះជាមិនខាន ។

ក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈ ដែលមានភារៈកិច្ចទទួលខុសត្រូវយ៉ាងធ្ងន់លើប្រាសាទនិងវត្ថុបុរាណទាំងឡាយ ក្នុងព្រះរាជាណាចក្រ ក្រៅអំពីវិធានការណ៍ដែលបានចាត់រួចមកហើយ កំពុងពិនិត្យនឹងធ្វើសេចក្តីព្រាងច្បាប់ថ្មីមួយ ដើម្បីកំណត់ព្រំប្រទល់ប្រាសាទបុរាណឲ្យបានជាក់លាក់ និងគ្រោងជាបទបញ្ញាផ្សេងៗទៀត សម្រាប់ទប់ទល់នឹងអំពើឈ្លានពានគ្រប់បែបយ៉ាង ដូចបានពណ៌នាខាងលើស្រាប់ ។

តែដោយហេតុថា ច្បាប់ថ្មីនេះ ពុំទាន់បានដាក់ឲ្យអនុវត្តនៅឡើយ ក្នុងរយៈពេលជាបណ្តោះអាសន្ននេះ ខ្ញុំសូមសហជីវិន មេត្តាជួយហាមប្រាមយ៉ាងណាដល់ប្រជាពលរដ្ឋយើង កុំឲ្យមានការប្រព្រឹត្តល្មើសបែបនេះទៅទៀត ។ ម្យ៉ាងវិញទៀត បើត្រូវការស្ថាបនាគេហដ្ឋាននៅទីណាមួយដែលមានប្រាសាទបុរាណនៅជិត សូមឲ្យសង់យ៉ាងតិចចម្ងាយ១០០ម៉ែត្រពីប្រាសាទបុរាណនោះជាកំហិត គឺគិតចាប់តាំងពីកំពែងខាងក្រៅទៅ ពោះ

ជាគ្រឹះស្ថាននោះសម្រាប់សាធារណៈប្រយោជន៍ក្តី សម្រាប់ប្រយោជន៍ឯកជនក្តី ។

វិធានការនេះចៀសវាងដើម្បីកុំឲ្យមានការលំបាកគ្រប់យ៉ាងនៅថ្ងៃក្រោយ ក្នុងកិច្ចការពារនឹងជួសជុលប្រាសាទជាតិ ។

ខ្ញុំសង្ឃឹមថា សហជីវិននឹងមុខជាជួយធ្វើសហប្រតិបត្តិការក្នុងរឿងនេះ គ្រាន់តែបានសម្រេចលទ្ធផលល្អជាពុំខាន ។

ហត្ថលេខាៈកូរ-ស៊ី-គ៊ិយ